សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royal de Droit et des Sciences Economiques

Royal University of Law and Economics


**សារណាបញ្ចប់ការសិក្សា**

# ការអនុវត្តច្បាប់ព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ **កញ្ញា ម៉ូ ស្រីម៉ុច**

**កញ្ញា គិន ស្រីតី**

ណែនាំដោយ

លោកគ្រូ **ខួន ម៉ុនធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

ជាបឋមនាងខ្ញុំទាំងពីរនាក់ឈ្មោះ **ម៉ូ ស្រីម៉ុច** និង**គិន ស្រីតី** ជានិសិត្សថ្នាក់បរិញ្ញាបត្រជំនាន់ទី២៤ ឆ្នាំសិក្សា ២០២៣ - ២០២៤ ផ្នែកនីតិសាស្ត្រ ដែលសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**យើងខ្ញុំសូមលើកម្រាមដៃឡើងប្រណម្យ និងលំឱនកាយ ដើម្បីគោរពសម្តែងនូវការដឹងគុណ កតញ្ញូ មេត្តាធម៌ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនចំពោះ៖**

លោកឪពុក **ម៉ូ វណ្ណា** និងអ្នកម្តាយ **សុខ្ន សុផល** ព្រមទាំងលោកឪពុក **យុខ សារឿន** និងអ្នកម្តាយ **ខៃ៉ត មុំ** ដែលជាអ្នកមានគុណដ៏ធំធេងពុំអាចកាត់ថ្លៃបានក្នុងជីវិតរបស់កូន។ លោកអ្នកមានគុណបានផ្តល់កំណើត ចិញ្ចឹមថែរក្សារូបកូន និងទំនុកបម្រុងកូន ហើយបានបំពេញតម្រូវការរបស់កូនដោយមិនឲ្យកូនខ្វះខាតអ្វីឡើយ។ លើលពីនេះទៅទៀតលោកទាំងពីរបានផ្គត់ផ្គង់នូវប្រាក់កាក់ឲ្យកូនបានរៀនសូត្រតាំងពីសាលាមតេយ្យ រហូតដល់ថ្នាក់ឧត្តមសិក្សាដើម្បីឲ្យកូនបានក្រេបយកចំណេះដឹង ដើម្បីជាប្រយោជន៍យកទៅប្រើប្រាស់នាថ្ងៃអនាគត។ ក្រៅពីនេះលោកទាំងពីរបានអប់រំទូន្មានកូនឲ្យខិតខំរៀនសូត្រ ដើម្បីក្លាយជាកូនល្អ សិស្សល្អ មិត្តល្អ និងពលរដ្ឋល្អនៅក្នុងសង្គម និងជៀសវៀងនូវរាល់អំពើមិនល្អទាំងឡាយ។ យើងខ្ញុំមិនអាចបំភ្លេចបាននូវគុណូបការៈដ៏ថ្លៃថ្លា និងធំធេងមិនអាចកាត់ថ្លៃនេះបានឡើយ។ មានតែម្រាមដៃដប់បន់ស្រន់ដល់វត្ថុស័ក្តិសិទ្ធិ សូមជួយថែរក្សាលោកឪពុក និងអ្នកម្តាយ ហើយយើងខ្ញុំនឹងតបស្នងសងគុណលោកទាំងពីរដោយការដឹងគុណជារហូតអស់មួយជីវិត។

ប្រមុខរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត** ព្រមទាំងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ដែលបានដឹកនាំ និងជាចង្កូតសម្រាប់សង្គម រួមទាំងបង្កើតឲ្យមានកាលានុវត្តភាពដ៏គាប់ប្រសើរ និងជម្រុញឲ្យសង្គមជាតិមានការអភិវឌ្ឍ ជឿនលឿន លូតលាស់លើគ្រប់វិស័យទាំងអស់ ជាពិសេសទៅលើវិស័យអប់រំ បើកចំហទៅលើការសិក្សាស្រាវជ្រាវ។ ការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំបានធ្វើឱ្យប្រទេសកម្ពុជាសព្វថ្ងៃនេះ ទទួលបានសុខសន្តិភាព ស្ថេរភាព ហើយធ្វើអោយប្រជាពលរដ្ឋគ្រប់រូបអាចទទួលបានការសិក្សារៀនសូត្រ មិនថាទាំងចំណេះដឹង ឬជំនាញផ្សេងៗ ដើម្បីជាប្រយោជន៍សម្រាប់ការអភិវឌ្ឍសង្គមជាតិឲ្យមានភាពទាន់សម័យ លូតលាស់ជឿនលឿន និងប្រកបដោយវឌ្ឍនភាពថែមទៀត។

យើងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តមបណ្ឌិត លុយ ចន្ណា** ជាសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច សាកលវិទ្យាធិការងព្រឹទ្ធបុរស ព្រមទាំងលោកគ្រូ អ្នកគ្រូសាស្រ្តាចារ្យខ្មែរ និងបរទេសទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានខិតខំបង្ហាត់បង្រៀនយ៉ាងយកចិត្តទុកដាក់ ផ្តល់នូវចំណេះដឹងប្រឹងប្រែងអស់ពីកម្លាំងកាយ កម្លាំងចិត្ត ចំណាយពេលវេលាដ៏មានតម្លៃក្នុងការដឹកនាំ និងណែនាំផ្លូវល្អៗជ្រោមជ្រែង ត្រួសត្រាយផ្លូវសម្រាប់និស្សិតទាំងអស់ ព្រមទាំងពង្រឹងគុណភាពកម្មវិធីសិក្សាដល់និស្សិតគ្រប់ជំនាញប្រកបដោយប្រសិទ្ធភាពការងារខ្ពស់ ជាពិសេសជម្រុញលើកទឹកចិត្ត រួមទាំងជួយតម្រង់ទិសយើងចាប់ពីឆ្នាំទី១ រហូតដល់ឆ្នាំទី៤ ដើម្បីឲ្យទទួលបានពុទ្ធិច្បាស់លាស់ដើម្បីក្លាយជាសសរទ្រូងរបស់ជាតិ អាចបម្រើនិងសងគុណដល់សង្គមជាតិ។ ជាចុងក្រោយយើងខ្ញុំសូមប្រសិទ្ធពរជ័យដល់ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការង ព្រឹទ្ធបុរស ព្រមទាំងលោកគ្រូ អ្នកគ្រូសាស្រ្តាចារ្យខ្មែរ និងបរទេសទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ឱ្យមានសុខភាពល្អ សុភមង្គល និងទទួលបានជោគជ័យក្នុងគ្រប់ភារកិច្ចទាំងអស់។

ជាពិសេស យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះលោកគ្រូ **ឌួន ម៉ុនធី** ដែលបានណែនាំ និងផ្តល់យោបល់ល្អៗក្នុងការដឹកនាំការស្រាវជ្រាវលើប្រធានបទសារណាបញ្ចប់ការសិក្សាមួយនេះ ដែលលោកគ្រូបានលះបង់ពេលវេលាដ៏មានតម្លៃ ខិតខំអស់ពីកម្លាំងកាយចិត្ត និងយកចិត្តទុកដាក់ក្នុងការពន្យល់ណែនាំ ចង្អុលបង្ហាញឲ្យយើងខ្ញុំអាចសម្រេចកិច្ចការនេះប្រកបដោយជោគជ័យ។ ការជួយណែនាំ ការដឹកនាំបំភ្លឺផ្លូវ ហើយបានផ្តល់ជាបទពិសោធន៍ដ៏មានគុណតម្លៃរបស់លោកគ្រូកន្លងមក បានបង្រៀនឲ្យយើងខ្ញុំយល់ច្បាស់ពីប្រធានបទនេះ ទើបធ្វើឲ្យយើងខ្ញុំសម្រេចបាននូវការតាក់តែងសារណាបញ្ចប់ការសិក្សាប្រកបដោយគុណភាព។

សិស្សច្បង និងមិត្តនិស្សិត ដែលបានគាំទ្រ លើកទឹកចិត្ត ផ្តល់ជាគំនិតយោបល់ និងបទពិសោធន៍ល្អៗ ដែលបានជម្រុញឲ្យយើងខ្ញុំកាន់តែមានទឹកចិត្តក្នុងការសរសេរនូវសារណានេះ ដោយមិនរុញរា ដើម្បីទុកជាវិភាគទានក្នុងការសិក្សាស្រាវជ្រាវផ្សេងៗក៏ដូចជាបន្សល់ទុកដល់មិត្តនិស្សិត និងប្អូនៗជំនាន់ក្រោយបានសិក្សាឲ្យកាន់តែស៊ីជម្រៅលើប្រធានបទនេះបន្ថែមទៀត។

មុននឹងធ្វើការបញ្ចប់ នាងខ្ញុំទាំងពីរនាក់សូមលើកម្រាមដៃដប់ បួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោកអោយតាមជួយថែរក្សាលោកអ្នកទាំងអស់គ្នាដែលបានរៀបរាប់ខាងលើអោយជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើន និងជួបនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្នុងការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រអស់រយៈពេល ០៤ឆ្នាំកន្លងមកនេះ ដោយបានឆ្លងកាត់ការបង្ហាត់បង្រៀនពីសំណាក់លោកគ្រូ អ្នកគ្រូដែលជាសាស្ត្រាចារ្យ ព្រមទាំងទទួលបានការណែនាំបន្ថែមពីរៀមច្បង ជម្រុញអោយនាងខ្ញុំយល់ដឹងកាន់តែច្រើនទៅលើជំនាញនេះ។ ការចំណាយពេលសិក្សាចាប់តាំងពីឆ្នាំទី១ រហូតដល់ឆ្នាំទី៤ នាងខ្ញុំបានសិក្សាទៅលើមុខវិជ្ជាជាច្រើន ក្នុងនោះផងដែរនាងខ្ញុំក៏បានសិក្សារួចមកហើយអំពីក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ហើយរួមផ្សំនឹងកត្តាចំណង់ចំណូលចិត្តទៅលើការអនុវត្តច្បាប់ព្រហ្មទណ្ឌ ទើបជាហេតុនាំអោយក្រុមយើងខ្ញុំសម្រេចចិត្តយកប្រធានបទនេះឡើងមកពន្យល់បកស្រាយដើម្បីអោយអ្នកសិក្សាទាំងឡាយបានសិក្សាស្វែងយល់បន្ថែមទៅលើដែនកំណត់របស់ការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងព្រះរាជាណាចក្រកម្ពុជា។

ចំពោះការស្រាវជ្រាវទៅលើប្រធានបទមួយនេះ គឺក្រុមយើងខ្ញុំបានធ្វើការស្រាវជ្រាវនូវរាល់ឯកសារពាក់ព័ន្ធនានាដូចជាច្បាប់ បទដ្ឋានគតិយុត្ត សៀវភៅសាស្ត្រាចារ្យ វេបសាយ ដើម្បីធ្វើជាមូលដ្ឋាននៃការស្រាវជ្រាវ។ ដើម្បីអាចបង្កើតសៀវភៅនេះបាន យើងខ្ញុំបានលះបង់កម្លាំងកាយ ព្រមទាំងកម្លាំងចិត្ត និងថវិកាផ្ទាល់ខ្លួន ប្រើរយៈពេលប្រមាណជាជាង ២ខែ។ ចំពោះផលវិបាកក្នុងការស្រាវជ្រាវ គឺឯកសារដែលទាក់ទងពុំសូវជាមានច្រើន។ ទោះជាយ៉ាងណាក៏ដោយ យើងខ្ញុំសង្ឃឹមថាការសិក្សាស្រាវជ្រាវមួយនេះនឹងរួមចំណែកផ្តល់ជាចំណេះដឹង ជាស្មារតីសម្រាប់និស្សិត អ្នកសិក្សាស្រាវជ្រាវស្វែងយល់ពីប្រធានបទមួយនេះ នឹងអាចធ្វើជាទុនបន្ថែមក្នុងការសិក្សា។ តាមរយៈការស្រាវជ្រាវប្រធានបទមួយនេះ យើងសង្កេតឃើញថាឯកសារជំនួយស្មារតីពាក់ព័ន្ធប្រធានបទមួយនេះ ហាក់បីដូចជាមិនទាន់គ្រប់គ្រាន់នៅឡើយទេ។ ហេតុនេះយើងខ្ញុំសូមទទួលយកការរិះគន់ទាំងឡាយណា ក្នុងន័យជួយស្ថាបនានូវកិច្ចការស្រាវជ្រាវមួយនេះឲ្យកាន់តែប្រសើរឡើងថែមទៀត។ ម្យ៉ាងទៀតក៏សូមអភ័យទោសទុកជាមុននូវរាល់កំហុសខុសឆ្គង ដែលកើតឡើងទាំងផ្នែកបច្ចេកទេស ខ្លឹមសារ ពាក្យពេចន៍មួយចំនួនមានភាពខ្វះចន្លោះ ដោយអចេតនាណាមួយនៃការស្រាវជ្រាវមួយនេះផងដែរ។

ដូច្នេះរាល់ការស្រាវជ្រាវ គឺតែងតែមានចំណុចវិជ្ជមាន និងចំណុចអវិជ្ជមានមួយចំនួនដែលជាការឆ្គាំឆ្គងកើតមានផងដែរ។ ដូចនេះហើយ យើងខ្ញុំសូមឲ្យបងប្អូនមិត្តនិស្សិត ក៏ដូចជាមិត្តអ្នកអាន សាស្ត្រាចារ្យសូមមេត្តាជួយកែតម្រូវ និងបំពេញចំណុចខ្វះខាត និងកំហុងឆ្គងដោយអចេតនារបស់យើងខ្ញុំដោយក្តីអនុគ្រោះ។

# មាតិកា

ទំព័រ


**សេចក្តីផ្តើម**

១. លំនាំបញ្ហា ...... ១

២. ចំណោទបញ្ហា ...... ៣

៣. គោលបំណងនៃការស្រាវជ្រាវ...... ៤

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ...... ៤

៥. សារសំខាន់នៃការស្រាវជ្រាវ ...... ៥

៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ...... ៥

**ជំពូកទី ១**

**សញ្ញាណទូទៅនៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា**

**១.១. ការកកើតនៃក្រមព្រហ្មទណ្ឌ** ...... ៧

១.១.១. ការកកើត...... ៧

១.១.១.១. ការរៀបចំតាក់តែង ......១៨

១.១.១.២. ការអនុម័តច្បាប់......១៩

១.១.១.៣. ការប្រកាសអោយប្រើ ......១៩

១.១.២. ប្រភពនៃក្រមព្រហ្មទណ្ឌ ...... ២០

១.១.២.១. ប្រភពជាតិ ...... ២០

១.១.២.២. ប្រភពអន្តរជាតិ......២២

**១.២. ទំនាក់ទំនងនៃក្រម** ...... ២៣

១.២.១. ចំណែកចែកក្រម...... ២៣

១.២.១.១. ផ្នែកទូទៅ...... ២៣

១.២.១.២. ផ្នែកពិសេស...... ២៣

១.២.២. គោលបំណងនៃក្រម...... ២៤

១.២.៣. គោលបំណងនៃទោសកំណត់ដោយក្រម ..... ២៤

## ជំពូកទី ២

## ការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងពេលវេលា

**២.១. គោលការណ៍ទាក់ទងនឹងការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា** ..... ២៥
២.១.១. ការចូលជាធរមាន និងការចាប់ផ្ដើមអនុវត្ត ..... ២៥
២.១.២. គោលការណ៍នីត្យានុគោលភាព ..... ២៦
២.១.២.១. គោលការណ៍បកស្រាយច្បាប់ព្រហ្មទណ្ឌ ..... ២៨
**២.២. ការអនុវត្តចំពោះច្បាប់ព្រហ្មទណ្ឌគ្រឹះ ឬច្បាប់សារធាតុ** ..... ២៩
២.២.១. គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ..... ៣០
២.២.២. អញ្ញត្រកម្មនៃគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ..... ៣២
២.២.២.១. ការអនុវត្តច្បាប់ព្រហ្មទណ្ឌដែលលុបចោលបទល្មើស ..... ៣៣
២.២.២.២. ការអនុវត្តច្បាប់ព្រហ្មទណ្ឌស្រាលជាងដែលបញ្ញត្តិអំពីទោស ..... ៣៣
**២.៣. ការអនុវត្តចំពោះច្បាប់ព្រហ្មទណ្ឌទម្រង់ ឬច្បាប់នីតិវិធី** ..... ៣៥

## ជំពូកទី ៣

## ការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជានៅក្នុងលំហ

**៣.១. ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា** ..... ៣៧
៣.១.១. ការអនុវត្តចំពោះបទល្មើសដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា..... ៣៧
៣.១.១.១. សញ្ញាណទូទៅនៃដែនដីនៃព្រះរាជាណាចក្រកម្ពុជា ..... ៣៨
៣.១.១.២. ការអនុវត្តច្បាប់ព្រហ្មទណ្ឌចំពោះទីតាំងទូត ឬស្ថានកុងស៊ុលរបស់ព្រះរាជាណាចក្រកម្ពុជានៅឯបរទេស ..... ៤១
៣.១.១.៣. ការអនុវត្តចំពោះអំពើដែលបានចាប់ផ្ដើមប្រព្រឹត្តនៅកម្ពុជា ..... ៤២
៣.១.១.៤. ការកម្រិតនៃដែនដី ..... ៤២
៣.១.២. ការមិនអនុវត្តច្បាប់ព្រហ្មទណ្ឌនៅលើដែនដីកម្ពុជាតាមកិច្ចព្រមព្រៀងអន្តរជាតិ..... ៤៤
៣.១.៣. ការចាត់ទុកថាជាដែនដីនៃព្រះរាជាណាចក្រកម្ពុជា ..... ៤៥

៣.១.៣.១. បទល្មើសដែលប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ........................ ៤៦
៣.១.៣.២. បទល្មើសដែលចាត់ទុកថាបានប្រព្រឹត្តនៅកម្ពុជា........................................... ៤៦
**៣.២. បទល្មើសដែលប្រព្រឹត្តក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា**................................ ៥០
៣.២.១. ការអនុវត្តច្បាប់ព្រហ្មទណ្ឌតាមគោលការណ៍សញ្ជាតិ.................................... ៥០
៣.២.១.១. បទល្មើសដែលមានជនល្មើសជាពលរដ្ឋខ្មែរ .................................................. ៥០
៣.២.១.២. បទល្មើសដែលមានជនរងគ្រោះជាពលរដ្ឋខ្មែរ............................................... ៥២
៣.២.១.៣. លក្ខខណ្ឌនៃការចោទប្រកាន់ ..................................................................... ៥៣
៣.២.២. បទល្មើសដែលប្រឆាំងនឹងកម្ពុជា ..................................................................... ៥៣
៣.២.២.១. បទល្មើសដែលប្រឆាំងនឹងសុវត្ថិភាពនៃកម្ពុជាព្រះរាជាណាចក្រកម្ពុជា................ ៥៤
៣.២.២.២. បទល្មើសក្លែងត្រាផ្លូវការ ........................................................................... ៥៧
៣.២.២.៣. បទល្មើសក្លែងរូបិយវត្ថុ និងធនបត្រជាតិនៃព្រះរាជាណាចក្រកម្ពុជា.................... ៥៧
៣.២.២.៤. បទល្មើសប្រឆាំងភ្នាក់ងារទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា .................. ៥៩
៣.២.២.៥. បទល្មើសប្រឆាំងនឹងទីតាំង ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា...................... ៦០
៣.២.៣. ការមិនចោទប្រកាន់ត្រួតគ្នា និងទោស ........................................................... ៦១
**សេចក្តីសន្និដ្ឋាន**....................................................................................................... ៦៤
**អនុសាសន៍**............................................................................................................. ៦៦
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់មនុស្សតែងតែមានការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក។ ក្នុងនោះផងដែរក៏បាននាំមកនូវការប្រព្រឹត្តនូវរាល់អំពើផ្ទុយនឹងច្បាប់ជាច្រើន ហើយដើម្បីការពារកុំអោយកើតមាននូវបទល្មើស និងអំពើដែលនាំអោយអសន្តិសុខដល់សង្គមជាតិ និងសណ្តាប់ធ្នាប់សាធារណៈ ថ្នាក់ដឹកនាំប្រទេសរមែងរិះករាល់គ្រប់មធ្យោបាយធ្វើយ៉ាងណាបង្ការមិនអោយមាន ឬកាត់បន្ថយការប្រព្រឹត្តបទល្មើស និងបង្ក្រាបអោយបានចំពោះអំពើដែលប្រព្រឹត្តផ្ទុយនឹងច្បាប់។ ជាក់ស្តែងប្រទេសជាតិមួយមានអត្រានៃការប្រព្រឹត្តបទល្មើសទាបអាចធានាបានថាការរស់នៅរបស់ប្រជាជន គឺប្រកបដោយសន្តិសុខ សុវត្ថិភាពល្អ។ បើយើងក្រឡេកមកមើលប្រទេសកម្ពុជាយើងវិញ បន្ទាប់ពីឆ្លងកាត់សង្គ្រាមជាច្រើនសម័យកាល យើងសង្កេតឃើញថាវិស័យជាច្រើននៅក្នុងប្រទេសកម្ពុជាបានកំពុងនឹងរីកលូតលាស់យ៉ាងលឿនគួរអោយកត់សម្គាល់ អាចនិយាយបានថា កម្ពុជាជាប្រទេសកំពុងអភិវឌ្ឍន៍លើគ្រប់វិស័យ ក្រោមការដឹកនាំប្រកបដោយភាពឈ្លាសវៃក្នុងគោលនយោបាយឈ្នះៗ។ ក្នុងនោះយើងក៏សង្កេតឃើញថាវិស័យយុត្តិធម៌ គឺបានធ្វើនូវកំណែទម្រង់យ៉ាងលឿនគួរអោយកត់សម្គាល់ ដូចដែលយើងបានដឹងស្រាប់មកហើយថា បច្ចុប្បន្នយើងមានក្រមធំៗចំនួនបួនរួមមាន៖ **ក្រមព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមនីតិវិធីរដ្ឋប្បវេណី។** ក្នុងនោះបើយើងនិយាយអំពីក្រមព្រហ្មទណ្ឌវិញ ជាលទ្ធផលនៃការងារអស់រយៈពេលជាង១០ឆ្នាំ របស់ក្រសួងយុត្តិធម៌ ដែលបានរៀបចំឡើងដោយមានជំនួយពីកិច្ចសហប្រតិបត្តិការបារាំង។ ក្រសួងយុត្តិធម៌បានចាប់ផ្តើមរៀបចំឱ្យមានក្រមព្រហ្មទណ្ឌថ្មីតាំងពីឆ្នាំ១៩៩៨ ដើម្បីឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងនៃប្រទេសកម្ពុជា ហើយបានរៀបចំក្រមនេះ ដោយផ្អែកលើគោលការណ៍ធំៗនៃប្រព័ន្ធច្បាប់អន្តរជាតិ ប្រពៃណីច្បាប់ព្រហ្មទណ្ឌកម្ពុជា បទប្បញ្ញត្តិព្រហ្មទណ្ឌដែលមានស្រាប់ និងបរិបទថ្មីៗដែលកំពុងប្រឈម។ ឈរលើមូលដ្ឋាននេះ ក្រមព្រហ្មទណ្ឌកម្ពុជាត្រូវបានបង្កើតឡើងដោយគិតគូរអំពីគោលការណ៍ចម្បងៗពាក់ព័ន្ធដោយផ្ទាល់ និងដោយប្រយោលទៅនឹងនីតិព្រហ្មទណ្ឌ ដែលមានចរឹកក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងក្នុងបណ្តាបទដ្ឋានអន្តរជាតិនានាដែលកម្ពុជាទទួលស្គាល់ និងផ្តល់សច្ចាប័ន។ ក្រមព្រហ្មទណ្ឌ គឺជាបណ្តុំរាល់បទប្បញ្ញត្តិព្រហ្មទណ្ឌទាំងឡាយ ក្នុងនោះបទប្បញ្ញត្តិមួយផ្នែកចែងអំពីគោលការណ៍គ្រឹះ និងវិធានរួមនៅក្នុងនីតិព្រហ្មទណ្ឌសម្រាប់ចៅក្រមយកទៅអនុវត្តក្នុងការផ្តល់យុត្តិធម៌ក្នុងរឿងព្រហ្មទណ្ឌ និងបទប្បញ្ញត្តិមួយផ្នែកទៀត ចែងអំពីបទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោស។ ក្រមព្រហ្មទណ្ឌមានចរិត និងគោលដៅចម្បងបម្រើឱ្យប្រយោជន៍សាធារណៈ តាមរយៈការធានារក្សាការពារសណ្តាប់ធ្នាប់សាធារណៈ សន្តិសុខសង្គម សិទ្ធិ

សេរីភាពបុគ្គល សេចក្តីថ្លៃថ្នូរ និងភាពសុខសាន្តជូនប្រជាជន។ ដើម្បីធានាដល់គោលការណ៍នីត្យានុភាពនៃច្បាប់ព្រហ្មទណ្ឌ ការរៀបចំក្រមព្រហ្មទណ្ឌថ្មីត្រូវបានចងក្រងជាលំអិតក្នុងការកំណត់ជាគោលការណ៍ទូទៅ និងប្រភេទបទល្មើសនីមួយៗឲ្យសព្វគ្រប់ និងជាក់ច្បាស់បញ្ចៀសរាល់អំពើទាំងឡាយណាដែលបំផ្លាញដល់សង្គមបានរួចផុតពីការដាក់ទោសទណ្ឌ។ ក្រមព្រហ្មទណ្ឌត្រូវបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ និងដោយព្រឹទ្ធសភា នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៩ ហើយត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។ ការអនុម័ត និងប្រកាសឲ្យប្រើក្រមនេះជាសក្ខីភាពមួយនៃសមិទ្ធកម្មក្នុងការធ្វើទំនើបនីយកម្មក្របខណ្ឌច្បាប់ និងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌស្របតាមគោលនយោបាយកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌របស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបច្ចុប្បន្នលោកជាប្រធានព្រឹទ្ធសភា។** ជាគោលការណ៍នៃការចូលជាធរមានរបស់ច្បាប់ ត្រូវបានរដ្ឋធម្មនុញ្ញកំណត់ថា "ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ ហើយត្រូវបានព្រះមហាក្សត្រទ្រង់លាយព្រះហស្តលេខាប្រកាសឱ្យប្រើ ត្រូវចូលជាធរមាននៅរាជធានីភ្នំពេញ ក្នុងរយៈពេល ១០ថ្ងៃគត់ ក្រោយថ្ងៃប្រកាស់ឱ្យប្រើ និងនៅទូទាំងប្រទេសក្នុងរយៈពេល ២០ថ្ងៃគត់ ក្រោយថ្ងៃប្រកាសឱ្យប្រើ។ ប៉ុន្តែ បើច្បាប់នេះបានចែងថាជាការប្រញាប់ ច្បាប់នេះត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេស ក្រោយថ្ងៃប្រកាសឱ្យប្រើ។ ក្រមព្រហ្មទណ្ឌត្រង់មាត្រា ៦៧២ ចែងថា "បទប្បញ្ញត្តិនៃគន្ថីទី១ ស្តីពីបទប្បញ្ញាត្តិទូទៅ ត្រូវយកទៅអនុវត្តភ្លាមក្រោយពីចូលជាធរមាន" ដែលគិតចាប់ពីមាត្រា ១ ដល់មាត្រា ១៨២ នៃក្រមព្រហ្មទណ្ឌ "ប៉ុន្តែចំពោះបទប្បញ្ញាត្តិដទៃទៀត នៃក្រមព្រហ្មទណ្ឌអាចត្រូវយកទៅអនុវត្តបានក្នុងរយៈពេល ១ឆ្នាំក្រោយការចូលជាធរមាននៃក្រមនេះ" ។ ក្រមព្រហ្មទណ្ឌ គឺជាបទបញ្ញត្តិច្បាប់ដែលចែងអំពីបទល្មើស និងទោសត្រូវអនុវត្តទៅលើបុគ្គលដែលបានប្រព្រឹត្តល្មើសនឹងច្បាប់ព្រហ្មទណ្ឌ ក្រមព្រហ្មទណ្ឌត្រូវបានចាត់ទុកជាច្បាប់ទូទៅ ហើយក៏មានច្បាប់ពិសេសផ្សេងៗទៀតដែលត្រូវយកមកអនុវត្តទន្ទឹមនឹងគ្នាផងដែរ ដូចជាច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីរបបសារពត៌មានជាដើម។ ជារួមច្បាប់ព្រហ្មទណ្ឌរមែងចែងពីបទល្មើស ទោស និងការទទួលខុសត្រូវចំពោះបទល្មើស។ ហើយបើយើងនិយាយពីសាខានៃនីតិព្រហ្មទណ្ឌវិញ គឺថានីតិព្រហ្មទណ្ឌនេះគឺត្រូវបានគេធ្វើការបែងចែកជា ៣ សណ្ឋានរួមមាន៖ នីតិព្រហ្មទណ្ឌទូទៅ នីតិព្រហ្មទណ្ឌពិសេស និងនីតិវិធីព្រហ្មទណ្ឌ។

- នីតិព្រហ្មទណ្ឌទូទៅ ជាកម្រងអត្ថបទច្បាប់ដែលសិក្សាអំពីគោលការណ៍ទូទៅដូចជា៖ ការសិក្សាលើដែនអនុវត្តច្បាប់ព្រហ្មទណ្ឌ ចំណាត់ថ្នាក់នៃបទល្មើស ការទទួលខុសត្រូវច្បាប់ព្រហ្មទណ្ឌ ប្រភេទនៃទោស និងជាពិសេសសិក្សាលើគោលការណ៍ការអនុវត្តទោស។ល។

- នីតិព្រហ្មទណ្ឌពិសេស ជាកម្រងអត្ថបទច្បាប់ដែលសិក្សាអំពីបទល្មើស ប្រភេទបទល្មើស និងអំពីការបែងចែងប្រភេទនៃទោស ដូចជាទោសក្នុងបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុជាដើម។ អត្ថបទច្បាប់នេះសិក្សាលើនិយមន័យ អត្ថន័យ និងធាតុផ្សំនៃបទល្មើសនីមួយៗ។ នីតិព្រហ្មទណ្ឌពិសេស គឺត្រូវបានដាក់ឲ្យប្រើប្រាស់ ឬចូលជាធរមាន ១ឆ្នាំក្រោយការប្រកាសអោយប្រើនូវនីតិព្រហ្មទណ្ឌទូទៅ។ ហើយចំពោះក្រមព្រហ្មទណ្ឌនេះមានគោលបំណងរក្សានូវសុខសុវត្ថិភាពក៏ដូចជាធ្វើអោយមាននូវស្ថេរភាពសង្គមតាមរយៈការដាក់ទណ្ឌកម្មទៅលើជនដែលបានប្រព្រឹត្តនូវទង្វើរដែលផ្ទុយពីច្បាប់។ តែបើទោះបីជាមានអំពើយ៉ាងណាក៏ដោយ បើសិនជាអំពើនោះពុំមានចែងនៅក្នុងច្បាប់ ឬក៏ច្បាប់ចាត់ថាអំពើនោះពុំមែនជាបទល្មើសទេនោះ គឺប្រាកដណាស់ជនដែលបានបង្ករអំពើនោះគឺពុំមានឡើយ។
- នីតិវិធីព្រហ្មទណ្ឌ ជាកម្រងអត្ថបទច្បាប់ដែលសិក្សាអំពីវិធានទាំងឡាយស្តីពីការរៀបចំ ការប្រព្រឹត្តទៅនៃស្ថាប័នតុលាការព្រហ្មទណ្ឌគ្រប់ជាន់ថ្នាក់ និងកំណត់នូវវិធានស្តីពីនីតិវិធីចោទប្រកាន់ នីតិវិធីស៊ើបអង្កេត នីតិជំនុំជម្រះ ព្រមទាំងកំណត់អំពីសិទ្ធិអំណាចទាំងឡាយនៃអង្គចៅក្រម មេធាវី មន្ត្រីនគរបាល មន្ត្រីយុត្តិធម៌ គូភាគី សាក្សី អ្នកជំនាញ។ល។ ក្រមនីតិវិធីព្រហ្មទណ្ឌត្រូវបានសភាអនុម័តកាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៧ ហើយក៏ត្រូវបានព្រះមហាក្សត្រទ្រង់ប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ក្រោយពីព្រឹទ្ធសភាអនុម័តយល់ព្រមនាថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧ ដោយមាន ៦១២ មាត្រា ដោយចែកជា ១១គន្ថី ផងដែរ។

## ២. ចំណោទបញ្ហា

ជាទូទៅរាល់បទដ្ឋានគតិយុត្តនីមួយៗសុទ្ធតែបានកំណត់នូវដែនអនុវត្ត។ ក្នុងនោះផងដែរក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩ ក៏មានវិសាលភាពអនុវត្តមិនខុសពីអត្ថបទច្បាប់ព្រះរាជាណាចក្រកម្ពុជាដែលធ្លាប់មានពីមុន និងអត្ថបទច្បាប់របស់រដ្ឋដទៃទៀតដែរ។ ដែនអនុវត្តនេះត្រូវបានចែងក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចាប់ពីមាត្រា ៩ ដល់មាត្រា ២៣ ។ ការកំណត់អំពីដែនអនុវត្តត្រូវបានបែងចែកចេញជាពីរផ្នែកគឺ៖ **ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា និងការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងលំហ**។ ទោះបីជាមានបទប្បញ្ញត្តិចែងច្បាស់អំពីវិសាលភាពនៃការអនុវត្តក្រមនេះក៏ដោយក៏យើងនៅតែមើលឃើញអំពីបញ្ហាមួយចំនួនដែលកើតមានឡើងចំពោះការអនុវត្តផ្ទាល់ផងដែរ។

ដោយសារតែបទប្បញ្ញត្តិដែលចែងអំពីវិសាលភាពនៃការអនុវត្តនៅក្នុងក្រមនេះ ចែងតែអំពីចំណុចគោលធំៗប៉ុណ្ណោះ ដែលជាហេតុនាំឱ្យអ្នកសិក្សា និងអ្នកអនុវត្តមួយចំនួននៅមិនទាន់មានភាពច្បាស់លាស់អំពីការអនុវត្តដោយចំណុចលម្អិតផ្សេងនៃការអនុវត្ត គឺស្ថិតនៅក្នុងអត្ថបទច្បាប់ជាតិជាច្រើនដែលកំណត់អំពី

ការអនុវត្តរួមទាំងកិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀតដែលមានដូចជា សន្ធិសញ្ញា អនុសញ្ញា ឬកតិកាសញ្ញា ជាដើម។ ក្នុងនាមជាភាគីហត្ថលេខីនៅក្នុងកិច្ចព្រមព្រៀងអន្តរជាតិផ្សេងៗ ដែលចែងពាក់ព័ន្ធជាមួយនឹងការអនុវត្តច្បាប់ព្រហ្មទណ្ឌ យើងឃើញថានៅមានភាពស្មុគស្មាញនៅឡើយ សម្រាប់ការយកក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ នេះយកទៅអនុវត្ត ជាពិសេសចំពោះបទល្មើសព្រហ្មទណ្ឌដែលមានការលាយបញ្ចូលគ្នាជាមួយធាតុផ្សបរទេស។ សម្រាប់ការអនុវត្តក្រមព្រហ្មទណ្ឌនេះមានភាពស្មុគស្មាញ ទើបបានជានាំអោយមានការលើកយកនូវប្រធានបទមួយនេះមកធ្វើការសិក្សា និងស្វែងយល់បន្ថែម។

**តើការអនុវត្តច្បាប់ព្រហ្មទណ្ឌមានទំហំវិសាលភាពយ៉ាងដូចម្តេច? ហើយការអនុវត្តច្បាប់នេះបែងចែកចេញជាប៉ុន្មានប្រភេទ? អ្វីខ្លះ?**

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ គឺមានគោលបំណងដើម្បីរកអំពីចំណុចលម្អិតនីមួយៗ និងធ្វើការសិក្សាស្វែងយល់អោយកាន់តែច្បាស់ចំពោះបទប្បញ្ញត្តិដែលចែងអំពីវិសាលភាពនៃដែនអនុវត្តក្រមព្រហ្មទណ្ឌកម្ពុជា។ ភាពប្រតិសកម្ម និងមិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ជាពិសេសចំពោះបទល្មើស ដែលបានកើតឡើងទាក់ទងជាមួយនឹងទីកន្លែងប្រព្រឹត្តបទល្មើស ឬក៏អ្នកដែលចូលរួមពាក់ព័ន្ធក្នុងបទល្មើស។ ដោយហេតុថាការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងពេលវេលា និងការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងលំហ គឺពិតជាមានលក្ខណៈស្មុគស្មាញ និងប្រទាក់ក្រឡាគ្នាយ៉ាងខ្លាំង ដែលទាមទារអោយយើងមានការបកស្រាយច្រើន ហើយក៏ទាមទារអោយយើងធ្វើការស្រាវជ្រាវទាំងបទដ្ឋានគតិយុត្តិជាតិ រួមទាំងបទដ្ឋានគតិយុត្តិអន្តរជាតិផងដែរ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ដូចដែលយើងបានដឹងស្រាប់ហើយថា នីតិព្រហ្មទណ្ឌ គឺពិតជាមានភាពទូលំទូលាយណាស់ដែលពាក់ព័ន្ធទៅនឹងរបៀបកំណត់នូវបទល្មើស ទោស សម្រាប់អនុវត្តទៅលើជនដែលបានប្រព្រឹត្តបទល្មើស ឋានៈនៃអ្នកចូលរួមប្រព្រឹត្តបទល្មើស ប្រធាននៃបទល្មើស ការកំណត់អំពីបុគ្គលដែលច្បាប់ចាត់ថាបានប្រព្រឹត្តនូវអំពើដែលនាំឲ្យមានទោស និងការប្រព្រឹត្តនូវអំពើមួយចំនួនទៀត ប៉ុន្តែច្បាប់កំណត់ថាពុំមានទោសឡើយប្រសិនបើបានបំពេញនូវលក្ខខណ្ឌមួយចំនួនដែលច្បាប់បានតម្រូវឲ្យធ្វើ ហើយក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ក៏បានកំណត់ផងដែរពីអានុភាពនៃច្បាប់នេះដែលមានវិសាលភាពអនុវត្តនៅទូទាំងប្រទេស រហូតដល់អាចពន្លាតបានដល់រដ្ឋបរទេសដែលពលរដ្ឋខ្លួនបាននឹងកំពុងស្នាក់នៅ រួមទាំងពេលវេលានៃការអនុវត្តច្បាប់នេះ មុននិងក្រោយការចូលជាធរមានទៀតផងដែរ។ ប៉ុន្តែបើទោះបីជានៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ មានចែងនូវចំណុច ឬទ្រឹស្តីនៃការអនុវត្តជាច្រើនក៏ដោយក៏នៅក្នុងបរិបទនៃការស្រាវជ្រាវនេះ គឺយើងខ្ញុំទាំងពីរនាក់សូមលើកយកតែប្រធាន

បទស្តីអំពី « **ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា** » មកធ្វើការស្រាវជ្រាវតែប៉ុណ្ណោះ។ ហើយទោះបីជាបានដឹងថា ប្រធានបទមួយនេះក៏ធ្លាប់ត្រូវបានរៀមច្បងជំនាន់មុនៗបានយកមកធ្វើជាប្រធានបទសិក្សាស្រាវជ្រាវរួចហើយក៏ដោយ ក៏ពួកនាងខ្ញុំយកប្រធានបទមួយនេះមកធ្វើការសិក្សាស្រាវជ្រាវបន្ថែមដោយបង្កើតនូវគំនិតថ្មីៗ និងវិធីសាស្ត្រថ្មីៗដើម្បីជាពុទ្ធិបន្ថែមដល់អ្នកសិក្សាជំនាន់ក្រោយបានអាន និងបានយល់ទៅលើប្រធានបទមួយនេះបន្ថែមទៀត។

## ៥. សារសំខាន់នៃការស្រាវជ្រាវ

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ ក៏ដូចជាស្វែងយល់បន្ថែមទាក់ទងទៅលើប្រធានបទស្តីពី « **ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា** » នាំអោយនាងខ្ញុំទាំងពីរនាក់ទទួលបាននូវចំណេះដឹងយ៉ាងច្រើន ដែលពាក់ព័ន្ធទៅលើវិសាលភាពនៃការអនុវត្តក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ ចំពោះបទល្មើសដែលបានប្រព្រឹត្តមុន ឬក្រោយក្រមព្រហ្មទណ្ឌនេះចូលជាធរមាន។ មានន័យថា បើទោះបីជាបទល្មើសបានកំពុងនឹងប្រព្រឹត្ត ឬក៏ធ្វើការចោទប្រកាន់នានាពីសំណាក់អង្គការអយ្យការទាំងដែលបទល្មើសនេះស្ថិតក្រោមអានុភាពនៃច្បាប់ចាស់ ហើយច្បាប់ថ្មីដែលជាក្រមព្រហ្មទណ្ឌយើងនេះពុំបានចែងពីបទល្មើសនោះទេ ការចោទប្រកាន់ដែលកំពុងប្រព្រឹត្តទៅនោះត្រូវបញ្ចប់។ ប្រសិនបើការផ្តន្ទាទោសជាស្ថាពរត្រូវបានប្រកាសរួចហើយ ទោសដែលចេញអំពីការផ្តន្ទាទោសនេះមិនត្រូវអនុវត្តទេ ឬត្រូវតែឈប់អនុវត្ត។ ហើយម៉្យាងទៀតក៏អាចអោយយើងបានស្វែងយល់កាន់តែច្រើនទៅលើរបៀបអនុវត្តក៏ដូចជាសមត្ថកិច្ច និងសិទ្ធអំណាចនៃប្រព័ន្ធតុលាការកម្ពុជានៅពេលដែលមានបទល្មើសណាមួយបានកើតឡើងមិនថាតែក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ឬនៅរដ្ឋក្រៅពីដែនដីនៃប្រទេសកម្ពុជានោះទេ គឺបានសេចក្តីថាច្បាប់ព្រហ្មទណ្ឌកម្ពុជាមានវិសាលភាពអនុវត្តទៅដល់ដែនដីនៃរដ្ឋបរទេសនៅពេលដែលមានបទល្មើសណាមួយបានកើតឡើងដោយឈរលើគោលការណ៍សញ្ជាតិ និងបទឧក្រិដ្ឋដោយឡែកមួយចំនួន។ ទាំងនេះហើយជាអានុភាពនៃច្បាប់ព្រហ្មទណ្ឌកម្ពុជាមានវិសាលភាពទៅលើច្បាប់ព្រហ្មទណ្ឌអន្តរកាលផងនោះដែរ។

លើសពីនេះ ការសិក្សាស្រាវជ្រាវក៏មានគោលបំណងអោយអ្នកអានបានយល់អំពីគោលការណ៍នានាដែលបានកំណត់ទាំងក្នុងក្រមនេះក្តី ឬច្បាប់ដទៃទៀតក្តីដែលមានទំនាក់ទំនងនៅក្នុងការអនុវត្ត។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណាបទនេះរៀបចំឡើងជាភាសាខ្មែរ ដែលទាក់ទងទៅនឹងប្រធានបទនៃការស្រាវជ្រាវស្តីអំពី « **ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅព្រះរាជាណាចក្រកម្ពុជា** » នៅក្នុងនោះផងដែរយើងបានចែក

ចេញជា ៣ ជំពូកធំៗ នៅក្នុងជំពូកនីមួយៗក៏បានបែងចែកជាចំណុចតូចៗជាច្រើនទៀត និងមាន ៦៦ទំព័រ ហើយយើងនឹងធ្វើការបកស្រាយអំពីចំណុចសំខាន់ៗទាក់ទងទៅនឹងប្រធានបទដែលមានដូចតទៅៈ

- **ជំពូកទី១ សញ្ញាណទូទៅនៃក្រមព្រហ្មទណ្ឌកម្ពុជា**
  - **១.១ ការកកើតនៃក្រមព្រហ្មទណ្ឌ**
  - **១.២ ទំនាក់ទំនងនៃក្រម**
- **ជំពូកទី២ ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា**
  - **២.១ គោលការណ៍ទាក់ទងនឹងការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា**
  - **២.២ ការអនុវត្តចំពោះច្បាប់ព្រហ្មទណ្ឌគ្រឹះ ឬច្បាប់សារធាតុ**
  - **២.៣ ការអនុវត្តចំពោះច្បាប់ព្រហ្មទណ្ឌទម្រង់ ឬច្បាប់នីតិវិធី**
- **ជំពូកទី៣ ដែនអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងលំហ**
  - **៣.១ ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា**
  - **៣.២ បទល្មើសដែលប្រព្រឹត្តក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា**

# ជំពូកទី ១
# សញ្ញាណទូទៅនៃក្រមព្រហ្មទណ្ឌ
# នៃព្រះរាជាណាចក្រកម្ពុជា

# ជំពូកទី ១
# សញ្ញាណទូទៅនៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

ប្រទេសកម្ពុជាបានឆ្លងកាត់មកជាច្រើនសម័យកាល ហើយក៏បានជួបប្រទះនឹងសង្គ្រាមជាញឹកញាប់ មិនថាជាសង្គ្រាមស៊ីវិល (រវាងខ្មែរ និងខ្មែរ) ឬក៏សង្គ្រាមជាមួយរដ្ឋជិតខាង (ថៃ វៀតណាម) ថែមទាំងអស្ថេរភាពនយោបាយថែមទៀតផង ទើបនាំអោយក្រម ច្បាប់នានា ជាពិសេសរដ្ឋធម្មនុញ្ញមានការផ្លាស់ប្តូរ និងកែប្រែជាបន្តបន្ទាប់ទម្រាំតែសម្រេចបាននូវរដ្ឋធម្មនុញ្ញដូចពេលបច្ចុប្បន្ននេះ។ បើក្រឡេកមកមើលក្រមព្រហ្មទណ្ឌយើងបច្ចុប្បន្នវិញ មុននឹងមានក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ គឺមានច្បាប់ព្រហ្មទណ្ឌអន្តរកាល បង្កើតឡើងសម្រាប់ដាក់អនុវត្តក្នុងរយៈពេលខ្លី ដែលកម្ពុជាមិនទាន់បានចងក្រងក្រម ឬបង្កើតនូវប្រព័ន្ធច្បាប់ព្រហ្មទណ្ឌនៅឡើយ។ បទបញ្ញត្តិច្បាប់នេះត្រូវបានអនុវត្តរហូតដល់ក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ បានចូលជាធរមាន។ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា គឺត្រូវបានរៀបចំតាក់តែងឡើងដោយគោរពទៅតាមប្រពៃណី វិធាននៃច្បាប់ចាស់ និងឈរលើមូលដ្ឋានគ្រឹះរបស់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ធ្វើយ៉ាងណាឱ្យសមស្របទៅនឹងស្ថានភាព និងការវិវត្តរបស់បទល្មើសនាពេលបច្ចុប្បន្ន។ ដើម្បីធ្វើការស្វែងយល់អោយកាន់តែលំអិតទាក់ទងទៅនឹងសញ្ញាណទូទៅនៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩ យើងនឹងធ្វើការបែងចែកចែញជា ២ ផ្នែកគឺ៖ **១.១. ការកកើតនៃក្រមព្រហ្មទណ្ឌ ១.២. ទំនាក់ទំនងនៃក្រម។**

## ១.១. ការកកើតនៃក្រមព្រហ្មទណ្ឌ

### ១.១.១. ការកកើត

មុននឹងធ្វើការស្វែងយល់អោយកាន់តែច្បាស់ទាក់ទងនឹងការកកើតនៃក្រមព្រហ្មទណ្ឌ យើងនឹងលើកយកដំណើរវិវត្តន៍នៃប្រព័ន្ធកម្ពុជាមកស្វែងយល់ខ្លះៗផងដែរ។ ច្បាប់របស់កម្ពុជាបានឆ្លងកាត់ការប្រែប្រួលតាមសម័យកាលប្រវត្តិសាស្ត្រជាច្រើនបន្តបន្ទាប់គ្នាទម្រាំមានលក្ខណៈដូចសព្វថ្ងៃ។ វិធានច្បាប់សំខាន់អនុម័តដោយសភា។ ការចងក្រងវិធាននានាជាក្រម ឬអត្ថបទច្បាប់តែមួយ ចៅក្រមមានត្រឹមអំណាចបកស្រាយច្បាប់ជាជាងបង្កើតច្បាប់... (ច្បាប់ក្នុង"គ្រួសារស៊ីវិលឡ")។[1]

ដោយយកឆ្នាំ១៨៦៣ ដែលជាឆ្នាំនៃការចូលមកដល់ទឹកដីកម្ពុជារបស់បារាំង និងដែលសម្គាល់ការចាប់ផ្តើមនៃទំនើបភាវូបនីយកម្ម (Modernization) នៃប្រព័ន្ធច្បាប់កម្ពុជាតាមការរៀបចំរបស់បារាំងជាគោលនោះ យើងអាចបែងចែកសម័យកាលប្រវត្តិសាស្ត្រទាំងនោះជា ៣ ដំណាក់កាលធំៗ[2] ៖

ក. ដំណាក់កាលមុនឆ្នាំ១៨៦៣

---
[1] មេរៀនប្រព័ន្ធច្បាប់កម្ពុជា រៀបចំមេរៀន-បង្រៀនដោយ ថាន់ ច័ន្ទចំណាន។

[2] ដកស្រង់ពីគេហទំព័រ https://www.scribd.com (ថ្ងៃចូលមើលចុងក្រោយ ៨ សីហា ២០២៤)។

ខ. ដំណាក់កាលពីឆ្នាំ១៨៩៣ ដល់មុនឆ្នាំ១៩៩៣

គ. ដំណាក់កាលពីឆ្នាំ១៩៩៣ មកដល់សព្វថ្ងៃ។

**ក. ដំណាក់កាលមុនឆ្នាំ១៨៦៣**

- សម័យហ្វូណន/នគរភ្នំ (សតវត្សរ៍ទី១ – សតវត្សរ៍ទី៦)

ស្តេចចាត់ឲ្យមន្ត្រីរបស់ព្រះអង្គតាមមណ្ឌលនានានៃអាណាចក្រ ដើម្បីជំនុំជម្រះក្តីក្តាំរបស់ប្រជារាស្ត្រ។ គ្មានស្ថាប័នតុលាការប្រចាំការរួចជាស្រេចនៅតាមមណ្ឌលទាំងនោះឡើយ។ ស្តេចពេលខ្លះសម្រេចអារកាត់រឿងក្តីជូនប្រជាជនរបស់ព្រះអង្គ ដោយមិនមានច្បាប់ច្បាស់លាស់ណាមួយដែលចែងពីតួនាទី ឬកាតព្វកិច្ចរបស់ស្តេចក្នុងការចូលរួមដោះស្រាយរឿងក្តីជូនប្រជារាស្ត្ររបស់ព្រះអង្គឡើយ។ អន្តរាគមន៍របស់ព្រះអង្គគឺចំណុះនឹងព្រះរាជហឫទ័យរបស់ព្រះអង្គទាំងស្រុង។

- ទណ្ឌកម្មអនុវត្តលើជនប្រព្រឹត្តកំហុសមាន ២ ប្រភេទ៖

**ទណ្ឌកម្មស្រាល** ការបង់ប្រាក់សំណងជូនភាគីរងគ្រោះ ឬប្រាក់ពិន័យជូនរដ្ឋ។

**ទណ្ឌកម្មធ្ងន់** ការដាក់បង្ខាំងក្នុងទ្រុងជាមួយសត្វសាហាវ (ឧ. ខ្លា, ពស់...) រយៈពេល៣ថ្ងៃ ដើម្បីកំណត់ថាជននោះជាជនស្លូតត្រង់ ឬមានពិរុទ្ធភាពដូចការចោទប្រកាន់។ ក្នុងរយៈពេល៣ថ្ងៃនេះ បើសត្វអស់នោះមិនព្រមស៊ីទេគេចាត់ទុកថាគ្មានកំហុស ហើយដោះលែងឱ្យរួចខ្លួនវិញ។[3] គេប្រកាន់ជំនឿមុតមាំថា កាលបើគាត់ត្រូវសត្វទាំងនោះបង្ករបួស ឬសម្លាប់នោះ គាត់ពិតជាមានកំហុសមែន។ ផ្ទុយមកវិញ បើផុតរយៈពេលឃុំខ្លួននោះ ហើយគាត់មិនត្រូវបានសត្វរួមទ្រុងយាយីទេនោះវាសបញ្ជាក់ថា គាត់ជាមនុស្សល្អបរិសុទ្ធនឹងត្រូវបានដោះលែងភ្លាម។

- សម័យចេនឡា (សតវត្សរ៍ទី៦ – សតវត្សរ៍ទី៨)

ជារួមទិដ្ឋភាពច្បាប់ និងតុលាការ គឺមានលក្ខណៈដូចគ្នាសុទ្ធសាធទៅនឹងសម័យហ្វូណនដែរ។ ស្តេចត្រាស់បង្គាប់ឲ្យមន្ត្រីចុះតាមខេត្ត-ក្រុងដើម្បីរកយុត្តិធម៌ជូនប្រជាជន ស្តេចបើកសវនាការជម្រះក្តីជូនពលរដ្ឋតាមតែទឹកព្រះទ័យរបស់ព្រះអង្គ និងការអនុវត្តទណ្ឌកម្មស្រាល និងធ្ងន់ចំពោះជនល្មើស។

- សម័យអង្គរ (សតវត្សរ៍ទី៨ - សតវត្សរ៍ទី១៥)

ឧត្តមភាពនៃព្រះមហាក្សត្រ

[3] សៀវភៅប្រវត្តិស្ថាប័នខ្មែរ លោកសាស្ត្រាចារ្យ ពៅ សារឿន ឆ្នាំ២០១៥ ទំព័រ៤៤។

**ស្តេចជាអ្នកបង្កើតច្បាប់កំពូលគេ** ជាអ្នកជ្រើសរើសមន្ត្រីជាន់ខ្ពស់ ជាអគ្គបញ្ជាការកងទ័ព ជាអ្នកកាន់កាប់នយោបាយក្រៅប្រទេស។ ព្រះអង្គមានអំណាចលើដីធ្លីទាំងអស់ (ការលក់ ការប្តូរ ឬធ្វើអំណោយដីត្រូវតែមានសេចក្តីយល់ព្រមពីព្រះអង្គ)។[4] វិធានចេញពីស្តេចត្រូវផ្សព្វផ្សាយតាមរយៈមន្ត្រីព្រះបរមរាជវាំងដោយផ្ទាល់មាត់ជូនដល់ពលរដ្ឋ។ វិធានមួយចំនួនត្រូវបានសរសេរនៅលើជញ្ជាំងប្រាសាទ វិហារ ទីសក្ការៈបូជាបណ្ណាល័យ ហើយខ្លះទៀតចារឹកទុកលើបន្ទះលោហៈ ឬស្បែកសត្វ។

**ស្តេចជាចៅក្រមលំដាប់ខ្ពស់ជាងគេ** អន្តរាគមន៍របស់ព្រះរាជា គឺកើតឡើងតាមតែការសព្វព្រះទ័យរបស់ព្រះអង្គតែប៉ុណ្ណោះ។ ព្រះអង្គប្រតិបត្តិការងារកាត់សេចក្តីដោយអនុលោមតាមក្រមម៉ានូ (Manu) របស់ឥណ្ឌា (ច្បាប់ដែលកំណត់ពីព្រះពស្ត្រ ឥរិយាបថ និងវិធីសាស្ត្ររបស់ក្សត្រក្នុងអំឡុងសវនាការកាត់សេចក្តី)។[5] សេចក្តីសម្រេចរបស់ព្រះអង្គ គឺជាសេចក្តីចុងក្រោយ និងបិទផ្លូវតវ៉ា។ ការប្រើប្រាស់វិធីសាស្ត្រប្លែកៗមួយចំនួនក្នុងដំណើរការក្តីព្រហ្មទណ្ឌដូចជា អ្នករងគ្រោះ និងក្រុមគ្រួសាររបស់គាត់មានបន្ទុកស្វះស្វែងតាមចាប់ជនល្មើសដោយខ្លួនឯង ដើម្បីប្រគល់ឲ្យអាជ្ញាធររដ្ឋកាត់ទោសតាមក្រោយ មិនមែនជាការងាររបស់មន្ត្រីរដ្ឋឡើយ) និងការបញ្ច្រកស្រាឲ្យជនសង្ស័យស្រវឹង និងឆ្លើយសារភាព (ចម្លើយដែលទទួលបានពីជនសង្ស័យដែលកំពុងតែស្រវឹងបាត់បង់ម្ចាស់ការ គឺចាត់ទុកជាបានការដូចចម្លើយសារភាពក្នុងស្ថានភាពធម្មតាមិនស្រវឹងស្រាដែរ)។

នៅសម័យអង្គរស្ថាប័នតុលាការមានដំណើរការតាមបែបទំនៀមទម្លាប់ពីបុរាណកាល ពោលគឺតាមបែបអច្ឆរិយៈទាំងនីតិវិធីស្វែងរកជនប្រព្រឹត្តបទល្មើស និងទាំងនីតិវិធីនៃការដាក់ទណ្ឌកម្មដូចគ្នានឹងសម័យមុនៗដែរ ប៉ុន្តែមានចំណុចខ្លះខុសពីសម័យមុនផងដែរដូចជា[6]៖

- ពេលដែលព្រះរាជាបើកសវនាការជំនុំជម្រះក្តីម្តងៗ ត្រូវអមដោយមន្ត្រីយុត្តិធម៌ជានិច្ច។ មន្ត្រីយុត្តិធម៌នោះហៅថាយមរាជ ឬចៅក្រម (ចៅក្រមអាចជាស្ត្រី ឬជាបុរសផងដែរ) ។

- តាមរដ្ឋបាលភូមិភាគក៏មានការបើកសវនាការជំនុំជម្រះក្តីដែរ ដែលធ្វើឡើងដោយចៅហ្វាយខេត្ត ឬចៅហ្វាយស្រុកជំនួសឱ្យចៅក្រមពីព្រោះចៅហ្វាយខេត្ត ឬចៅហ្វាយស្រុកមានអំណាចទូលំទូលាយណាស់នៅសម័យនោះ។ គេមានសិទ្ធិសំរេចថាមានទោស ឬគ្មានទោស និងអាចដាក់ទណ្ឌកម្មគ្រប់កំរិតនៅវង្វង់ដែនដីរបស់ខ្លួន។

[4] សៀវភៅប្រវត្តិស្ថាប័នខ្មែរ លោកសាស្ត្រាចារ្យ ពៅ សារឿន ឆ្នាំ២០១៥ ទំព័រ៥៣។

[5] មេរៀនប្រព័ន្ធច្បាប់កម្ពុជា រៀបចំមេរៀន-បង្រៀនដោយ ថាន់ ច័ន្ទចំណាន។

[6] សៀវភៅប្រវត្តិស្ថាប័នខ្មែរ លោកសាស្ត្រាចារ្យ ពៅ សារឿន ឆ្នាំ២០១៥ ទំព័រ៥៦។

- ចំណែកមេឃុំ ឬមេភូមិអាចដោះស្រាយវិវាទក្នុងកំរិតចរចា ផ្សះផ្សារ ឬវិវាទកំរិតតូចតាចតែប៉ុណ្ណោះ មិនអាចដាក់ទណ្ឌកម្មបានឡើយ ។

ទណ្ឌកម្មមានច្រើនទម្រង់៖ បង់ប្រាក់ពិន័យ កាត់អវយវៈ (ដៃ ត្រចៀក ច្រមុះ...) កប់ទាំងរស់។

- សម័យក្រោយអង្គរ ( សតវត្សរ៍ទី១៥ ឆ្នាំ១៤៣១ – ១៨៦៣ )

ទោះជាប់រវល់ដោះស្រាយការងារជាច្រើនរបស់ប្រទេសជាតិ (ជាពិសេសទប់ទល់មហិច្ឆតាឈ្លានពាន របស់រដ្ឋជិតខាង) ក្សត្រខ្មែរមួយចំនួនបានតាក់តែងច្បាប់ជាច្រើនដែលមានទម្រង់ជាព្រះរាជក្រម ក្នុងនោះនៅ រាជ្ជកាលព្រះបាទជ័យជេដ្ឋាទី២ មានចំនួន២៤ក្រម រាជ្ជកាលព្រះសូរជ័តចេស្តា និងព្រះបាទអង្គឌួង មានចំនួន ២៨ក្រម ហើយក្រមទាំងនេះត្រូវសើរើឡើងវិញនៅរាជ្ជកាលព្រះបាទនរោត្តមក្នុងគ.ស១៨៨១[7]។ ព្រះអង្គបាន សង្ខាតចងក្រងវិធានរាយប៉ាយនានានៅក្នុងអាណាចក្ររបស់ព្រះអង្គដូចជាវិធានប្រពៃណី ទាក់ទងនឹងការ រៀបការ ការចែកកេរមរតក និងការជម្រះក្តីរបស់តុលាការ។ កម្រងវិធានទាំងនោះត្រូវបានគេហៅជាសាមញ្ញ ថាក្រមខ្មែរ (Khmer Kram ឬKhmer Code)។ នេះសបញ្ជាក់ឱ្យឃើញថាដំណើការប្រព្រឹត្តទៅនៃស្ថាប័ន តុលាការខ្មែរនៅក្រោយអង្គរមានលក្ខណៈប្រសើរជាងសម័យមុនៗ ព្រោះគេអនុវត្តន៍តាមព្រះរាជក្រមដែល បានកំណត់ពីបទល្មើសជាច្រើនដូចជា[8]៖ ក្រមរាជក្រឹត្យសង្គ្រី (ការបំពានលើទំនៀមទម្លាប់) ក្រមតុលាការ ក្រមអន្តាភាស (លក្ខន្តិកៈចៅក្រម) ក្រមព្រះធម្មនុញ្ញ (សមាសភាពតុលាការ) ក្រមព្រហ្មទណ្ឌ ក្រមពិធីការ ក្រមមរតក ក្រមស្រុក (ច្បាប់ធម្មនុញ្ញ) ក្រមតំណាងរឿងក្តី។ល។

**ខ. ដំណាក់កាលពីឆ្នាំ១៨៦៣ ដល់មុនឆ្នាំ១៩៩៣**

- សម័យអាណាព្យាបាល-អាណានិគមបារាំង (១៨៦៣-១៩៥៣)

ស្ថាប័នតុលាការត្រូវបានកំណត់ក្នុងសន្ធិសញ្ញាបារាំង-ខ្មែរឆ្នាំ១៨៦៣ និងកំណែទម្រង់ឆ្នាំ១៨៧៧។ ឥទ្ធិពលរបស់បារាំងមកលើការរៀបចំប្រព័ន្ធច្បាប់ទំនើបរបស់កម្ពុជា[9]៖

- ការលុបបំបាត់របបទាសភាព។

- ការបង្កើត និងទទួលស្គាល់របបកម្មសិទ្ធិឯកជនដីធ្លីជូនដល់ពលរដ្ឋទូទៅ។ ស្តេច និងញាតិវង្សរបស់ ព្រះអង្គមិនមែនជាម្ចាស់ដីផ្តាច់មុខនៅទូទាំងប្រទេសទៀតទេ។

[7] សេចក្តីផ្តើមនៃនីតិរបស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ទំព័រ១៣-១៤។

[8] សៀវភៅប្រវត្តិស្ថាប័នខ្មែរ លោកសាស្ត្រាចារ្យ ពៅ សារឿន ឆ្នាំ២០១៥ ទំព័រ៨០។

[9] មេរៀនប្រព័ន្ធច្បាប់កម្ពុជា រៀបចំមេរៀន-បង្រៀនដោយ ថាន់ ច័ន្ទចំណាន។

- ការចងក្រងវិធាននានាឲ្យមានលក្ខណៈជាវិធានសរសេរនៅក្នុងសៀវភៅ ឬឯកសារច្បាស់លាស់ (ជាពិសេស**ក្រមព្រហ្មទណ្ឌ និងក្រមរដ្ឋប្បវេណី**)។

**ក្រោមជំនួយរបស់បារាំង កម្ពុជាទទួលបានក្រមព្រហ្មទណ្ឌដំបូងបំផុតរបស់ខ្លួនក្នុងឆ្នាំ១៩១២ និង ក្រមរដ្ឋប្បវេណីដំបូងបំផុតរបស់ខ្លួនក្នុងឆ្នាំ១៩២០ នៅរជ្ជកាលព្រះបាទស៊ីសុវត្ថិ។**

- **ការព្រាងរដ្ឋធម្មនុញ្ញដំបូងបំផុត/ទី១របស់កម្ពុជា** ពោលរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ មាន ១០ជំពូក ១២១ មាត្រា ជារដ្ឋធម្មនុញ្ញបែបរាជានិយមអាស្រ័យធម្មនុញ្ញ។

- ការបណ្តុះបណ្តាលអ្នកច្បាប់កម្ពុជា តាមរូបភាពការបើកវគ្គសិក្សានៅកម្ពុជាផ្ទាល់ និងការផ្តល់អាហារូបករណ៍ដល់និស្សិតឆ្នើមរបស់កម្ពុជាឲ្យទៅសិក្សានៅប្រទេសបារាំងផ្ទាល់តែម្តង។

- ការរៀបចំរចនាសម្ព័ន្ធតុលាការ ការបែងចែកជាតុលាការជាន់ទាប និងតុលាការជាន់ខ្ពស់ និងការកំណត់យុត្តាធិការជំនាញរបស់តុលាការ (**យុត្តាធិការព្រហ្មទណ្ឌ យុត្តាធិការរដ្ឋប្បវេណី** ...)។

- សម័យសង្គមរាស្ត្រនិយម (១៩៥៣-១៩៧០)

ប្រព័ន្ធយុត្តាធិការនៃព្រះរាជាណាចក្រកម្ពុជានាសម័យនោះបានបន្តអនុវត្តប្រព័ន្ធនេះតាមលំនាំបែបបារាំងដែលបន្សល់ទុកតាំងពីសម័យអាណានិគមនិយមមកម្ល៉េះ។

- ការធ្វើបច្ចុប្បន្នភាពក្រមព្រហ្មទណ្ឌ និងក្រមរដ្ឋប្បវេណី ដែលបន្សល់ទុកពីសម័យមុន (សម័យបារាំងគ្រប់គ្រង) និងការបង្កើតច្បាប់ថ្មីៗដទៃទៀត (**ឧទាហរណ៍**. ច្បាប់ពាណិជ្ជកម្ម ឬអ្នកខ្លះហៅថា ក្រមពាណិជ្ជកម្មនាពេលនោះ) ។

- ការបន្តជំនួយគាំទ្រផ្នែកច្បាប់របស់បារាំង គំនិតទស្សនៈច្បាប់បារាំងនៅតែមានឥទ្ធិពលខ្លាំងក្លាមកលើវិធីសាស្ត្រស្រាវជ្រាវច្បាប់ និង**នីតិកម្ម** (ការធ្វើច្បាប់) របស់កម្ពុជា។ បារាំងសហការបញ្ជូននិស្សិត និងមន្ត្រីច្បាប់ពូកែៗរបស់កម្ពុជាឲ្យទៅសិក្សានៅទឹកដីខ្លួន។

- ការបង្កើតគ្រឹះស្ថានឧត្តមសិក្សាច្បាប់ដំបូងគេរបស់កម្ពុជា គឺ**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ** នៅឆ្នាំ១៩៥៧ សព្វថ្ងៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឬហៅកាត់តាមភាសាអង់គ្លេស RULE(S)។

- សម័យសាធារណរដ្ឋខ្មែរ (១៩៧០-១៩៧៥)

**រដ្ឋធម្មនុញ្ញទី២** របស់កម្ពុជាដែលកំណត់ថាប្រទេសត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធានាធិបតីជាប្រមុខរដ្ឋនោះត្រូវបានអនុម័តនៅថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៧២ (រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២)។[10] រដ្ឋធម្មនុញ្ញនេះ

[10] មេរៀនប្រព័ន្ធច្បាប់កម្ពុជា រៀបចំមេរៀន-បង្រៀនដោយ ថាន់ ច័ន្ទចំណាន។

មាន១១ជំពូក ១២១មាត្រា។ ការលេចឡើងនូវប្បធម៌នៃការពិភាក្សាគ្នាយ៉ាងផុសផុលក្នុងចំណោមអ្នកជំនាញច្បាប់ និងអ្នកចាប់អារម្មណ៍នឹងបញ្ហាច្បាប់តាមទំព័រកាសែត ក៏ដូចជានៅតាមវេទិកាសាធារណៈនានា។

- សម័យកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

ខ្មែរក្រហមបានបោះបង់ចោលក្រមច្បាប់នានា ក៏ដូចជាប្រព័ន្ធតុលាការដែលបន្សល់ទុកពីរបបមុនៗ ដោយសំអាងថាវាជាឧបករណ៍ដែលក្រុមអ្នកមាន និងវណ្ណៈជិះជាន់ប្រើប្រាស់ដើម្បីកេងប្រវ័ញ្ច និងសង្កត់សង្កិនមកលើពលរដ្ឋក្រីក្រ។ ពួកគេក៏បានសម្លាប់ ធ្វើទារុណកម្ម និងធ្វើទុក្ខបុកម្នេញមកលើចៅក្រម មន្ត្រីតុលាការ និងមន្ត្រីអនុវត្តច្បាប់នៃរបបមុនផងដែរ។ ក្រុមមេដឹកនាំខ្មែរក្រហម (ដែលរួមសំបាច់គ្នាក្នុងរូបភាពជា**អង្គការ**នោះ) បានបង្កើតរដ្ឋធម្មនុញ្ញថ្មីមួយទៀតដែលមាន២១មាត្រា (ចែកចេញដល់ទៅ១៦ជំពូក) សម្រាប់របបគ្រប់គ្រងរបស់ខ្លួន ពោលរដ្ឋធម្មនុញ្ញឆ្នាំ១៩៧៦ (**រដ្ឋធម្មនុញ្ញទី៣** របស់កម្ពុជា) ដែលត្រូវបានអនុម័តដោយសមាជិកមួយពាន់នាក់ក្នុងមហាសន្និបាតជាតិថ្ងៃទី១៥-១៩ ខែធ្នូ ឆ្នាំ១៩៧៥។[11]

- សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា-រដ្ឋកម្ពុជា (១៩៧៩-១៩៩៣)

នៅខែមិថុនា ឆ្នាំ១៩៨១ រដ្ឋអំណាចនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាបានអនុម័ត និងដាក់ប្រើប្រាស់នូវ**រដ្ឋធម្មនុញ្ញទី៤** របស់កម្ពុជា (រដ្ឋធម្មនុញ្ញឆ្នាំ១៩៨១) ដើម្បីបញ្ជាក់ពីអត្ថិភាពជាផ្លូវការនៃរបបនយោបាយរបស់ខ្លួន។ រដ្ឋធម្មនុញ្ញនេះមាន១០ជំពូក ៩៣មាត្រា។

ជាក់ស្តែងចាប់ពីឆ្នាំ១៩៧៩-១៩៨៥ មានសាលាជំនុំជម្រះតែមួយគត់ ដែលមានឈ្មោះថា "**តុលាការប្រជាជន**"[12]។ នៅឆ្នាំ១៩៨១ តុលាការយោធាត្រូវបានបង្កើតឡើង[13]។

នាខែមេសា ឆ្នាំ១៩៨៩ រដ្ឋធម្មនុញ្ញថ្មីមួយទៀតបានចូលខ្លួនមកជំនួសរដ្ឋធម្មនុញ្ញឆ្នាំ១៩៨១។ តាមរយៈ**រដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩ ឬរដ្ឋធម្មនុញ្ញទី៥** របស់កម្ពុជាមានឈ្មោះថ្មីមួយថា **រដ្ឋកម្ពុជា** មាន១០ជំពូក ៩៣មាត្រា។ រដ្ឋធម្មនុញ្ញនេះត្រូវបានរដ្ឋសភានៃសាធារណរដ្ឋប្រជាមានិតកម្ពុជាអនុម័តជាឯកច្ឆ័ននៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៩ នាសម័យប្រជុំសាមញ្ញនៃនីតិកាលទី១។[14] ជាមួយគ្នានេះដែរ អាជ្ញាធរនៃរបបថ្មីបានបើកឲ្យពលរដ្ឋកម្ពុជាមានសិទ្ធិកម្មសិទ្ធិឯកជនសាជាថ្មីលើដីធ្លី (ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨៩ ពួកគាត់ទទួលបានតែកម្មសិទ្ធិសមូហភាពតែប៉ុណ្ណោះ)។

[11] សៀវភៅប្រវត្តិស្ថាប័នខ្មែរ លោកសាស្ត្រាចារ្យ ពៅ សារឿន ឆ្នាំ២០១៥ ទំព័រ១៦៧។

[12] ក្រឹត្យលេខ ១២ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៨២។

[13] ក្រឹត្យ-ច្បាប់លេខ ០៥ ស្តីពីការចាត់តាំងតុលាការយោធា ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៨១។

[14] មាត្រា៩៣ កថាខណ្ឌទី២ រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា ឆ្នាំ១៩៨៩។

ច្បាប់សំខាន់ៗដែលត្រូវបានបង្កើតឡើងក្នុងសម័យកាល ១៩៧៩-១៩៩៣ រួមមាន៖ ច្បាប់ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា(១៩៨៨) ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ(១៩៨៩) ច្បាប់ភូមិបាល(១៩៩២) និងច្បាប់ព្រហ្មទណ្ឌអន្តរកាល ឬច្បាប់អ៊ុនតាក់(១៩៩២)។

**គ. ដំណាក់កាលពីឆ្នាំ១៩៩៣ មកដល់បច្ចុប្បន្ន**

ក្រោយការបោះឆ្នោតនាខែឧសភា ឆ្នាំ១៩៩៣ រដ្ឋធម្មនុញ្ញចុងក្រោយបំផុតរបស់កម្ពុជា ពោល **រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ឬរដ្ឋធម្មនុញ្ញទី៦** របស់កម្ពុជាត្រូវបានអនុម័ត និងដាក់ឲ្យប្រើប្រាស់ (ឲ្យច្បាស់ចាប់ពីខែកញ្ញា ឆ្នាំ១៩៩៣)។ ច្បាប់កំពូលបច្ចុប្បន្នរបស់កម្ពុជានេះទទួលស្គាល់សាជាថ្មីនូវរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ និងគោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស និងសេដ្ឋកិច្ចទីផ្សារសេរី (ផ្លាស់ចេញពីរបបសាធារណរដ្ឋ សង្គមនិយម ឯកបក្សនិយម និងសេដ្ឋកិច្ចផែនការ)។[15]

ច្បាប់ជាច្រើនត្រូវបានបង្កើតឡើងជាហូរហែ ដើម្បីឆ្លើយតបនឹងតម្រូវការដែលកាន់តែកើនឡើងរបស់ប្រទេសជាតិ និងប្រជាជន (ជាពិសេសចាប់តាំងពីដើមសតវត្សរ៍ទី២១នេះ)៖ ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល ច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី ច្បាប់ស្តីពីអស្សាមិករណ៍ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក...។

ច្បាប់ដែលបន្សល់ទុកពីសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជាមួយចំនួននៅបន្តប្រើប្រាស់ ហើយទើបនឹងអស់សុពលភាព ឬត្រូវបាននិរាករណ៍នាពេលប៉ុន្មានឆ្នាំចុងក្រោយនេះតែប៉ុណ្ណោះ (**ឧទាហរណ៍.** ច្បាប់ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា និងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារបន្តប្រើជាធម្មតារហូតដល់ចុងឆ្នាំ២០១១ ទម្រាំក្រមរដ្ឋប្បវេណីបច្ចុប្បន្នចាប់ផ្តើមអនុវត្តជាផ្លូវការតាំងពីពេលនោះមក) **ច្បាប់ព្រហ្មទណ្ឌអន្តរកាល** នៅមានសុពលភាពប្រើប្រាស់រហូតដល់ចុងឆ្នាំ២០១០ (រហូតដល់កាលវេលានៃការចាប់ផ្តើមប្រើប្រាស់ជាផ្លូវការនៃក្រមព្រហ្មទណ្ឌបច្ចុប្បន្ន) ច្បាប់ភូមិបាលឆ្នាំ១៩៩២ ត្រូវបានប្រើប្រាស់រហូតដល់ចុងខែសីហា ឆ្នាំ២០០១ (គិតដល់ពេលដែលច្បាប់ភូមិបាលថ្មី ពោលច្បាប់ភូមិបាលឆ្នាំ២០០១ ចូលខ្លួនមកជំនួស)។

រដ្ឋបរទេសជាមិត្តមួយចំនួនបានជួយកម្ពុជាក្នុងកិច្ចការកសាងច្បាប់ និងអនុវត្តច្បាប់៖

- ជប៉ុន៖ តាមរយៈចៃកា (JICA) ជួយតាក់តែង និងផ្សព្វផ្សាយក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី។

[15] មេរៀនប្រព័ន្ធច្បាប់កម្ពុជា រៀបចំមេរៀន-បង្រៀនដោយ ថាន់ ច័ន្ទចំណាន។

- បារាំងជួយតាក់តែង និងផ្សព្វផ្សាយក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ។

- អាល្លឺម៉ង់ជួយដំណើរគម្រោងផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីដល់ពលរដ្ឋ ស្របតាមបទបញ្ញត្តិនៃច្បាប់ភូមិបាល។

- ស៊ុយអែតសហការផ្នែកបច្ចេកទេស ដើម្បីកែលម្អក្របខ័ណ្ឌច្បាប់ពន្ធដា។

- សហរដ្ឋអាមេរិកជួយពង្រឹងសមត្ថភាពតស៊ូមតិផ្នែកច្បាប់ទូទៅដល់យុវជនកម្ពុជា។

គិតមកដល់ត្រឹមដើមខែមេសា ឆ្នាំ២០២០ រដ្ឋាភិបាលកម្ពុជារៀបចំព្រាងច្បាប់ដទៃទៀត ដើម្បីបម្រើប្រយោជន៍សង្គម និងពលរដ្ឋ (ដោយស្របតាមស្មារតីនៃកំណែទម្រង់ច្បាប់ ប្រព័ន្ធយុត្តិធម៌ដែលត្រូវបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់ខ្លួនចាប់តាំងពីឆ្នាំ២០០៤មក) : ច្បាប់ស្តីឧក្រិដ្ឋកម្ម តាមបណ្តាញព័ត៌មាន ឬអ៊ីនធ័រនែត និងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន...។

តុលាការ ឬសាលាជម្រះក្តីត្រូវបានរៀបចំជាជាន់ ឬថ្នាក់ និងតាមមូលដ្ឋានក្នុងសភាពមួយដែលច្បាស់លាស់ជាងមុន។ បច្ចុប្បន្នតុលាការមាន២ជាន់ គឺតុលាការជាន់ទាប (សាលាដំបូង២៥ រាជធានី-ខេត្ត) តុលាការយោធា (១) និងតុលាការជាន់ខ្ពស់ (សាលាឧទ្ធរណ៍៤ + តុលាការកំពូល១)។

មុនថ្ងៃទី១ ខែមេសា ឆ្នាំ២០២០ កម្ពុជាមានសាលាឧទ្ធរណ៍តែមួយគត់ដែលស្ថិតក្នុងរាជធានីភ្នំពេញ ដើម្បីចាត់ការរឿងក្តីទូទាំងប្រទេស។ ប៉ុន្តែចាប់តាំងពីកាលបរិច្ឆេទនោះមក សាលាឧទ្ធរណ៍បីទៀតត្រូវបានដាក់ឲ្យដំណើរការដើម្បីរំលែកការងារគ្នា (សាលាឧទ្ធរណ៍ត្បូងឃ្មុំ សាលាឧទ្ធរណ៍បាត់ដំបង និងសាលាឧទ្ធរណ៍ព្រះសីហនុ)។ គម្រោងអនាគតបង្កើតតុលាការជំនាញ (**ឧទាហរណ៍**. តុលាការការងារ តុលាការរដ្ឋបាល តុលាការពាណិជ្ជកម្ម តុលាការសម្រាប់អនីតិជន...)។

ការបង្កើតសាលាបណ្តុះបណ្តាលអ្នកប្រកបវិជ្ជាជីវៈច្បាប់ និងតុលាការ : ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី អាជ្ញាសាលា សារការី មេធាវី...។

បន្ទាប់ពីបានសិក្សាស្វែងយល់ខ្លះៗ អំពីដំណើរវិវត្តន៍នៃប្រព័ន្ធច្បាប់កម្ពុជារួចមកហើយ យើងនឹងធ្វើការសិក្សាស្វែងយល់បន្ថែមទៅលើការកកើតនៃក្រមព្រហ្មទណ្ឌ។

នីតិព្រហ្មទណ្ឌត្រូវបានគេយកមកអនុវត្តតាំងពីយូរយារណាស់មកហើយនៅក្នុងប្រទេសកម្ពុជា។ មានភស្តុតាងជាច្រើនដែលបានបញ្ជាក់ពីអត្ថិភាពនៃច្បាប់ព្រហ្មទណ្ឌកម្ពុជាក្នុងអតីតកាល។ ជាក់ស្តែងក្រមព្រហ្មទណ្ឌកម្ពុជា ត្រូវបានចងក្រងឡើងពីច្បាប់នានារបស់សង្គមខ្មែរមុនពេលដែលប្រទេសបារាំងមកដាក់អាណានិគមនៅឆ្នាំ១៨៦៣ ។ លោក អាដេម៉ា ឡឺក្លែរ (Adhémard Leclère) បានចងកងកម្រងច្បាប់ទាំងនេះជាពីរភាគ ហើយត្រូវបានបោះពុម្ពផ្សាយនៅឆ្នាំ១៨៩៨។

តាមលោក អាដេម៉ា ឡឺក្លែរ ទោសដែលអ្នកនីតិបញ្ញត្តិខ្មែរបានចែងទុករួមមាន[16]៖

**ក. ទោសប្រហារជីវិត**

គេសង្កេតឃើញមានទោសប្រហារជីវិតដោយសន្សឹមៗចំនួន ២១ ប្រភេទដូចជា៖

១. អ្នកប្រហារជីវិតត្រូវធ្វើឲ្យទណ្ឌិតមានរបួសយ៉ាងធ្ងន់ជាមុន បណ្ដាលអោយឈាមហូរចេញមកពីក្បាល ហើយយកទណ្ឌិតទៅដាក់លើបន្ទះដែកដុតឡើងក្រហម បន្ទាប់មកទៀតទុកឲ្យទណ្ឌិតនៅលើបន្ទះដែកនោះ រហូតដល់ឆេះអស់សាច់ឈាមនៅសល់តែឆ្អឹងប៉ុណ្ណោះ។

២. អ្នកប្រហារជីវិតត្រូវពន្លាត់ស្បែកក្បាលរបស់ទណ្ឌិត ដើម្បីឲ្យស្បែកក្បាលនោះធ្លាក់គ្របមុខឲ្យជិត។

៣. អ្នកប្រហារជីវិតត្រូវចាក់ប្រេងទៅក្នុងមាត់របស់ទណ្ឌិត រួចទុកឲ្យមាត់នៅបើកចំហដោយដាក់ដំបងមួយជាចន្ទល់ បន្ទាប់មកទើបយកភ្លើងមកដុតមាត់របស់ទណ្ឌិតឲ្យឆេះសន្ធោសន្ធៅឡើង។

៤. អ្នកប្រហារជីវិតត្រូវពុះមាត់ទណ្ឌិតឲ្យរយះចេញជាពីរទាំងសងខាងរហូតដល់ទៅត្រចៀក រួចហើយទុកឲ្យចំហចោលរហូតដល់ទណ្ឌិតនោះស្លាប់បាត់បង់ជីវិត។

៥. អ្នកប្រហារជីវិតត្រូវចងម្រាមដៃទាំងដប់របស់ទណ្ឌិតនឹងក្រណាត់ដែលជ្រលក់ប្រេងឲ្យជោគ បន្ទាប់មកដុតទណ្ឌិតឲ្យឆេះស្លាប់បាត់បង់ជីវិតតែម្តង។

៦. អ្នកប្រហារជីវិតវះឆូតសាច់ទណ្ឌិតចាប់តាំងពីដើមករហូតមកដល់ភ្នែកគោល បន្ទាប់មកក៏វាយដំអ្នកទោសរហូតដល់ស្លាប់បាត់បង់ជីវិត។

៧. អ្នកប្រហារជីវិតត្រូវពន្លាត់ស្បែកអ្នកទោសពីដើមករហូតមកដល់ចង្កេះ រួចហើយក៏យកស្បែកដែលពន្លាត់បាននោះ មកគ្របផ្នែកខាងក្រោមរបស់ទណ្ឌិត។

៨. អ្នកប្រហារជីវិតត្រូវយកច្បូកដែកមកចាក់លើខ្លួនរបស់ទណ្ឌិតឲ្យផ្ទប់ទៅនឹងដីជាប់ ដើម្បីកុំឲ្យអ្នកទោសរើខ្លួនរួច បន្ទាប់មកយកភ្លើងមកដុតអ្នកទោសនោះឲ្យឆេះរហូតដល់ស្លាប់បាត់បង់ជីវិត។

៩. អ្នកប្រហារជីវិតត្រូវយកកាំបិតតាំងតោពន្លះយកសាច់ទណ្ឌិតបន្តិចម្តងៗឲ្យមានដំបៅជាច្រើនកន្លែងរហូតទាល់តែអ្នកទោសស្លាប់បាត់បង់ជីវិត។ល។

**ខ. ការកាត់ដៃកាត់ជើង**

[16] សៀវភៅរបស់លោក អាដេម៉ា ឡឺក្លែរ ការស្រាវជ្រាវច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីរបស់កម្ពុជា ឆ្នាំ១៨៩៤ (Recherches sur la legislation criminelle et la procedure des cambodgiens) ។

**គ. ការដាក់គុកច្រវាក់**

**ឃ. ការដាក់ជាទាសភាព**

**ង. ការរឹបអូសទ្រព្យសម្បត្តិ**

**ច. ការដាក់ម៉ាកលើថ្ងាស់**

**ឆ. ការអាក្រាតជាសាធារណៈ**

**ជ. ទោសលើរូបកាយ**

**ឈ. ទោសជាប់ឃ្នាង**

**ញ. ទោសបន្ថយស័ក្តិ**

**ដ. ការពិន័យ**

**ឋ. ទោសបង់តម្លៃជីវិតមនុស្ស**

**ឱ. ទោសផ្សេងៗទៀត** ដូចជាការបណ្តេញគ្រួសារអ្នកទោសចេញជាដើម។

នៅពេលដែលប្រទេសបារាំងបានដាក់អាណានិគមមកលើប្រទេសកម្ពុជា គេបានបង្កើតបន្ថែមនូវទោសមួយទៀតគឺ**ការបំបរបង់**។ ក្រោយមក**អាណានិគមបារាំងបានរៀបចំតាក់តែងក្រមព្រហ្មទណ្ឌមួយនៅឆ្នាំ១៩២៤** ដែលយកលំនាំតាមក្រមព្រហ្មទណ្ឌរបស់ប្រទេសបារាំងនៅខណៈនោះ។ យោងតាមអត្ថន័យនៃក្រមព្រហ្មទណ្ឌនេះទោសសម្លាប់ជីវិតបង់ ឬទោសប្រហារជីវិតត្រូវធ្វើឡើងតាមរយៈការពិឃាដកាត់ក្បាល ហើយមុននឹងការពិឃាដនេះ អ្នកទោសនឹងត្រូវដង្ហែទៅដល់កន្លែងដំឡើងយន្តពិឃាដ[17]។ ក្រមព្រហ្មទណ្ឌខ្មែរត្រូវបានកែប្រែជាបន្តបន្ទាប់ព្រមទាំងត្រូវបានយកមកប្រើប្រាស់នៅក្នុងសម័យសង្គមរាស្ត្រនិយម ដោយធ្វើការកែប្រែអនុម័តជាថ្មីក្នុងឆ្នាំ១៩៥៩។ ក្រមព្រហ្មទណ្ឌខាងលើនៅតែមានអានុភាពបន្តអនុវត្តរហូតដល់ឆ្នាំ១៩៧៥។ បន្ទាប់ពីរបបប្រល័យពូជសាសន៍បានរលំរលាយទៅ ក្រមព្រហ្មទណ្ឌចាស់ពុំត្រូវបានយកមកបន្តអនុវត្តទៀតទេ ក៏ប៉ុន្តែត្រូវបានចាត់ទុកដូចជាទំនៀមទម្លាប់ ឬជាគោលការណ៍ច្បាប់ដែលចៅក្រមត្រូវគោរពផងដែរ[18]។ បន្ថែមពីលើនេះទៀតគេសង្កេតឃើញមាន**ច្បាប់ ក្រឹត្យច្បាប់ ក្រឹត្យ និងសារាចរ**ដទៃទៀតដែលត្រូវបាន

[17] មាត្រា ២៤ និងមាត្រា ២៥ នៃក្រមព្រហ្មទណ្ឌខេមរៈ ដែលត្រូវបានដាក់ឲ្យប្រើតាមព្រះរាជប្រកាស ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ១៩២៤ និងមានព្រះរាជប្រកាសចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩២៩ កែប្រែ។

[18] ទាក់ទងនឹងការអនុវត្តក្រមព្រហ្មទណ្ឌចាស់នាពេលបច្ចុប្បន្ន មានការបកស្រាយខុសប្លែកពីគ្នាទៅលើមាត្រា ១៥៨ថ្មី នៃរដ្ឋធម្មនុញ្ញ ដែលចែងថា៖ ច្បាប់ និងលិខិតបទដ្ឋានទាំងអស់នៅកម្ពុជាដែលធានាការពារបាននូវទ្រព្យសម្បត្តិរដ្ឋ សិទ្ធិសេរីភាព និងទ្រព្យសម្បត្តិត្រឹមត្រូវតាមច្បាប់របស់បុគ្គល និងដែលសមស្របនឹងប្រយោជន៍ជាតិ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀតរហូត ដល់មានអត្ថបទថ្មីមក

សម្រេចយកមកអនុវត្តក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា។ បទដ្ឋានដែលបានអនុម័តរួចមានជាច្រើនដែលយើងពុំអាចរៀបរាប់ឲ្យអស់បាននៅក្នុងក្របខ័ណ្ឌនៃសៀវភៅសិក្សានេះ។ ក្នុងវិស័យតុលាការព្រហ្មទណ្ឌ គេសង្កេតឃើញមានក្រឹត្យច្បាប់លេខ ០១ ក្រ.ច ស្តីពីការកំណត់អង្គការចាត់តាំងតុលាការប្រជាជនបដិវត្តខេត្តក្រុង ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៨០ ច្បាប់ស្តីពីការបង្កើតតុលាការប្រជាជនកំពូល និងមហាអយ្យការអមតុលាការប្រជាជនកំពូល ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៨៥ មូលដ្ឋានច្បាប់ក្នុងវិស័យព្រហ្មទណ្ឌមានដូចជា ក្រឹត្យច្បាប់លេខ ០២ ក្រ.ច ស្តីពីការផ្តន្ទាទោសក្បត់បដិវត្ត និងបណ្តាទោសប្រព្រឹត្តបទល្មើសផ្សេងៗទៀត ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៨០ ក្រឹត្យច្បាប់ស្តីពីការបង្ក្រាបការក្លែងរូបិយវត្ថុ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៨៥ ក្រឹត្យច្បាប់ស្តីពីរបបជីវភាពនៃទណ្ឌិត និងជនឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៨៥ ក្រឹត្យច្បាប់ស្តីពីការចាប់ខ្លួន ឃាត់ខ្លួន ឃុំខ្លួនជាបណ្តោះអាសន្ន ការដោះលែង ការឆែកឆេរលំនៅដ្ឋាន សម្ភារះវត្ថុ និងលើខ្លួនបុគ្គល ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៨៦ ក្រឹត្យលេខ ០១ ក្រ ស្តីពីការពិនិត្យអនុគ្រោះទោស ឬលើកលែងទោសចំពោះបណ្តាពិរុទ្ធជន ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៨៤ អនុក្រឹត្យស្តីពីរបៀបរៀបរយសាធារណៈនៅរដ្ឋធានីភ្នំពេញ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៨១ អនុក្រឹត្យស្តីពីចរាចរណ៍ផ្លូវគោក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៨៤ ក្រឹត្យច្បាប់លេខ ០៤ ក្រ.ច ស្តីពីបទល្មើសមានលក្ខណៈយោធា និងទណ្ឌកម្ម ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៨១ ក្រឹត្យលេខ ២៨ ក្រ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៨៨ ស្តីពីការលើកលែងទោស និងការបន្ធូរបន្ថយទោសឲ្យទណ្ឌិត។ល។

លុះដល់ឆ្នាំ១៩៩២ ក្រុមប្រឹក្សាជាតិជាន់ខ្ពស់បានអនុម័តបទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាលហៅកាត់ថា **ច្បាប់ព្រហ្មទណ្ឌអន្តរកាល** សម្រាប់អនុវត្តក្នុងរយៈពេលអន្តរកាលលុះត្រាមានច្បាប់ថ្មីមកជំនួសក្រោយពេលបង្កើតរដ្ឋសភារួចហើយ។ តាមការពិតទៅច្បាប់ព្រហ្មទណ្ឌអន្តរកាលនៅតែមានអានុភាពអនុវត្តរហូតដល់បទបញ្ញត្តិទាំងអស់នៃក្រមព្រហ្មទណ្ឌថ្មីត្រូវតែយកមកអនុវត្ត។ មុនពេលមានការអនុវត្តក្រមព្រហ្មទណ្ឌថ្មី បទប្បញ្ញត្តិមួយចំនួននៃច្បាប់ព្រហ្មទណ្ឌអន្តរកាលត្រូវបាននិរាករណ៍ ដោយច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋដែលត្រូវបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០១០២/០០៤ ចុះថ្ងៃទី០៧ ខែមករា ឆ្នាំ២០០២ ក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៨០៧/០២ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

កែប្រែឬលុបចោល លើកលែងតែបទបញ្ញត្តិណាដែលផ្ទុយនឹងស្មារតីនៃរដ្ឋធម្មនុញ្ញនេះ។ សៀវភៅ "សេចក្តីផ្តើមនៃនីតិកម្ពុជា" បោះពុម្ពនៅឆ្នាំ ២០០៣ រៀបរៀងដោយ ក. បេអាទ្រិស បាលិវ៉េថាំង ស៊ីណា ត្រង់អត្ថបទលេខ ២៥១-២៥២ ទំព័រទី ១៦២-១៦៣ ។

នៅប្រទេសកម្ពុជានីតិកម្ម (Legislation) ឬដំណើរការបង្កើតច្បាប់ (Lawmaking process) មាន ៣ ដំណាក់កាលសំខាន់[19]៖

**១.១.១.១. ការរៀបចំតាក់តែង**

នៅព្រះរាជាណាចក្រកម្ពុជាមានស្ថាប័នចំនួន ៣ ដែលអាចផ្តួចផ្តើមដំណើរការបង្កើតច្បាប់បាន រួមមាន៖ **១. នាយករដ្ឋមន្ត្រី ២. សមាជិកសភា(តំណាងរាស្ត្រ) ៣. សមាជិកព្រឹទ្ធសភា**[20]។ ច្បាប់ដែលត្រូវបានបង្កើតភាគច្រើនគឺមកពីនាយករដ្ឋមន្ត្រី។[21] ទោះបីជានាយករដ្ឋមន្ត្រីត្រូវបានបញ្ញត្តក្នុងរដ្ឋធម្មនុញ្ញខាងលើចុចឈ្មោះជាឥស្សរជនម្នាក់ដែលអាចផ្តួចផ្តើមធ្វើច្បាប់ក៏ដោយក៏នេះមិនមែនមានន័យថា គាត់ជាអ្នកតាក់ ឬសរសេរដោយផ្ទាល់ដែរ។ អាស្រ័យដោយមានការមមាញឹកនឹងភារកិច្ចដឹកនាំប្រទេសជាច្រើន ក៏ដូចជាការទាមទារឲ្យមានចំណេះដឹងផ្នែកច្បាប់មាំទាំ គាត់ផ្ទេរភារៈនេះទៅឲ្យមន្ត្រីក្រោមឱវាទរបស់គាត់ដែលមានចំណេះដឹងបែបនេះដូចជារដ្ឋមន្ត្រី ឬមន្ត្រីជំនាញតាមស្ថាប័នរណបនឹងរដ្ឋាភិបាលវិញ។

**ក្រមព្រហ្មទណ្ឌ** គឺជាបណ្តុំរាល់បទប្បញ្ញត្តិព្រហ្មទណ្ឌទាំងឡាយ ក្នុងនោះបទប្បញ្ញត្តិមួយផ្នែកចែងអំពីគោលការណ៍គ្រឹះ និងវិធានរួមនៅក្នុងនីតិព្រហ្មទណ្ឌសម្រាប់ចៅក្រមយកទៅអនុវត្តក្នុងការផ្តល់យុត្តិធម៌ក្នុងរឿងព្រហ្មទណ្ឌ និងបទប្បញ្ញត្តិមួយផ្នែកទៀតចែងអំពីបទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោស។ តាមរយៈនេះក្រមព្រហ្មទណ្ឌមានចរិត និងគោលដៅចម្បងបម្រើឱ្យប្រយោជន៍សាធារណៈ ធានារក្សាការពារសណ្តាប់ធ្នាប់សាធារណៈ សន្តិសុខសង្គម សិទ្ធិសេរីភាពបុគ្គល សេចក្តីថ្លៃថ្នូរ និងភាពសុខសាន្តជូនប្រជាជន។

ដោយមើលឃើញពីសារៈសំខាន់នៃក្រមព្រហ្មទណ្ឌ និងដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការចាំបាច់ចំពោះមុខក្នុងការប្រយុទ្ធប្រឆាំងទម្រង់ថ្មីនៃបទល្មើស ព្រមទាំងឧក្រិដ្ឋកម្មសម័យទំនើបផ្សេងៗ ប្រកបដោយប្រសិទ្ធភាព និងមានលក្ខណៈគ្រប់ជ្រុងជ្រោយក្នុងគោលដៅធានាការពារឱ្យបាននូវសិទ្ធិសេរីភាព សេចក្តីថ្លៃថ្នូរ សន្តិសុខសង្គម និងសណ្តាប់ធ្នាប់សាធារណៈជូនប្រជាជនទើបរាជរដ្ឋាភិបាលបានផ្តោតការយកចិត្តទុកដាក់ខ្ពស់លើកិច្ចការនេះ និងបានចាត់ទុកការជម្រុញអនុម័តក្រមព្រហ្មទណ្ឌ គឺជារបៀបវារៈអាទិភាពមួយនៃកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌របស់ខ្លួន។

រាជរដ្ឋាភិបាលតាមរយៈក្រសួងយុត្តិធម៌ក៏បានស្នើសុំឱ្យមានកិច្ចសហប្រតិបត្តិការពីរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង ដើម្បីរៀបចំតាក់តែងសេចក្តីព្រាងច្បាប់ស្តីពី "ក្រមព្រហ្មទណ្ឌ" នេះឡើង។ នៅក្នុងឆ្នាំ២០០១

[19] ដកស្រង់ពីគេហទំព័រ https://www.scribd.com (ថ្ងៃចូលមើលចុងក្រោយ ៨ សីហា ២០២៤)។

[20] មាត្រា ៩១ កថាខណ្ឌទី១ ថ្មីនៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣។

[21] ដកស្រង់ពីគេហទំព័រ https://opendevelopmentcambodia.net (ថ្ងៃចូលមើលចុងក្រោយ ៨ សីហា ២០២៤)។

**សេចក្តីព្រាងក្រមព្រហ្មទណ្ឌដើមដំបូង** ជាភាសាខ្មែរត្រូវបានរៀបចំឡើង និងបានប្រគល់ដល់ក្រសួងយុត្តិធម៌ ដើម្បីធ្វើការពិនិត្យ និងកែសម្រួលបន្ថែមដើម្បីឱ្យក្រមនេះមានលក្ខណៈសមស្រប និងអាចយកមកអនុវត្តបាន នៅក្នុងសង្គមកម្ពុជាធានាបាននូវប្រសិទ្ធិភាព និងសង្គតិភាព[22] ភាពរលូន និងស៊ីចង្វាក់គ្នាជាមួយនឹងប្រពៃណីច្បាប់កម្ពុជា និងបទដ្ឋានគតិយុត្តដែលមានស្រាប់។ ដើម្បីធានាសង្គតិភាព ភាពរលូន និងនិរន្តភាពរវាងច្បាប់ព្រហ្មទណ្ឌចាស់ និងច្បាប់ព្រហ្មទណ្ឌថ្មី ក្រមនេះក៏ត្រូវបានតាក់តែងដោយគោរពគំនិតសំខាន់ៗដែលមានចែងក្នុងក្រមព្រហ្មទណ្ឌចាស់ និងក្នុងប្រព័ន្ធច្បាប់រ៉ូម៉ាំង-អាល្លឺម៉ង់[23]ដែលជាប្រពៃណីនៃច្បាប់ព្រហ្មទណ្ឌកម្ពុជា។ ម្យ៉ាងទៀតដើម្បីបំពេញបន្ថែមចន្លោះខ្វះខាតនៃច្បាប់ និងបទប្បញ្ញត្តិព្រហ្មទណ្ឌដទៃទៀតដែលកំពុងនៅជាធរមាននាពេលនោះ ក្រមព្រហ្មទណ្ឌក៏បានចែងអំពីបទល្មើសបន្ថែមផ្សេងទៀតដែលចាំបាច់ ដើម្បីអនុញ្ញាតឱ្យប្រព័ន្ធបង្ក្រាបអាចប្រយុទ្ធប្រឆាំងប្រកបដោយប្រសិទ្ធិភាព និងគ្រប់ជ្រុងជ្រោយទៅនឹងទម្រង់ថ្មីៗនៃបទល្មើសក្នុងសង្គម និងឧក្រិដ្ឋកម្មសម័យទំនើបផ្សេងៗ។

**១.១.១.២. ការអនុម័តច្បាប់**

ក្រោមកិច្ចខិតខំប្រឹងប្រែងចងក្រងអស់រយៈពេលជាង ១០ឆ្នាំរបស់ក្រសួងយុត្តិធម៌ និងដោយមានការជួយគាំទ្រពីភាគីបារាំងផងដែរនោះ ជាលទ្ធផលសេចក្តីព្រាងក្រមព្រហ្មទណ្ឌត្រូវបានអនុម័តដោយអង្គប្រជុំគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩។ ក្រមព្រហ្មទណ្ឌដែលរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាបានធ្វើការអនុម័តនៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៤ និងដោយព្រឹទ្ធសភា នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៦ នីតិកាលទី២។

**១.១.១.៣. ការប្រកាសអោយប្រើ**

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ **ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ មានចំនួន ៦៧២មាត្រា**។ ក្រមនេះបានចូលជាធរមាននៅរាជធានីភ្នំពេញ១០ថ្ងៃក្រោយពេលប្រកាសឲ្យប្រើ គឺថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៩ និង២០ថ្ងៃក្រោយពេលប្រកាស

---

[22] សទ្ទានុក្រមវិទ្យាសាស្ត្រសេដ្ឋកិច្ចខ្មែរ អង់គ្លេស និងបារាំងបានពន្យល់ពាក្យ "សង្គតិភាព" មានន័យថាការរាប់អានគ្នា ការរួបរួមគំនិតគ្នា ការជួបប្រសព្វគ្នា សេចក្តីស្មោះស្ម័គ្រទៅវិញទៅមករកគ្នា។ ដកស្រង់ពីគេហទំព័រ https://thmeythmey.com (ថ្ងៃចូលមើលចុងក្រោយ ១៨ សីហា ២០២៤)។

[23] អាចហៅម្យ៉ាងទៀតថា ច្បាប់Civil Law ដែលមានប្រវត្តិតាំងពីសម័យចក្រភពរ៉ូម៉ាំង។ ការធ្វើច្បាប់នេះ គឺគេពឹងផ្អែកទៅលើស្ថាប័នមួយដែលមានអំណាចបញ្ញត្តិច្បាប់ ដើម្បីតាក់តែងជាក្រម ឬហៅថាច្បាប់សរសេរ។ ដកស្រង់ពីគេហទំព័រ https://www.khsearch.com/qna/26516 (ថ្ងៃចូលមើលចុងក្រោយ ១៨ សីហា ២០២៤)។

ឲ្យប្រើនៅទូទាំងប្រទេស គឺថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៩[24]។ យោងតាមមាត្រា ៦៧២ នៃក្រមព្រហ្មទណ្ឌ បទបញ្ញត្តិទូទៅនៃគន្ថីទី១ នៃក្រមព្រហ្មទណ្ឌត្រូវយកទៅអនុវត្តភ្លាមក្រោយការចូលជាធរមាននៃក្រម ចំណែកឯបទបញ្ញត្តិផ្សេងៗទៀតត្រូវយកទៅអនុវត្តក្នុងរយៈពេល ១ឆ្នាំក្រោយការចូលជាធរមាននៃក្រម។ ហេតុដូច្នេះ នៅក្នុងបញ្ញត្តិនៃក្រមព្រហ្មទណ្ឌគឺមាន ៦៧២មាត្រា ដែលចែកជា ៦គន្ថី ចំពោះមាត្រា ១ រហូតដល់មាត្រា ១៨២ នៃក្រមព្រហ្មទណ្ឌបានចាប់ផ្តើមអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា ចាប់តាំងពីពេលដែលក្រមព្រហ្មទណ្ឌបានចូលជាធរមានមកម្ល៉េះ រីឯបទបញ្ញត្តិចាប់ពីមាត្រា ១៨៣ រហូតដល់មាត្រា ៦៦៧ នៃក្រមព្រហ្មទណ្ឌវិញគឺត្រូវចូលជាធរមាន ១ឆ្នាំក្រោយក្រោយពេលប្រកាសឲ្យប្រើ ត្រូវយកមកអនុវត្តនៅរាជធានីភ្នំពេញ ចាប់តាំងពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១០ និងនៅទូទាំងប្រទេស ចាប់តាំងពីថ្ងៃ២០ ខែធ្នូ ឆ្នាំ២០១០តទៅ លើកលែងតែមាត្រាមួយចំនួនដែលមាននៅក្នុងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ។

### ១.១.២. ប្រភពនៃក្រមព្រហ្មទណ្ឌ

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មានប្រភពមកពីៈ ជាតិ និងអន្តរជាតិ។[25]

#### ១.១.២.១. ប្រភពជាតិ

មានប្រភពមកពីជាតិដែលមានដូចជាៈ រដ្ឋធម្មនុញ្ញ ច្បាប់ព្រហ្មទណ្ឌ បទដ្ឋានគតិយុត្តក្រោមច្បាប់ យុត្តិសាស្ត្រ លទ្ធិ ប្បវេណី ទំនៀមទំលាប់ ទ្រឹស្តី ប្រពៃណី សាសនា។ល។

#### ក. រដ្ឋធម្មនុញ្ញ

រដ្ឋធម្មនុញ្ញ គឺជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា[26]។ ហេតុនេះរដ្ឋធម្មនុញ្ញត្រូវស្ថិតនៅឋានានុក្រមលើគេបង្អស់នៃច្បាប់ដែលអាចបញ្ជាក់ថា ច្បាប់ទាំងឡាយត្រូវតែស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត។ អាស្រ័យហេតុនេះ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ បានបញ្ជាក់ផងដែរពីគោលការណ៍មួយចំនួនដែលទាក់ទងនឹងនីតិព្រហ្មទណ្ឌដូចជា គោលការណ៍សន្មតថាគ្មានទោស ឬហៅម្យ៉ាងទៀតថា គោលការណ៍សច្ចធារណ៍នៃនិរទោស[27] ការការពារភាពមិនអាចរំលោភបាននៃលំនៅដ្ឋាន អាថ៌កំបាំងនៃការឆ្លងឆ្លើយតាមលិខិត តាមសារទូលេខ ទូរពុម្ព និងតាមទូរស័ព្ទ[28]។ល។ ការហាមឃាត់មិនអោយប្រើប្រាស់អំពើហិង្សាដើម្បីសួរចម្លើយនៃពិរុទ្ធភាព ដូចមានចែងក្នុងមាត្រា ៣៨ ថា ″ ការបង្ខិតបង្ខំធ្វើបាបលើ

[24] មាត្រា ៩៣ ថ្មី កថាខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

[25] ដកស្រង់ពីគេហទំព័រ https://www.scribd.com (ថ្ងៃចូលមើលចុងក្រោយ ៨ សីហា ២០២៤)។

[26] មាត្រា ១៥០ ថ្មី នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣។

[27] មាត្រា ៣៨ កថាខណ្ឌទី៧ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣។

[28] មាត្រា ៤០ កថាខណ្ឌទី៣ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣។

រូបរាងកាយ ឬប្រព្រឹត្តកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្មអនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធធនាគារ ត្រូវហាមឃាត់មិនឲ្យធ្វើឡើយ។ ជនដៃដល់ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិតត្រូវទទួលទោសតាមច្បាប់។ ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ"។

### ខ. ច្បាប់ក្នុងន័យចង្អៀត

ច្បាប់ក្នុងន័យចង្អៀត គឺជាច្បាប់ដែលមានប្រភពចេញពីអង្គការនីតិបញ្ញត្តិ។ រហូតមកដល់បច្ចុប្បន្ននេះ ច្បាប់ជាច្រើនត្រូវបានអនុម័ត និងប្រកាសឲ្យប្រើ។ ច្បាប់ទាំងនោះរួមមានដូចជា[29]៖

- បទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២
- ច្បាប់ស្តីពីស្ថានទម្ងន់ទោសបទឧក្រិដ្ឋ ប្រកាសឲ្យប្រើនៅថ្ងៃទី០៧ ខែមករា ឆ្នាំ២០០២
- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ប្រកាសឲ្យប្រើនៅថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៣
- ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រកាសឲ្យប្រើនៅថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៧
- ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រកាសឲ្យប្រើនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨
- ច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង ប្រកាសឲ្យថ្ងៃនៅថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦
- ច្បាប់ភូមិបាល ប្រកាសឲ្យប្រើនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១
- ច្បាប់ស្តីពីការរំលូតកូន ប្រកាសឲ្យប្រើថ្ងៃនៅថ្ងៃទី១២ ខែ វិច្ឆិកា ឆ្នាំ១៩៩៧
- ច្បាប់ស្តីពីការផ្តន្ទាទោសការកាន់អាវុធ និងការពាក់សំលៀកបំពាក់ឯកសណ្ឋានដោយខុសពីបទបញ្ជា ប្រកាសឲ្យប្រើនៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ១៩៩២
- ច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវ ប្រកាសឲ្យប្រើនៅថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៥
- ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ប្រកាសឲ្យប្រើនៅថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៧
- ក្រមនីតិវិធីព្រហ្មទណ្ឌ ប្រកាសឲ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
- និងក្រមព្រហ្មទណ្ឌ ប្រកាសឲ្យប្រើនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។ល។ និង។ល។

[29] នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ កែសម្រួលដោយលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ ២០១២ ទំព័រ១២។

**គ. បទបញ្ជា**

បទដ្ឋានគតិយុត្តនានាដែលមានប្រភពមកពីអង្គការនីតិប្រតិបត្តិក៏ជាប្រភពនៃនីតិព្រហ្មទណ្ឌដែរ។ មាត្រា ១ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌបានបញ្ជាក់យ៉ាងច្បាស់លាស់ពីករណីនេះដោយចែងថា "នៅក្នុងករណីចាំបាច់បទដ្ឋានគតិយុត្តដែលចេញដោយអង្គការនីតិប្រតិបត្តិអាចចែងពីបទលហុដែលត្រូវផ្ដន្ទាទោសត្រឹមតែពិន័យជាប្រាក់តែប៉ុណ្ណោះ"។

**១.១.២.២. ប្រភពអន្តរជាតិ**

មានប្រភពមកពីអន្តរជាតិ គឺមានដូចជា៖ សន្ធិសញ្ញា អនុសញ្ញា កតិការសញ្ញាពាក់ព័ន្ធនឹងសិទ្ធិមនុស្ស កិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនឹងការជួយគ្នាទៅវិញទៅមកលើវិស័យព្រហ្មទណ្ឌ កិច្ចព្រមព្រៀងអន្តរជាតិ និងការធ្វើបត្យាប័ន និងតុលាការព្រហ្មទណ្ឌអន្តរជាតិ។

ព្រះរាជាណាចក្រកម្ពុជា គឺជាប្រទេសហត្ថលេខីនៃសន្ធិសញ្ញអន្តរជាតិជាច្រើន។ ពាក់ព័ន្ធនឹងរឿងក្តីព្រហ្មទណ្ឌ គេសង្កេតឃើញមានសន្ធិសញ្ញាមួយចំនួនដូចជា[30]៖

- កតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងនយោបាយ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ ។
- អនុសញ្ញាស្តីពី ការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៤៨ ។
- សេចក្តីប្រកាសជាសកលស្តីពី សិទ្ធិមនុស្ស ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ ។
- អនុសញ្ញាស្តីពី សិទ្ធិកុមារ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩ ។
- អនុសញ្ញាទីក្រុងវីយែនស្តីពី ទំនាក់ទំនងការទូត ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៦១ ។
- អនុសញ្ញាទីក្រុងវីយែនស្តីពី ទំនាក់ទំនងកុងស៊ុល ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៦៣ ។
- សន្ធិសញ្ញាស្តីពី បត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ១៩៦៣ ។
- សន្ធិសញ្ញាស្តីពី បត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៦៣ ។
- សន្ធិសញ្ញាស្តីពី បត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៦៣ ។

[30] នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ កែសម្រួលដោយលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ ២០១២ ទំព័រ១១។

## ១.២. ទំនាក់ទំនងនៃក្រម

ដើម្បីការសិក្សាស្វែងយល់ពីទំនាក់ទំនងនៃក្រមព្រហ្មទណ្ឌកម្ពុជាអោយកាន់តែមានភាពងាយស្រួល យើងនឹងធ្វើការចែកចេញជា ៣ ចំណុចរួមមាន៖

### ១.២.១. ចំណែកចែកក្រម

ជាការពិតណាស់យើងទាំងអស់គ្នាបានដឹងច្បាស់រួចមកហើយថា ក្រមព្រហ្មទណ្ឌយើងបច្ចុប្បន្នត្រូវបានបែងចែកចេញជា ២ ផ្នែកគឺ៖ ផ្នែកទូទៅ និងផ្នែកពិសេស។

#### ១.២.១.១. ផ្នែកទូទៅ

ក្នុងផ្នែកទូទៅនៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ រាប់ចាប់ពីគន្ថីទី១ បទប្បញ្ញត្តិទូទៅ មាត្រា ១ រហូតដល់មាត្រា ១៨២។ ក្នុងផ្នែកនេះដែរជាកម្រងអត្ថបទច្បាប់ដែលសិក្សាអំពីគោលការណ៍ទូទៅដូចជា៖

- ការសិក្សាលើដែនអនុវត្តច្បាប់ព្រហ្មទណ្ឌ (ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា និងការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងលំហ)
- ចំណាត់ថ្នាក់នៃបទល្មើស (បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ)
- ការទទួលខុសត្រូវច្បាប់ព្រហ្មទណ្ឌ ប្រភេទនៃទោស
- និងជាពិសេសសិក្សាលើគោលការណ៍ការអនុវត្តទោស។ល។

#### ១.២.១.២. ផ្នែកពិសេស

ព្រហ្មទណ្ឌពិសេសរាប់ចាប់ពីគន្ថីទី២ មាត្រា ១៨៣ រហូតដល់មាត្រា ៦៦៧។ ផ្នែកពិសេសជាកម្រងអត្ថបទច្បាប់ដែលសិក្សាលើនិយមន័យ អត្ថន័យ និងធាតុផ្សំនៃបទល្មើសនីមួយៗ សិក្សាអំពីបទល្មើស ប្រភេទបទល្មើស និងអំពីការបែងចែងប្រភេទនៃទោស ដូចជាទោសក្នុងបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុជាដើម។ **ឧទាហរណ៍**. បទរំលោភសេពសន្ថវៈ បទបង្ករបួសស្នាម។ ហើយព្រហ្មទណ្ឌពិសេសដែលចែងអំពីបទល្មើសនេះ គឺត្រូវបានគេធ្វើការបែងចែកជា ៣ ផ្នែកដូចជា៖

១. បទល្មើសប្រឆាំងនឹងបុគ្គល (មាត្រា ១៨៣ - មាត្រា ៣៥២)

២. បទល្មើសប្រឆាំងនឹងទ្រព្យសម្បត្តិ (មាត្រា ៣៥៣ - មាត្រា ៤៣១)

៣. បទល្មើសប្រឆាំងនឹងជាតិ (មាត្រា ៤៣២ - មាត្រា ៦៦៧)។

ម៉្យាងទៀតដើម្បីអាចឲ្យយើងចាត់ទុកបានថា អំពើណាមួយជាបទល្មើសនោះ គឺត្រូវមានចែងនៅក្នុងច្បាប់ ហើយដាច់ខាតក៏ត្រូវបំពេញអោយបាននូវធាតុផ្សំបទល្មើសទាំង ៣ ទើបគេអាចធ្វើការចោទប្រកាន់ ឬដាក់ទណ្ឌកម្មទៅលើជនដែលប្រព្រឹត្តនោះបាន ហើយធាតុផ្សំបទល្មើសទាំង ៣ រួមមាន៖

១. ធាតុផ្សំនីត្យានុកូល ឬធាតុច្បាប់

២. ធាតុផ្សំសត្យានុម័ត ឬធាតុសម្ភារៈ និង

៣. ធាតុផ្សំអត្តនោម័ត ឬធាតុចិត្តសាស្ត្រ។

### ១.២.២. គោលបំណងនៃក្រម

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាមានគោលបំណង គឺកំណត់បទល្មើស និងផ្តន្ទាទោសរាល់ការប្រព្រឹត្តអំពើអនីត្យានុគោលទាំងឡាយណា ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩ ហើយផ្តោតទៅលើការបង្ករព្យសនកម្មដល់ផលប្រយោជន៍សាធារណៈ ថែរក្សាការពារសិទ្ធិ សេរីភាព កិត្តិយស សេចក្តីថ្លៃថ្នូរ ផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋ ជាពិសេសផលប្រយោជន៍សាធារណៈ រក្សារបៀបរៀបរយសាធារណៈ និងសណ្តាប់ធ្នាប់សង្គម ធ្វើឲ្យសង្គមមានយុត្តិធម៌។

រីឯមុខងារនៃក្រមព្រហ្មទណ្ឌមានដូចជា[31]៖

- បង្ក្រាប មានន័យថា បង្ក្រាបរាល់អំពើដែលផ្ទុយនឹងច្បាប់ព្រហ្មទណ្ឌ
- អប់រំ មានន័យថា ធ្វើឲ្យទណ្ឌិតសម្របខ្លួនចូលក្នុងសង្គមវិញ
- បង្ការ មានន័យថា ទប់ស្កាត់ និងបញ្ឈប់ជាបន្ទាន់នូវការប្រព្រឹត្តបទល្មើសទាំងបច្ចុប្បន្ន និងអនាគត។

### ១.២.៣. គោលបំណងនៃទោសកំណត់ដោយក្រម

ក្រមព្រហ្មទណ្ឌបានកំណត់ទោសអោយសមស្របទៅនឹងអំពើល្មើស ឬក៏ព្យសនកម្មដែលសង្គមទទួលរង ហើយដាក់ទណ្ឌកម្មទៅលើជនដែលប្រព្រឹត្តល្មើសនោះ។ ការសម្រេចដាក់ទោសជាអតិបរមា ឬអប្បរមា គឺជាឆន្ទានុសិទ្ធិរបស់ចៅក្រម ប៉ុន្តែត្រូវផ្អែកទាំងស្រុងទៅលើគោលការណ៍ឯកត្តកម្មនៃទោស[32] មានន័យថា ចៅក្រមត្រូវថ្លឹងបទល្មើស គ្រោះថ្នាក់នៃបទល្មើសដែលកើតមានដោយសារអំពើល្មើស និងចរិតលក្ខណៈរបស់បុគ្គលល្មើស ក្នុងការជ្រើសរើសទោសនេះមួយដាក់អោយវាសមល្មមទៅនឹងកម្រិតដែលបានប្រព្រឹត្ត[33]។

---

[31] មេរៀននីតិព្រហ្មទណ្ឌទូទៅ របស់អ្នកគ្រូ វ៉ាន់នី សុភីដាវ

[32] មាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[33] ប្រសាសន៍របស់ ឯកឧត្តម គើត រិទ្ធ ក្នុងកម្មវិធីផ្សព្វផ្សាយក្រមព្រហ្មទណ្ឌ

# ជំពូកទី ២
# ការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងពេលវេលា

# ជំពូកទី ២
# ការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងពេលវេលា

កាលណាគេនិយាយអំពីការអនុវត្តច្បាប់ព្រហ្មទណ្ឌ នោះគេប្រាកដជានឹកឃើញភ្លាមទៅដល់ "**ដែនអនុវត្តច្បាប់ព្រហ្មទណ្ឌនៅព្រះរាជាណាចក្រកម្ពុជា**"។ ព្រោះថាដែនអនុវត្តច្បាប់ព្រហ្មទណ្ឌនេះ គឺចែងពីរបៀបនៃការអនុវត្តទៅលើបទល្មើស និងទោសទាំងឡាយណាដែលបានចូលជាធរមានដោយក្រមនេះ រួមទាំងបទល្មើស និងទោសណាខ្លះដែលមិនអាចអនុវត្តបានដោយសារថាបទល្មើស និងទោសទាំងនោះបានប្រព្រឹត្តក្រោមអានុភាពនៃច្បាប់ចាស់ ហើយដែលក្រមព្រហ្មទណ្ឌកម្ពុជាថ្មីនេះពុំបានចែង ម្ល៉ោះហើយអំពើទាំងនោះមិនអាចយកទៅអនុវត្តបានឡើយ។ ក្រមនេះមានអានុភាពអនុវត្តគ្របដណ្តប់លើដែនដីជាតិទាំងមូល ហើយក៏អាចពង្រីកវិសាលភាពរបស់ខ្លួនទៅដល់បរទេសផងដែរ កាលណាអំពើទាំងនោះមានការពាក់ព័ន្ធដល់ពលរដ្ឋដែលមានសញ្ជាតិខ្មែរ។ ហើយដែនអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជានេះ គឺមានចែងយ៉ាងច្បាស់លាស់នៅក្នុងច្បាប់ព្រហ្មទណ្ឌគ្រឹះ ឬច្បាប់សារធាតុនៅក្នុងជំពូកទី២ និងជំពូកទី៣ ចាប់ពីមាត្រា ៩ រហូតដល់មាត្រា ២៣។

## ២.១. គោលការណ៍ទាក់ទងនឹងការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា

ជាធម្មតាច្បាប់មួយនឹងមានអានុភាពរហូតដល់ថ្ងៃដែលមានការធ្វើវិសោធនកម្ម ឬនិរាករណ៍ណាមួយបានកើតឡើង។

### ២.១.១. ការចូលជាធរមាន និងការចាប់ផ្តើមអនុវត្ត

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានរដ្ឋសភាអនុម័តកាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៤ ហើយត្រូវបានដាក់ជូនព្រឹទ្ធសភាពិនិត្យ និងយល់ព្រមកាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៦ នីតិកាលទី២ ដែលក្រមនេះបានដាក់ថ្វាយព្រះមហាក្សត្រឡាយព្រះហស្តលេខាប្រកាសឱ្យប្រើកាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។

ជាទូទៅបើទោះជាច្បាប់ដែលត្រូវបានរដ្ឋសភាអនុម័ត ហើយត្រូវបានត្រួតពិនិត្យដោយព្រឹទ្ធសភា និងត្រូវបានប្រកាសឱ្យប្រើដោយព្រះមហាក្សត្រហើយក៏ដោយច្បាប់នោះមិនទាន់មានអានុភាពអនុវត្តនៅឡើយទេ គឺត្រូវរង់ចាំឱ្យច្បាប់នោះចូលជាធរមានជាមុនសិន ទើបអាចយកច្បាប់នោះទៅអនុវត្តបាន។ ជាគោលការណ៍នៃការចូលជាធរមានរបស់ច្បាប់ត្រូវបានរដ្ឋធម្មនុញ្ញកំណត់ថា "ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ ហើយត្រូវបានព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាប្រកាសឱ្យប្រើត្រូវចូលជាធរមាននៅរាជធានីភ្នំពេញ ក្នុងរយៈពេល១០ថ្ងៃគត់ក្រោយថ្ងៃប្រកាសឱ្យប្រើ និងនៅទូទាំងប្រទេសក្នុងរយៈ

ពេល២០ថ្ងៃគត់ក្រោយថ្ងៃប្រកាសឱ្យប្រើ។ ច្បាប់ដែលព្រះមហាក្សត្រទ្រង់បានឡាយព្រះហស្ថលេខាប្រកាសឱ្យប្រើត្រូវចុះក្នុងរាជកិច្ច និងផ្សព្វផ្សាយនៅទូទាំងប្រទេសឱ្យទាន់តាមពេលកំណត់"[34]។ ប៉ុន្តែបើច្បាប់នេះបានចែងថា ជាការប្រញាប់ច្បាប់នេះត្រូវចូលជាធរមានភ្លាមនៅទូទាំងប្រទេសក្រោយថ្ងៃប្រកាសឱ្យប្រើ។ ដូច្នេះបើយោងតាមគោលការណ៍នៃការចូលជាធរមានរបស់ច្បាប់ដែលបានកំណត់ដោយរដ្ឋធម្មនុញ្ញត្រង់មាត្រា ៩៣ នោះក្រមព្រហ្មទណ្ឌត្រូវចូលជាធរមាននៅរាជធានីភ្នំពេញនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៩ ពោលគឺរយៈពេល១០ថ្ងៃគត់ក្រោយថ្ងៃប្រកាសឱ្យប្រើ ហើយក្រមនេះត្រូវចូលជាធរមាននៅទូទាំងប្រទេសនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៩ ពោលគឺ២០ថ្ងៃគត់ក្រោយថ្ងៃប្រកាសឱ្យប្រើ។ ប៉ុន្តែបើយោងតាមការចែងកំណត់របស់ក្រមព្រហ្មទណ្ឌត្រង់មាត្រា ៦៧២ ចែងថា "បទប្បញ្ញត្តិនៃគន្ថីទី១ ស្តីពីបទប្បញ្ញត្តិទូទៅ ត្រូវយកទៅអនុវត្តភ្លាមក្រោយពីចូលជាធរមាន" ដែលគិតចាប់ពីមាត្រា ១ ដល់មាត្រា ១៨២ នៃក្រមព្រហ្មទណ្ឌ "ប៉ុន្តែចំពោះបទប្បញ្ញត្តិដទៃទៀតនៃក្រមព្រហ្មទណ្ឌអាចត្រូវយកទៅអនុវត្តបានក្នុងរយៈពេល ១ឆ្នាំក្រោយការចូលជាធរមាននៃក្រមនេះ"។ ដូចនេះ ក្រមព្រហ្មទណ្ឌបន្ទាប់ពីបានចូលជាធរមានហើយពុំទាន់អាចអនុវត្តបានទាំងស្រុងនោះទេ ពោលគឺអាចអនុវត្តបានតែចំពោះគន្ថីទី១ ស្តីពីបទប្បញ្ញត្តិទូទៅដែលមាន ១៨២ មាត្រា គឺគិតចាប់ពីមាត្រា ១ រហូតដល់មាត្រា ១៨២ នៃក្រមនេះ គឺអាចយកទៅអនុវត្តភ្លាមក្រោយពីការចូលជាធរមានគឺនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៩ នៅរាជធានីភ្នំពេញ និងនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៩ នៅទូទាំងប្រទេស។ ចំពោះបញ្ញត្តិដែលក្រៅពីគន្ថីទី១ នៃក្រមព្រហ្មទណ្ឌត្រូវរង់ចាំរយៈពេលមួយឆ្នាំក្រោយទើបអាចយកទៅអនុវត្តបាន ពោលគឺនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១០ នៅរាជធានីភ្នំពេញ និងនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០ នៅទូទាំងប្រទេសទើបអាចយកបញ្ញត្តិដទៃក្រៅពីគន្ថីទី១ ទៅអនុវត្តបាន។ លើកលែងតែមាត្រាមួយចំនួនដែលមាននៅក្នុងច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ។ ជារួមក្រមព្រហ្មទណ្ឌអាចអនុវត្តពេញលេញ នៅថ្ងៃទី០២ ខែសីហា ឆ្នាំ២០១១។

### ២.១.២. គោលការណ៍នីត្យានុកូលភាព

ជាក់ស្តែងមាត្រា ៣ នៃក្រមព្រហ្មទណ្ឌ គឺជាបទបញ្ញាត្តិមូលដ្ឋានដែលចែងពីគោលការណ៍នីត្យានុកូល ដោយមាត្រានេះបានចែងថា មានតែអំពើដែលបង្កើតជាបទល្មើសនៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន។ គោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងទោស ត្រូវតែកំណត់ដោយច្បាប់យ៉ាងច្បាស់លាស់។ គោលការណ៍នីត្យានុកូលភាពត្រូវបានទទួលស្គាល់ដោយ**លិខិតតុបករណ៍អន្តរជាតិ**[35] ដែលមានតម្លៃជាងរដ្ឋធម្មនុញ្ញ។ តាមរយៈមាត្រា ៣១

[34] មាត្រា ៩៣ ថ្មីនៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣។

[35] លិខិតតុបករណ៍អន្តរជាតិ គឺជាលិខិតបទដ្ឋានអន្តរជាតិ ដែលបង្កើតឡើងរវាងរដ្ឋ ឬក៏រវាងរដ្ឋ និងអង្គការអន្តរជាតិ។

កថាខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញកម្ពុជា បានចែងថា "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ"។

ដូចនេះ យើងមានកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយបានទទួលស្គាល់នូវគោលការណ៍នេះតាមរយៈមាត្រា ១១ ដោយកំណត់ថា "គ្មានជនណាម្នាក់ត្រូវបានផ្តន្ទាទោសពីបទល្មើសព្រហ្មទណ្ឌ ដោយអំពើ ឬការខកខានមិនបានធ្វើ បើអំពើ ឬការខកខាននេះមិនបានចែងក្នុងច្បាប់ជាតិ ឬអន្តរជាតិថាជាបទល្មើសព្រហ្មទណ្ឌនៅពេលធ្វើអំពើ ឬមានការខកខាននេះ។ ដូចនេះ អំពើមួយអាចក្លាយជាបទល្មើសបាន លុះត្រាណាតែមានចែងច្បាស់លាស់ក្នុងច្បាប់ជាមុន ដើម្បីអោយពលរដ្ឋអាចយល់ដឹងផង។ ការធ្វើដូចនេះ គឺអាចអោយពលរដ្ឋបែងចែកអំពើណាខ្លះជាបទល្មើស អំពើណាខ្លះជាសេរីភាពរបស់ខ្លួន។ ក្នុងន័យនេះច្បាប់ហាក់ដូចជាស្តែងនូវព្រំដែននៃសិទ្ធិ ហើយអ្នកច្បាប់ជាច្រើនយល់ថា ការធ្វើដូច្នេះអាចជួយទប់ស្កាត់ការប្រព្រឹត្តបទល្មើសនៅក្នុងសង្គមផង និងជួយការពារសិទ្ធិសេរីភាពបុគ្គលផង[36] ព្រោះការចែងកំណត់មុន គឺអាចឲ្យជនទាំងនោះខ្លាចរអានឹងប្រព្រឹត្តបទល្មើស គឺខ្លាចរអានឹងការទទួលទោស។

នៅក្នុងគោលការណ៍គ្រឹះនេះ គឺត្រូវបានគេយល់មកពីពាក្យថា "គ្មានបទល្មើស គ្មានទោស បើគ្មានច្បាប់ចែង" *"Nullum Crimen, Nulla Poena, Sine Lege"*។ យោងទៅតាមអត្ថន័យនៃពាក្យនេះ យើងអាចបែងចែកជាពីរប្រភេទផ្សេងទៀតនៃគោលការណ៍នីត្យានុកូលភាព គឺ**គោលការណ៍នីត្យានុកូលភាពនៃបទល្មើស** និង**គោលការណ៍នីត្យានុកូលភាពនៃទោស**។

**នីត្យានុកូលភាពនៃបទល្មើស** គឺសំដៅលើអំពើណាមួយ ដែលគេអាចចាត់ទុកថាជាបទល្មើសបាន លុះត្រាតែអំពើនោះមានចែងជាមុនយ៉ាងច្បាស់លាស់ក្នុងច្បាប់ថាជាបទល្មើស បើមិនដូច្នេះទេតុលាការមិនអាចផ្តន្ទាទោសជនប្រព្រឹត្តនោះបានឡើយ ហេតុនេះហើយបានជាមានគោលការណ៍មួយកំណត់ថា "គ្មានបទល្មើសណា ដែលច្បាប់មិនបានចែងឡើយ" *"Pas d'infraction sans texte de loi"*។[37] នោះយើងអាចយល់បានថា គោលការណ៍នេះបានតម្រូវអោយច្បាប់ព្រហ្មទណ្ឌកំណត់អោយបានច្បាស់លាស់នូវនិយមន័យនៃបទល្មើសនីមួយៗ ជាពិសេស គឺសញ្ញាណដែលជាធាតុផ្សំ។[38]

---

[36] សិក្ខាសាលាដើម្បីស្វែងយល់លើ សេចក្តីព្រាងច្បាប់ស្តីពីក្រមព្រហ្មទណ្ឌ រៀបចំដោយ គណៈកម្មការនីតិកម្ម និងយុត្តិធម៌នៃរដ្ឋសភា រៀបរៀង និងបង្ហាញដោយ ឯកឧត្តម កើត រិទ្ធ ឆ្នាំ២០០៩ ទំព័រទី២។

[37] នីតិព្រហ្មទណ្ឌទូទៅ លោកសាស្ត្រាចារ្យ ផាត់ ពៅស៊ាង ឆ្នាំ១៩៩៨ ទំព័រទី១៦។

[38] សិក្ខាសាលាដើម្បីស្វែងយល់លើ សេចក្តីព្រាងច្បាប់ស្តីពីក្រមព្រហ្មទណ្ឌ, រៀបចំដោយ គណៈកម្មការនីតិកម្ម និងយុត្តិធម៌នៃរដ្ឋសភា, រៀបរៀង និងបង្ហាញដោយ ឯកឧត្តម កើត រិទ្ធ, ឆ្នាំ២០០៩, ទំព័រទី២។

**នីត្យានុកូលភាពនៃទោសមានន័យថា** ដើម្បីយកទោសណាមួយទៅផ្តន្ទាទោសលើជនណាមួយបាន លុះត្រាតែទោសនោះមានចែងទុកជាមុននៅក្នុងច្បាប់ព្រហ្មទណ្ឌ បើមិនដូចនេះទេ គេមិនអាចអនុវត្តទោសទៅលើបុគ្គលណាម្នាក់បានឡើយ។[39] ដូចនេះ គឺដាច់ខាតត្រូវតែតំរូវអោយមានចែងពីបទប្បញ្ញត្តិនៃទោស បើមិនដូច្នេះទេ ចៅក្រមមិនអាចប្រកាសលើជនណាមួយបានឡើយ គឺមិនអាចបង្កើតទោសទណ្ឌដោយខ្លួនឯងទេ ទោះជាច្បាប់បានកំណត់ថាអំពើនោះជាបទល្មើសក៏ដោយ។ **ឧទាហរណ៍**. មាត្រា ៧៨ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៨៩ ចែងថា "ការមិនព្រមបង់អាហារកិច្ចដូចចែងខាងលើនេះ ចាត់ទុកជាបទល្មើសព្រហ្មទណ្ឌដែលនឹងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន បើកាលណាមានភស្តុតាងបញ្ជាក់ថាជនដែលត្រូវផ្តល់អាហារកិច្ចនេះមិនស្មោះត្រង់"។ ដូចនេះ បើយោងតាមមាត្រានេះ អំពើមិនព្រមបង់អាហារកិច្ចគឺជាបទល្មើសព្រហ្មទណ្ឌ ប៉ុន្តែមាត្រា ៧៨ ក៏មិនបានចែងកំណត់ ឬបញ្ញត្តិពីទោសទណ្ឌនៃបទល្មើសនេះឡើយ។ ដូចនេះអ្នកធ្វើអំពើនេះមិនត្រូវផ្តន្ទាទោសឡើយនាសម័យកាលនោះ ព្រោះច្បាប់បានកំណត់តែនីត្យានុកូលភាពនៃបទល្មើស តែមិនបានកំណត់នូវនីត្យានុភាពនៃទោស។ ប៉ុន្តែរហូតដល់ថ្ងៃចូលជាធរមានទាំងស្រុងនៅទូទាំងប្រទេសនូវគ្រប់បទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌនាថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០ យើងពិនិត្យឃើញថានីត្យានុកូលភាពនៃទោសបានលេចឡើងសម្រាប់អំពើមិនព្រមបង់អាហារកិច្ចតាមមាត្រា ៣២៤ ដែលត្រូវផ្តន្ទាទោសពី ១ខែទៅ ១ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) ទៅ ២.០០០,០០០ (២លាន) រៀល។

### ២.១.២.១. គោលការណ៍បកស្រាយច្បាប់ព្រហ្មទណ្ឌ

យោងតាមមាត្រា ៥ នៃក្រមព្រហ្មទណ្ឌ២០០៩ ចែងថា "ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់ត្រូវបកស្រាយយ៉ាងតឹងរ៉ឹង។ ចៅក្រមមិនអាចពង្រីកវិសាលភាពអនុវត្ត ឬប្រព្រឹត្តតាមសទិសភាពបានឡើយ"។ យោងទៅតាមគោលការណ៍នេះ លោកម៉ុសតេសនខ្យឺបានប្រើប្រាស់ពាក្យមួយឃ្លាថា "ចៅក្រមគ្រាន់តែជាមាត់មួយសម្រាប់និយាយពីច្បាប់ប៉ុណ្ណោះ។[40] មានន័យថា ចៅក្រមគឺគ្រាន់តែជាអ្នកអនុវត្តច្បាប់ដើម្បីដោះស្រាយជម្លោះ និងធ្វើការផ្តន្ទាទោសចំពោះបទល្មើសទាំងឡាយណា ដែលមានចែងក្នុងបញ្ញត្តិច្បាប់តែប៉ុណ្ណោះ[41]។ ដូចនេះ ចៅក្រមពុំមានអំណាចក្នុងការបកស្រាយពង្រីកវិសាលភាព ដើម្បីតម្រូវឲ្យអំពើណាមួយក្លាយជាបទល្មើស ដោយអំពើនោះពុំមានច្បាប់ចែងថាជាបទល្មើសព្រហ្មទណ្ឌ ដើម្បីផ្តន្ទាទោសអំពើនោះតាមគោលការណ៍សទិសភាព

[39] នីតិព្រហ្មទណ្ឌទូទៅ, លោកសាស្ត្រាចារ្យ ផាត់ ពៅស៊ាង ឆ្នាំ១៩៩៨ ទំព័រទី១៦។

[40] មាត្រា កម ១១១១-៦ សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី ឆ្នាំ២០០៥។

[41] សិក្ខាសាលាដើម្បីស្វែងយល់លើ សេចក្តីព្រាងច្បាប់ស្តីពីក្រមព្រហ្មទណ្ឌ, រៀបចំដោយ គណៈកម្មការនីតិកម្ម និងយុត្តិធម៌នៃរដ្ឋសភា, រៀបរៀង និងបង្ហាញដោយ ឯកឧត្តម កើត រិទ្ធ, ឆ្នាំ២០០៩, ទំព័រទី៣។

(គោលការណ៍ប្រហាក់ប្រហែល) បានឡើយ។ គោលការណ៍នេះ គឺតម្រូវអោយចៅក្រមធ្វើការបកស្រាយច្បាប់ព្រហ្មទណ្ឌអោយបានត្រឹមត្រូវ គឺដោយតឹងរ៉ឹង និងដោយម៉ឺងម៉ាត់បំផុត។[42]

គោលការណ៍នេះ ក៏ជាបច្ច័យនៃគោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងទោសផងដែរ។[43] ក្នុងគោលការណ៍នេះ កាលណាបើចៅក្រមបានធ្វើការបកស្រាយច្បាប់ ដោយពង្រីកវិសាលភាព ឬចាកឆ្ងាយពីខ្លឹមសារ និងគោលបំណងនៃបទប្បញ្ញត្តិដែលបានកំណត់នោះ គឺមានន័យថា ចៅក្រមបានរំលោភលើសមត្ថកិច្ចរបស់អំណាចនីតិប្បញ្ញត្តិ ដោយធ្វើឈរតាំងខ្លួនជាអ្នកធ្វើច្បាប់វិញ។ ព្រោះនាំឲ្យជាការរំលោភបំពានលើស្មារតីនៃច្បាប់ព្រហ្មទណ្ឌ ក៏ដូចជាស្មារតីនៃឆន្ទៈប្រជាពលរដ្ឋ នេះគឺជាការចាកឆ្ងាយ និងផ្ទុយពីគោលការណ៍នៃការបែងចែកអំណាចទាំងបី។ ប៉ុន្តែតាមអត្ថន័យនេះ ក្រមព្រហ្មទណ្ឌបានផ្តល់ជូនដល់ចៅក្រមនូវអំណាចសំខាន់ៗជាច្រើនផងដែរដូចជានៅក្នុងរឿងឯកត្តកម្មនៃទោស គឺមានន័យថា ចៅក្រមអាចបកស្រាយច្បាប់ព្រហ្មទណ្ឌនោះ តែការបកស្រាយច្បាប់នោះត្រូវបកស្រាយចំនុចដែលចាំបាច់ដើម្បីស្វែងរកអត្ថន័យពិតប្រាកដ និងច្បាស់លាស់នៃបទប្បញ្ញត្តិព្រហ្មទណ្ឌ ជាពិសេសនៅពេលដែលបទប្បញ្ញត្តិនោះចែងមានលក្ខណៈស្រពិចស្រពិលពុំច្បាស់លាស់។[44] ចំណែកការប្រកាសទោសវិញ គឺចៅក្រមត្រូវផ្អែកទៅលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើស ទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាន និងបន្ទុកទៅលើមូលហេតុព្រមទាំងទៅលើកិរិយាមារយាទរបស់ជនល្មើសក្រោយពេលប្រព្រឹត្តបទល្មើសជាអាទិ៍ចំពោះជនរងគ្រោះ។[45]

## ២.២. ការអនុវត្តចំពោះច្បាប់ព្រហ្មទណ្ឌគ្រឹះ ឬច្បាប់សារធាតុ

ច្បាប់ព្រហ្មទណ្ឌគ្រឹះ ឬច្បាប់សារធាតុ គឺជាច្បាប់ទាំងឡាយណាដែលកំណត់អំពីធាតុផ្សំនៃបទល្មើស ឬដែលបញ្ញាត្តអំពីទោសដែលត្រូវអនុវត្តចំពោះបទល្មើសដែលបានប្រព្រឹត្តរួមទាំងលក្ខខណ្ឌនៃការទទួលខុសត្រូវរបស់ជនល្មើសនៃអំពើនោះ។ ហើយច្បាប់នេះទៀតសោត គឺមានតាំងពីច្បាប់ព្រហ្មទណ្ឌជាតិ និងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដែលមានអានុភាពអនុវត្តក្នុងព្រះរាជាណាចក្រកម្ពុជា។ ហើយវិធានទូទៅ គឺនៅតែជាគោលការណ៍នៃភាពមិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ និងគោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងទោសដដែល។ ម៉្យាងទៀតចំពោះច្បាប់ព្រហ្មទណ្ឌគ្រឹះនេះ គេក៏ធ្វើការបែងចែកអោយមានភាពខុសគ្នានូវច្បាប់

[42] មាត្រា កម ១១១១-៦ សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី ឆ្នាំ២០០៥។

[43] មាត្រា កម ១១១១-៦ សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មី ឆ្នាំ២០០៥។

[44] សិក្ខាសាលាដើម្បីស្វែងយល់លើ សេចក្តីព្រាងច្បាប់ស្តីពីក្រមព្រហ្មទណ្ឌ, រៀបចំដោយ គណៈកម្មការនីតិកម្ម និងយុត្តិធម៌នៃរដ្ឋសភា, រៀបរៀង និងបង្ហាញដោយ ឯកឧត្តម កើត រិទ្ធ, ឆ្នាំ២០០៩, ទំព័រទី៣។

[45] មាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩។

ថ្មីស្រាលជាង ឬធ្ងន់ជាងច្បាប់ចាស់ដែលចែងអំពីបទល្មើស និងទោសនេះឯង។ ការអនុវត្តច្បាប់ព្រហ្មទណ្ឌត្រូវគោរពគោលការណ៍ចំនួន ២ គឺគោលការណ៍ប្រតិសកម្ម និងគោលការណ៍មិនប្រតិសកម្ម។ បើនិយាយអំពីដែនអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងកាល គឺការអនុវត្តច្បាប់ព្រហ្មទណ្ឌត្រូវផ្អែកលើគោលការណ៍ពីរផ្ទុយគ្នា ប៉ុន្តែមិនដាច់ដោយឡែកពីគ្នាទេ ពោលគឺគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌដែលធ្ងន់ជាង និងគោលការណ៍ប្រតិសកម្មច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង។ ដោយយល់ឃើញនូវអានុភាពនៃច្បាប់ថ្មីនេះហើយ ទើបយើងសង្កេតឃើញថា មានចែងនូវគោលការណ៍ពីរសំខាន់ៗ គឺគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ និងអញ្ញត្រកម្មនៃគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ។

### ២.២.១. គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ

គោលការណ៍មិនប្រតិសកម្មច្បាប់ព្រហ្មទណ្ឌ គឺជាគោលការណ៍គ្រឹះនៃនីតិព្រហ្មទណ្ឌ។ សញ្ញាណនៃគោលការណ៍នេះចេញមកពីបារាំងដែលកើតមានតាំងតែពីឆ្នាំ១៧៨៩ នៅក្នុងសេចក្តីថ្លែងការណ៍ស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិមនុស្សរបស់បារាំង ហើយក្លាយជាគោលការណ៍មួយនៅក្នុងរដ្ឋធម្មនុញ្ញបារាំង។ ហើយគោលការណ៍នេះ គឺជាគោលការណ៍គ្រឹះនៃនីតិសិទ្ធិមនុស្ស និងនៅក្នុងលិទ្ធិប្រជាធិបតេយ្យ ដើម្បីធានានូវសិទ្ធិសេរីភាព និងសុវត្ថិភាពគតិយុត្តរបស់ពលរដ្ឋ។ បន្ថែមពីនេះ វាគឺជាគោលការណ៍ដែលការពារការសងសឹកគ្នារវាងគណបក្សនយោបាយដែលការពារមិនឱ្យអ្នកឡើងកាន់អំណាចក្រោយសងសឹកទៅលើអ្នកកាន់អំណាចមុនដែលបាត់បង់អំណាច។

គោលការណ៍នេះ គឺជាគោលការណ៍វិបាកកម្មដែលវាត្រូវដើរទន្ទឹមគ្នាជាមួយនឹងគោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងទោស។ គោលការណ៍នេះមានន័យថា ច្បាប់ព្រហ្មទណ្ឌគឺមានអានុភាពអនុវត្តតែទៅអនាគត ហើយមិនមានអានុភាពអនុវត្តទៅអតីតកាលទេ។ មានន័យថា អនុវត្តតែទៅលើបទល្មើសណាដែលកើតក្រោយច្បាប់ព្រហ្មទណ្ឌចូលជាធរមានតែប៉ុណ្ណោះ យើងមិនអាចយកច្បាប់ព្រហ្មទណ្ឌថ្មីនេះទៅអនុវត្តចំពោះអំពើដែលបានកើតឡើងរួមទាំងទោសដែលបានប្រកាស ឬអនុវត្តមុនច្បាប់នេះចូលជាធរមានបាននោះទេ[46]។ ដូចនេះ ច្បាប់ព្រហ្មទណ្ឌដែលធ្ងន់ជាងមិនអនុវត្តទៅនឹងបទល្មើសដែលកើតមុនច្បាប់ព្រហ្មទណ្ឌនោះ ចូលជាធរមាននោះទេ ពោលគឺមិនប្រតិសកម្មនោះទេ។ គោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌត្រូវបានអនុវត្តចំពោះបទល្មើសដែលកើតក្រោយការចូលជាធរមាននៃច្បាប់ព្រហ្មទណ្ឌ និងករណីច្បាប់ព្រហ្មទណ្ឌថ្មីធ្ងន់ជាងច្បាប់ចាស់ (ជាហេតុនាំឲ្យមិនមានអនុភាពប្រតិសកម្ម)។ **ឧទាហរណ៍**. ប្រសិនបើច្បាប់ព្រហ្មទណ្ឌអន្តរកាលចែងថា អំពើសរសេរអសីលធម៌គឺជាបទល្មើសលហុ ហើយពិន័យជាប្រាក់៥០០រៀល

[46] មាត្រា ៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩។

ប៉ុន្តែច្បាប់ថ្មីបានចែងថា អំពើសរសេរអសីលអម៌ គឺជាបទល្មើសមជ្ឈិមត្រូវផ្តន្ទាទោសដាក់គុក៣ខែ និងពិន័យជាប្រាក់ ៥លានរៀល។ អំពើទាំងឡាយដែលបានប្រព្រឹត្តក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាល មិនអាចយកច្បាប់ព្រហ្មទណ្ឌថ្មីទៅអនុវត្តទៅលើបទល្មើសនោះបានទេ ពីព្រោះច្បាប់ព្រហ្មទណ្ឌថ្មីមានលក្ខណៈធ្ងន់ជាងច្បាប់ព្រហ្មទណ្ឌអន្តរកាល។

គោលការណ៍នេះ គឺមានគោលដៅជាពិសេសធានានូវសិទ្ធិសេរីភាពក៏ដូចជាសុវត្ថិភាពគតិយុត្តនៃពលរដ្ឋ ហើយវាក៏ជាការជៀសវាងនូវការសងសឹកជាលក្ខណៈនយោបាយទៀតផងសម្រាប់ប្រទេសដែលប្រកាន់យកលទ្ធិប្រជាធិបតេយ្យ[47]។ ក្នុងគោលការណ៍នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយក៏បានទទួលស្គាល់ផងដែរ ដោយបានចែងថា "គ្មានជនណាម្នាក់ត្រូវជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌចំពោះអំពើ ឬការខកខានណាមួយ ដែលមិនបានចាត់ជាបទល្មើសព្រហ្មទណ្ឌស្របតាមច្បាប់ជាតិ ឬច្បាប់អន្តរជាតិក្នុងខណៈពេលប្រព្រឹត្តនោះឡើយ"។[48] ដូចនេះអំពើមួយក្លាយជាបទល្មើស លុះត្រាតែក្នុងខណៈពេលនៃការប្រព្រឹត្តអំពើនោះ ហើយច្បាប់នាពេលនោះបានកំណត់ថាអំពើនោះជាបទល្មើស។ វាគឺជាបរិបទសំខាន់មួយ ព្រោះដើម្បីកុំឲ្យគណបក្សនយោបាយដែលឡើងកាន់អំណាចមានគោលដៅចង់សងសឹកទៅលើសមាជិករដ្ឋាភិបាលចាស់ ឬក្រុមមនុស្សពីមុន ដោយពួកគេនាំគ្នាធ្វើច្បាប់មួយថ្មី ដើម្បីកំណត់អំពើរបស់អ្នកទាំងនោះថាជាបទល្មើសហើយត្រូវផ្តន្ទាទោសដោយអានុភាពប្រតិសកម្ម។ គោលការណ៍នេះបានសំដៅដល់បច្ច័យរបស់ខ្លួនផង គឺទាំងនីត្យានុកូលភាពនៃបទល្មើស និងទោស។ គោលការណ៍នេះ គឺជាគោលការណ៍គ្រឹះនៃនីតិសិទ្ធិមនុស្សក៏ដូចជាគោលការណ៍គ្រឹះនៃសង្គមប្រជាធិបតេយ្យ ព្រោះក្នុងរដ្ឋប្រជាធិបតេយ្យ សកម្មភាពទាំងឡាយដែលត្រូវបានកំណត់ដោយច្បាប់ គឺជាសេចក្តីហាមឃាត់មិនអោយធ្វើ ប៉ុន្តែក្រៅពីសកម្មភាពដែលហាមឃាត់ដោយច្បាប់ គឺសុទ្ធតែជាសេរីភាពរបស់ប្រជាពលរដ្ឋ។ ខុសពីរដ្ឋកុម្មុយនីស្ត រាល់សិទ្ធិ និងសេរីភាព គឺត្រូវបានកំណត់ដោយច្បាប់ក្រៅពីនេះ គឺសុទ្ធតែជាការហាមឃាត់។

ក្រៅពីមានចែងក្នុងក្រមនៃព្រះរាជាណាចក្រកម្ពុជាហើយ តាមពិតគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌក៏ត្រូវបានចែងក្នុងសន្ធិសញ្ញាអន្តរជាតិមួយចំនួនផងដែរ។ ក្រោយពីបានចូលជាភាគីក្នុងឆ្នាំ ១៩៩២ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ដែលសរសេរបញ្ចូល ឬយោងដល់សន្ធិសញ្ញាទាំងនោះត្រូវបានអនុម័ត ហើយក៏បានចែងពីការទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចដែលមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញា

[47] នីតិព្រហ្មទណ្ឌទូទៅខ្មែរ សាស្ត្រាចារ្យ កៅ សីហា, ឆ្នាំ២០១៣, ទំព័រទី១៧០ និង ១៧១

[48] មាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ឆ្នាំ១៩៦៦

ទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស[49]។ ដោយមាត្រា ៧ នៃអនុសញ្ញាអឺរ៉ុបស្តីពីការថែរក្សាការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន និងមាត្រា ១៥ នៃកតិកាសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ដែលនៅក្នុងលំដាប់គតិយុត្តបារាំងមានតំលៃខ្ពស់ជាងច្បាប់ ពីព្រោះថាជាសន្ធិសញ្ញាអន្តរជាតិ។

### ២.២.២. អញ្ញត្រកម្មនៃគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ

ទន្ទឹមគ្នានឹងការអនុវត្តគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ គោលការណ៍ប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌដែលស្រាលជាងក៏ត្រូវអនុវត្តផងដែរ។ មានន័យថា ចៅក្រមត្រូវអនុវត្តច្បាប់ព្រហ្មទណ្ឌដែលចូលជាធរមានក្រោយបទល្មើសកើតមាន ប្រសិនបើច្បាប់ព្រហ្មទណ្ឌនោះបញ្ញត្តិទោសស្រាល ឬក៏លុបចោលបទល្មើសណាមួយដែលមានក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាល។ ហើយការអនុវត្តនេះ គឺជាការអនុវត្តដើម្បីអនុគ្រោះដល់ជនល្មើស។ ក្នុងការអនុវត្តដោយប្រតិសកម្មនោះគឺមានចែងក្នុងបញ្ញត្តិមួយចំនួនដូចជា ច្បាប់ដែលលុបចោលនៃបទល្មើសដែលមានចែងក្នុងមាត្រា ៩ ដល់មាត្រា ១១ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ ប្រភេទនៃច្បាប់លុបចោលបទល្មើស និងកំណត់ទោសស្រាលនេះគឺត្រូវអនុវត្តភ្លាមៗ[50]។ បានន័យថា អំពើប្រព្រឹត្តក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាលបានចែងធ្ងន់ (ចែងថាជាបទល្មើស) មិនចាំបាច់ចោទប្រកាន់ទៀតទេ ប្រសិនបើច្បាប់ព្រហ្មទណ្ឌស្រាលជាងបានចូលជាធរមាន ដែលបានលុបចោលអំពើនោះថាមិនមែនជាបទល្មើសទេ។ ដូចនេះចៅក្រមមិនចាំបាច់ចោទប្រកាន់ជនប្រព្រឹត្តអំពើនោះទៀតទេ ពីព្រោះច្បាប់ព្រហ្មទណ្ឌដែលស្រាលជាងបានលុបអំពើនោះថាមិនមែនជាបទល្មើសទៀតទេ។ ប្រសិនបើបទល្មើសនោះកំពុងចោទប្រកាន់ត្រូវលុបចោលការចោទប្រកាន់នោះភ្លាម ហើយប្រសិនបើទោសដែលកំពុងអនុវត្តក៏ត្រូវបញ្ឈប់ការអនុវត្តភ្លាម ហើយបើទោសដែលមិនទាន់អនុវត្ត គឺមិនចាំបាច់អនុវត្តទៀតឡើយ[51] ពោលគឺមិនមែនជាបទល្មើសទៀតទេប្រសិនបើច្បាប់ព្រហ្មទណ្ឌថ្មីបានលុបចោលទៅហើយនេះ គឺជាការអនុវត្តគោលការណ៍ប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌដែលស្រាលជាងច្បាប់ព្រហ្មទណ្ឌចាស់ (ច្បាប់ព្រហ្មទណ្ឌអន្តរកាល) ដែលត្រូវបាននិរាករណ៍ ឬលុបចោល។ **ឧទាហរណ៍.** ថាបច្ចុប្បន្នការលេងល្បែងស៊ីសងគឺជាបទល្មើស ស្រាប់តែច្បាប់ថ្មីបានលុបចោលថាអំពើលេងល្បែងស៊ីសងមិនមែនជាបទល្មើសទៀតទេ។ ជនទាំងឡាយដែលកំពុងត្រូវបានចោទប្រកាន់អំពីអំពើនោះ ទោសកំពុងអនុវត្តនៃបទល្មើសនោះនឹងត្រូវលុបចោល ហើយដោះលែងជនដែលប្រព្រឹត្តនោះភ្លាមឱ្យមានសេរីភាព និងរួចផុតពីការចោទប្រកាន់។ លើសពីនេះប្រសិនបើច្បាប់ព្រហ្មទណ្ឌថ្មីកំណត់ទោសស្រាលជាងច្បាប់ព្រហ្មទណ្ឌអន្តរកាល គឺចៅក្រមត្រូវអនុវត្តទោសដែលបានបញ្ញត្តនៅក្នុងច្បាប់ព្រហ្មទណ្ឌថ្មីនោះភ្លាមៗ

[49] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣។

[50] មាត្រា ១០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩។

[51] មាត្រា ៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩។

ដូចគ្នា។ **ឧទាហរណ៍.** ថាបើសិនជាបទល្មើសលួចនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរកាលត្រូវមានទោសពី ៤ឆ្នាំទៅ ៥ឆ្នាំ ហើយច្បាប់ព្រហ្មទណ្ឌថ្មីបញ្ញត្តត្រឹមតែពី ៦ខែទៅ ៣ឆ្នាំ នោះគឺចៅក្រមត្រូវអនុវត្តទោសដែលបានបញ្ញត្ត នៅក្នុងច្បាប់ព្រហ្មទណ្ឌថ្មីនោះភ្លាម។

**២.២.២.១. ការអនុវត្តច្បាប់ព្រហ្មទណ្ឌដែលលុបចោលបទល្មើស**

ដូចដែលយើងបានរៀបរាប់ខ្លះៗពីខាងលើមកក៏ដូចជាបានដឹងរួចមកហើយនៅពេលដែលច្បាប់ថ្មីលុបបំបាត់នូវបទល្មើសណាមួយ នោះគេហៅថាជាច្បាប់ថ្មីស្រាលជាង។ មាត្រា ១០ បញ្ញត្តថា "បទប្បញ្ញត្តិថ្មីដែលលុបចោលបទល្មើសណាមួយនោះត្រូវអនុវត្តភ្លាម។ អំពើដែលប្រព្រឹត្តនៅមុនបទប្បញ្ញត្តិនេះចូលជាធរមាន មិនអាចត្រូវចោទប្រកាន់ទៀតឡើយ"។ ដូច្នេះប្រសិនបើការចោទប្រកាន់ទាំងឡាយពុំទាន់បានចាប់ផ្ដើមនៅឡើយទេ នោះការចោទប្រកាន់ទាំងនេះពុំត្រូវបានចាប់ផ្ដើមធ្វើឡើយ។ ប្រសិនបើការចោទប្រកាន់ទាំងនេះបានចាប់ផ្ដើមដំណើរការហើយគេត្រូវតែបញ្ចប់ភ្លាម។ គេសង្កេតឃើញនៅទីនេះថា ច្បាប់ព្រហ្មទណ្ឌថ្មីស្រាលជាងមានអានុភាពប្រតិសកម្ម ពីព្រោះថាច្បាប់នេះចូលមកអនុវត្តចំពោះអំពើទាំងឡាយដែលត្រូវបានប្រព្រឹត្តនៅមុនច្បាប់នេះចូលជាធរមាន ហើយក្នុងករណីនេះជាអំពើដែលផ្សំបង្កើតបានជាបទល្មើសព្រហ្មទណ្ឌ បើយោងតាមបទប្បញ្ញត្តិនៃច្បាប់ចាស់។ ប៉ុន្តែនៅពេលដែលនីតិនិពន្ធបានសម្រេចបញ្ញត្តិតាមរយៈច្បាប់ថ្មីមួយថាឱ្យលុបបទល្មើសនេះ ចារីទាំងឡាយដែលមិនទាន់បានជំនុំជម្រះនៅឡើយទេ ត្រូវតែអាចទទួលអត្ថប្រយោជន៍អំពីច្បាប់ថ្មីនេះ។ ចារីទាំងឡាយដែលត្រូវបានជំនុំជម្រះរួចហើយ ក៏អាចទទួលបានអត្ថប្រយោជន៍អំពីច្បាប់ថ្មីនេះផងដែរ។ តាមពិតមាត្រា ១០ បញ្ញត្តិផងដែរថា៖ ប្រសិនបើការផ្ដន្ទាទោសជាស្ថាពរត្រូវបានប្រកាសរួចមកហើយ ទោសដែលចេញអំពីការផ្ដន្ទាទោសនេះមិនត្រូវអនុវត្តទេ ឬត្រូវតែឈប់អនុវត្ត។ តាមពិតទៅជាការមិនសមហេតុផលមួយដែលថា ជនម្នាក់បន្តទទួលរងទោសដោយសារអំពើមួយដែលច្បាប់លែងចាត់ទុកជាបទល្មើសព្រហ្មទណ្ឌហើយ។ ដូច្នេះ ភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌស្រាលជាងនេះមានសារៈសំខាន់ណាស់ពីព្រោះថា វាត្រលប់មកសើរើឡើងវិញនូវការដាក់ឱ្យអនុវត្តការផ្ដន្ទាទោសស្ថាពរមួយ។

**២.២.២.២. ការអនុវត្តច្បាប់ព្រហ្មទណ្ឌស្រាលជាងដែលបញ្ញត្តអំពីទោស**

ដូចគ្នាចំពោះច្បាប់ព្រហ្មទណ្ឌស្រាលជាងដែលបញ្ញត្តអំពីបទល្មើសដែរ ដែលមានអានុភាពប្រតិសកម្ម ច្បាប់ថ្មីស្រាលជាងដែលបញ្ញត្តអំពីទោសក៏មានអានុភាពដូចគ្នានេះដែរ។ បទប្បញ្ញត្តិថ្មីទាំងឡាយដែលចែងអំពីទោសដែលស្រាលត្រូវអនុវត្តភ្លាម[52]។ នេះជាករណីដែលអំពើត្រូវបានប្រព្រឹត្តនៅក្នុងពេលដែលច្បាប់ចាស់បញ្ញត្តអំពីទោសធ្ងន់ជាងទោសដែលចែងដោយច្បាប់ថ្មីជាធរមាននៅពេលជំនុំជម្រះ។

[52] មាត្រា កម ១១១២-១ នៃសេចក្ដីព្រាងព្រហ្មទណ្ឌ ឆ្នាំ២០០៥។

**ឧទាហរណ៍.** អំពើមនុស្សឃាតដោយចេតនាមួយត្រូវបានប្រព្រឹត្តនៅថ្ងៃទី៤ មករា ២០០៥ ប៉ុន្តែច្បាប់ចែងទោសជាប់ពន្ធនាគារអស់មួយជីវិតចំពោះអំពើនេះ។ នៅថ្ងៃទី៨ មករា ២០០៥ ច្បាប់ថ្មីមួយដែលស្រាលជាងចូលជាធរមាន ដោយបន្ថយទោសពីជាប់ពន្ធនាគារអស់មួយជីវិត មកជាទោសពន្ធនាគារត្រឹម ៣០ឆ្នាំ ចំពោះអំពើមនុស្សឃាតដោយចេតនាវិញ។ តើច្បាប់មួយណាដែលចៅក្រមត្រូវយកមកអនុវត្ត នៅពេលដែលចៅក្រមត្រូវជំនុំជំម្រះនៅខែមេសា ឆ្នាំ២០០៥ ?

ប្រសិនបើគេប្រកាន់យកនូវគោលការណ៍មិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ចៅក្រមនឹងត្រូវប្រកាសផ្តន្ទាទោសជាប់ពន្ធនាគារអស់មួយជីវិត។ ប៉ុន្តែគេដឹងថាច្បាប់ព្រហ្មទណ្ឌស្រាលជាងដែលបញ្ញត្តអំពីទោសមានអានុភាពប្រតិសកម្ម ដែលជាហេតុធ្វើឱ្យចៅក្រមពុំអាចប្រកាសទោសពន្ធនាគារលើសពី ៣០ឆ្នាំបានឡើយ។ អានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌស្រាលជាងដែលបញ្ញត្តអំពីទោសនេះមានដែនកំណត់មួយ ពីព្រោះថាមាត្រា ១១ ចែងថា "ការផ្តន្ទាទោសដែលចូលជាស្ថាពរហើយនោះ ត្រូវអនុវត្តទោះបីទោសដែលប្រកាសនោះធ្ងន់ធ្ងរយ៉ាងណាក៏ដោយ"។ លើកឧទាហរណ៍ខាងលើមកពិចារណាឡើងវិញ ប្រសិនបើចារីនៃមនុស្សឃាតដោយចេតនាត្រូវបានជំនុំជម្រះនៅថ្ងៃទី៦ មករា ហើយការផ្តន្ទាទោសបានចូលជាស្ថាពរមុនពេលច្បាប់ថ្មីស្រាលជាងចូលជាធរមាន ចារីនេះត្រូវតែទទួលរងនូវទោសជាប់ពន្ធនាគារអស់មួយជីវិត ពីព្រោះថាច្បាប់ថ្មីស្រាលជាងពុំ មានអានុភាពលើការផ្តន្ទទោសស្ថាពរឡើយ។ ស្របតាមវិធានទាំងនេះអត្ថបទដដែរបានបញ្ញត្តថាបទប្បញ្ញត្តិថ្មីៗទាំងឡាយដែលចែងអំពីទោសធ្ងន់ជាងអាចយកទៅអនុវត្តបានចំពោះតែអំពើទាំងឡាយណាដែលត្រូវ បានប្រព្រឹត្តបន្ទាប់ពីបទប្បញ្ញត្តិទាំងនេះចូលជាធរមានប៉ុណ្ណោះ នេះជាវិធាននៃភាពមិនប្រតិសកម្មរបស់ច្បាប់ព្រហ្មទណ្ឌធ្ងន់ជាង ដែលតាមពិតទៅមានលក្ខណៈស្របទៅនឹងការអនុវត្តគោលការណ៍នីត្យានុកូលភាពនៃបទល្មើស និងទោស។ តាមពិតគោលការណ៍នេះក្រើនរំលឹកថា ទោសមួយអាចត្រូវបានយកទៅប្រកាសបាន លុះត្រាតែទោសនោះត្រូវបានចូលជាធរមាននៅថ្ងៃប្រព្រឹត្តអំពើ។ បដិប្បញ្ញត្តិ[53]តែមួយគត់ដែលអាចមាន គឺភាពប្រតិសកម្មជាប្រយោជន៍ដល់ចារី ដោយអនុលោមតាមច្បាប់ថ្មីស្រាលជាង។ នៅក្នុងប្រព័ន្ធច្បាប់ខ្មែរនាសម័យមុន គេពុំឃើញមានបទប្បញ្ញត្តិប្រភេទនេះទេ។ ប៉ុន្តែគេសង្កេតឃើញមានការវិវត្តមួយដែលមានលក្ខណៈអាចប្រៀបប្រដូចបានជាមួយបទប្បញ្ញត្តិនៅក្នុងបណ្តាប្រព័ន្ធគតិយុត្តអន្តរជាតិដែលទាក់ទិននឹងការសម្រាលទោសតាមរយៈបទប្បញ្ញត្តិថ្មីដែលមានគោលដៅបន្ធូរបន្ថយនូវភាពតឹងរ៉ឹងក្នុងការផ្តន្ទាទោស។ គេសង្កេតឃើញមានបទប្បញ្ញត្តិបែបនេះមានលក្ខណៈប្រហាក់ប្រហែលគ្នាដែលមានប្រភពចេញពីនីតិកម្ម

[53] នៅក្នុងវចនានុក្រមខ្មែររបស់សម្តេចសង្ឃរាជ ជួន ណាត "បដិប្បញ្ញត្តិ" មានន័យថា ការតាំងបញ្ញត្តិផ្ទុយ ឬមិនស្រប។

ជាធរមាន ពោលគឺបទប្បញ្ញត្តិនៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌ នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩២៩ និង១៩៥៥ (មាត្រា ៦) [54]។

តាមពិតគោលការណ៍ទាំងនេះ ដែលត្រូវអនុវត្តជាប្រយោជន៍ដល់ចារីនៃបទល្មើសអាចយល់បាន យ៉ាងងាយ។ ប្រសិនបើច្បាប់ចាស់ធ្ងន់ជាងត្រូវបានសំម្រាលឱ្យស្រាលនោះមានន័យថា សង្គមលែងមាន ប្រយោជន៍នឹងដាក់ទណ្ឌកម្មឱ្យធ្ងន់ដូចពីមុនទៀតហើយ ។

ក្រៅពីការវិភាគស្តីពីសណ្តាប់ធ្នាប់សង្គមនេះ ទាក់ទងនឹងអត្ថប្រយោជន៍របស់បុគ្គលជាការចម្លែកខុស ពីធម្មតាមួយដែលអនុវត្តចំពោះជនជាប់ចោទទាំងឡាយនូវទោសដែលមានលក្ខណៈធ្ងន់ជាងហើយជាការ អនុវត្តដោយគោរពតាមគោលការណ៍នៃភាពមិនប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ។ ផ្ទុយទៅវិញគោលការណ៍នេះ ត្រូវបានចែងដ៏ត្រឹមត្រូវដើម្បីការពារបុគ្គល។

អញ្ញត្រកម្មចំពោះគោលការណ៍នេះ នៅក្នុងលំដាប់គតិយុត្តជាតិ ឬអន្តរជាតិ គឺកម្រមានណាស់។ នៅប្រទេសបារាំងអាចកើតមានឡើងនូវករណីដែលនីតិនិពន្ធចែងយ៉ាងច្បាស់លាស់ថា ច្បាប់ព្រហ្មទណ្ឌថ្មីធ្ងន់ ជាងនឹងត្រូវមានអានុភាពប្រតិសកម្ម ហើយដូច្នេះត្រូវអនុវត្តចំពោះអំពើទាំងឡាយណាដែលត្រូវបានប្រព្រឹត្តមុន ពេលដែលច្បាប់នេះចូលជាធរមាន។ នេះធ្លាប់ជាករណីដែលកើតចេញពីសម័យចលាចលមួយនៅប្រទេសបារាំង ដោយសារច្បាប់ចុះថ្ងៃទី២៦ សីហា ១៩៤៤ ដែលបានបង្កើតឧក្រិដ្ឋកម្មប្រមាថជាតិដោយសហការជាមួយ ខ្មាំងសត្រូវនៅក្នុងសម័យដែលអាល្លឺម៉ង់នៅក្រោមរបបណាស៊ី។ ជាការជាក់ស្តែងដែលច្បាប់ចុះថ្ងៃទី២៦ សីហា ១៩៤៤ នេះដែលត្រូវបានប្រកាសឱ្យប្រើបន្ទាប់ពីការរំដោះប្រទេសបារាំង អាចអនុវត្តបានចំពោះតែអំពើដែល កើតមានឡើងមុនការប្រកាសឱ្យប្រើច្បាប់នេះ ដែលត្រូវបានប្រព្រឹត្តនៅក្នុងសម័យដែលស្ថិតនៅក្រោមការកាន់ កាប់របស់ប្រទេសអាល្លឺម៉ង់។ សព្វថ្ងៃនេះនីត្យានុកូលភាពនៃច្បាប់ព្រហ្មទណ្ឌធ្ងន់ជាងដែលមានអានុភាព ប្រតិសកម្មយ៉ាងច្បាស់លាស់នឹងត្រូវគេជំទាស់ខ្លាំងណាស់។

## ២.៣. ការអនុវត្តចំពោះច្បាប់ព្រហ្មទណ្ឌទម្រង់ ឬច្បាប់នីតិវិធី

នៅពេលដែលគេស្វែងរកដែនអនុវត្តន៍ច្បាប់ព្រហ្មទណ្ឌថ្មីក្នុងពេលវេលា សំណួរទីមួយដែលត្រូវ ដោះស្រាយ គឺត្រូវដឹងថាតើច្បាប់នោះជាច្បាប់នីតិវិធី (អាចនិយាយម្យ៉ាងទៀតថា ជាច្បាប់ទម្រង់) ឬជាច្បាប់គ្រឹះ។ ច្បាប់នីតិវិធី គឺជាច្បាប់ទាំងឡាយណាដែលចែងអំពីសមត្ថកិច្ចរបស់តុលាការ ស្ថាប័នតុលាការកំណត់អំពី បែបបទនៃការចោទប្រកាន់ និងដំណើរការនៃនីតិវិធី ដោយរួមទាំងផ្លូវតវ៉ា និងជាចុងក្រោយ គឺច្បាប់ដែលបញ្ញត្ត

[54] អត្ថបទ ប្រវត្តិសាស្ត្រកម្ពុជា

អំពីរបបនៃការអនុវត្តទោស។ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនេះផងដែរ គឺមានគោលបំណងកំណត់អំពីវិធាន ទាំងឡាយដែលត្រូវគោរព និងប្រព្រឹត្តតាមដោយហ្មត់ចត់ ដើម្បីកំណត់ឲ្យបានច្បាស់នូវអត្ថិភាពនៃបទល្មើស ព្រហ្មទណ្ឌណាមួយ។ បទប្បញ្ញត្តិនៃក្រមនេះត្រូវយកទៅអនុវត្តចំពោះរឿងក្តីព្រហ្មទណ្ឌផ្សេងៗទៀត កាលណា ពុំមានវិធានដោយឡែកចែងដោយច្បាប់ពិសេស។ យើងអាចនិយាយបានថាក្រមនីតិវិធីព្រហ្មទណ្ឌ គឺកំណត់ នូវវិធាន ឬដំណាក់កាលទាំងបួននៃនីតិវិធីព្រហ្មទណ្ឌដែលមានដូចជា៖ ១. ដំណាក់ស៊ើបអង្កេត (ធ្វើឡើង ដោយនគរបាលយុត្តិធម៌) ២. ដំណាក់កាលចោទប្រកាន់ (ធ្វើឡើងដោយស្ថាប័នអយ្យការ) ៣. ដំណាក់កាល ស៊ើបសួរ (ធ្វើឡើងដោយចៅក្រមស៊ើបសួរ) ៤. ដំណាក់កាលជំនុំជម្រះ (ធ្វើឡើងដោយចៅក្រមជំនុំជម្រះ)។

ចំពោះច្បាប់នីតិវិធីទាំងនេះ ជាគោលការណ៍ការអនុវត្តភ្លាមនៃបទប្បញ្ញត្តិនៃក្រមនេះ ត្រូវអនុវត្តភ្លាម ចំពោះគ្រប់កិច្ចនីតិវិធីក្រោយក្រមនេះចូលជាធរមាន។ ការអនុវត្តភ្លាមនូវបទប្បញ្ញត្តិនៃក្រមនេះ ពុំមានអានុភាព ទៅលើសុពលភាពនៃកិច្ចនីតិវិធីដែលត្រូវបានបំពេញរួចរាល់ហើយ ដោយអនុលោមតាមចាស់ឡើយ[55]។ នៅទីនេះគេបានពន្យល់យ៉ាងច្បាស់ថា កិច្ចនីតិវិធីទាំងឡាយត្រូវគោរពទៅតាមច្បាប់ជាធរមាននៅថ្ងៃដែលកិច្ច ទាំងនោះត្រូវបានបំពេញ។

លើសពីនេះទៀតបទប្បញ្ញត្តិថ្មីៗទាំងឡាយដែលចូលជាធរមាន និងនៅក្នុងករណីដែលបទប្បញ្ញត្តិ ទាំងនោះកែប្រែលក្ខខណ្ឌសុពលភាពនៃកិច្ចនីតិវិធី។ បទប្បញ្ញត្តិថ្មីទាំងនេះពុំមានអានុភាពប៉ះពាល់ដល់សុពល ភាពនៃកិច្ចដែលត្រូវបានធ្វើឡើងដោយគោរពតាមច្បាប់ចាស់នោះទេ។ ច្បាប់ព្រហ្មទណ្ឌថ្មីស្រាលជាងត្រូវអនុវត្ត ដោយគ្មានព្យសនកម្មដល់កិច្ចនីតិវិធីដែលត្រូវបានធ្វើក្រោមអានុភាពនៃច្បាប់ចាស់ឡើយ។[56]

**ឧទាហរណ៍**. ការឃាត់ខ្លួនក្នុងរយៈពេល ៤៨ម៉ោង ត្រូវបញ្ចប់នៅថ្ងៃទី៥ ខែមករា ឆ្នាំ២០០៥ នៅក្នុង ពេលដែលច្បាប់ចែងថា រយៈពេលអតិបរមា ៤៨ម៉ោងសំរាប់វិធានការនេះ។ នៅថ្ងៃទី៨ ខែមករា ឆ្នាំ២០០៥ ស្រាប់តែមានច្បាប់ថ្មីមួយចូលជាធរមាន ហើយចែងថា ការឃាត់ខ្លួនពុំអាចធ្វើឡើងលើសពីរយៈពេល ២៤ម៉ោងឡើយ។ នៅពេលបើកសវនាការដែលនឹងប្រព្រឹត្តទៅនៅខែមេសា ឆ្នាំ២០០៥ ប្រសិនបើចៅក្រម ព្រហ្មទណ្ឌពិនិត្យលើនិយតភាព[57]នៃការឃាត់ខ្លួន ចៅក្រមនឹងត្រូវយល់ថាច្បាប់ថ្មីចុះថ្ងៃទី៨ ខែមករា ឆ្នាំ ២០០៥ ពុំអាចមានអានុភាពប៉ះពាល់លើសុពលភាពនៃការឃាត់ខ្លួន ដែលត្រូវបានធ្វើឡើងដោយគោរពតាម ច្បាប់ជាធរមាននៅថ្ងៃដែលកិច្ចនីតិវិធីនេះត្រូវបានបំពេញឡើយ។ ដូច្នេះ ច្បាប់នីតិវិធីត្រូវអនុវត្តភ្លាម ប៉ុន្តែពុំមាន ឧបនិស្ស័យអនុវត្តជាប្រតិសកម្មឡើយ។

[55] មាត្រា ៦១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។
[56] មាត្រា កម ១១១២-៣ នៃសេចក្តីព្រាងព្រហ្មទណ្ឌថ្មី ឆ្នាំ២០០៥។
[57] និយតភាព គឺភាពត្រឹមត្រូវតាមច្បាប់បញ្ញត្តិ។

# ជំពូកទី ៣

# ការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា នៅក្នុងលំហ

# ជំពូកទី ៣
# ការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជានៅក្នុងលំហ

ប្រសិនបើបទល្មើសមួយត្រូវបានប្រព្រឹត្តនៅប្រទេសកម្ពុជា ដោយជនកម្ពុជាម្នាក់ប្រឆាំងនឹងជនកម្ពុជាម្នាក់ ជាការពិតឥតមន្ទិលដែលថា តុលាការព្រហ្មទណ្ឌកម្ពុជាមានសមត្ថកិច្ចដើម្បីអនុវត្តច្បាប់កម្ពុជា។ ឧទាហរណ៍ ប្រសិនបើអំពើលួចមួយត្រូវបានប្រព្រឹត្តដោយជនជាតិកម្ពុជាម្នាក់នៅប្រទេសបារាំង ហើយផលិតផលនៃអំពើលួចនេះ ត្រូវបានក្លាយជាកម្មវត្ថុនៃបទល្មើសទទួលផលចោរកម្មនៅប្រទេសវៀតណាម ដូច្នេះសំណួរត្រូវចោទថាតើច្បាប់ព្រហ្មទណ្ឌនៃប្រទេសមួយណាដែលត្រូវយកមកអនុវត្ត ហើយតើតុលាការមួយណាដែលមានសមត្ថកិច្ច។

ក្នុងការកំណត់អំពីការអនុវត្តច្បាប់ព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជានៅក្នុងលំហ ក្រមព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា ដែលចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ បានកំណត់យ៉ាងច្បាស់ដោយចែកចេញជាពីរគឺ ៣.១ ការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជានៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា និង ៣.២ បទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

## ៣.១. ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា

ជាគោលការណ៍នៅក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសទាំងឡាយដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ដែនដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវគិតរួមបញ្ចូលទាំងលំហ អាកាស និងសមុទ្រដែលមានចំណងចងភ្ជាប់នឹងដែនដីនៃព្រះរាជាណាចក្រកម្ពុជាផងដែរ[58]។ មានន័យថា អោយតែប្រព្រឹត្តបទល្មើសនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា គឺច្បាប់ព្រហ្មទណ្ឌមានអានុភាពអនុវត្តទាំងអស់ មិនថាជនជាតិអ្វីនោះទេ។

### ៣.១.១. ការអនុវត្តចំពោះបទល្មើសដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា

ច្បាប់ព្រហ្មទណ្ឌរបស់កម្ពុជាជាច្បាប់គ្រឹះមួយដែលមានអានុភាពអនុវត្តគ្រប់បទល្មើសទាំងអស់ ឲ្យតែប្រព្រឹត្តនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា ឬស្ថានភាពឯទៀតឡើយ។ យោងតាមមាត្រា ១៣ ទីកន្លែងប្រព្រឹត្តបទល្មើស ៖ បទល្មើសត្រូវបាន

58 មាត្រា ១២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩។

ចាត់ទុកថា ប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា នៅពេលដែលអំពើណាមួយនៃបទល្មើសនោះបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា[59]។

**ឧទាហរណ៍.** អាវុធមួយត្រូវបានប្រគល់ដោយជនសមគំនិត ដល់ចារីនៅលើដែនដីរបស់ព្រះរាជាណាចក្រកម្ពុជា ដើម្បីឱ្យអំពើមនុស្សឃាតដោយចេតនាមួយត្រូវបានប្រព្រឹត្តនៅទីក្រុងប៉ារីស។ មនុស្សឃាតនេះត្រូវបានប្រព្រឹត្តនៅប៉ារីស និងចារីនឹងត្រូវផ្តន្ទាទោសដោយតុលាការបារាំង។ ចំណែកជនសមគំនិតពុំបានចាកចេញពីកម្ពុជាទេ ច្បាប់កម្ពុជាមានសមត្ថកិច្ចជំនុំជម្រះជនសមគំនិតនេះចំពោះអំពើសមគំនិត ប្រព្រឹត្តអំពើមនុស្សឃាតដោយចេតនា។ យោងតាមមាត្រា ៧ លក្ខខណ្ឌនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជាបានចែងថាៈ ក្នុងរឿងព្រហ្មទណ្ឌដែនអនុវត្តក្នុងលំហត្រូវបានកំណត់ដោយបទប្បញ្ញត្តិនៃក្រមនេះ លើកលែងតែមានសន្ធិសញ្ញាអន្តរជាតិ។

### ៣.១.១.១. សញ្ញាណទូទៅនៃដែនដីនៃព្រះរាជាណាចក្រកម្ពុជា

យោងតាមមាត្រា ២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានចែងថាៈ បូរណភាពទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា មិនអាចរំលោភបានដាច់ខាតក្នុងព្រំដែនរបស់ខ្លួនដែលមានកំណត់ ក្នុងផែនទីខ្នាត ១/១០០.០០០ ធ្វើនៅចន្លោះ ឆ្នាំ១៩៣៣-១៩៥៣ ហើយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិនៅចន្លោះ ឆ្នាំ ១៩៦៣-១៩៦៩[60] ។ តើគេកំណត់ព្រំដែនគោក ដែនអាកាស និងដែនសមុទ្រយ៉ាងដូចម្តេច? ទើបដឹងថាច្បាប់ព្រហ្មទណ្ឌកម្ពុជាអាចយកទៅអនុវត្តបាន? ដូច្នេះយើងសូមធ្វើការបង្ហាញ ដូចខាងក្រោមៈ

ព្រំប្រទល់ដីគោករបស់ប្រទេសកម្ពុជា គឺមានព្រំប្រទល់ៈ ខាងជើងជាប់សាធារដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ខាងកើត និងខាងត្បូងជាប់ជាមួយ សាធារណរដ្ឋសង្គមនិយមវៀតណាម និងខាងលិចជាប់ជាមួយព្រះរាជាណាចក្រថៃ។

- ដែនអាកាស គឺជាការកំណត់មិនដាច់ខាត និងតាមជំនាញសុទ្ធសាធ គឺគេអាចធ្វើការកំណត់កំពស់លំហអាកាសរបស់រដ្ឋត្រឹមចំណុចមួយ ដែលយន្តហោះអាចហោះបាន ហើយត្រឹមចំណុចដែលយន្តហោះមិនអាចហោះបានត្រូវចាត់ទុកជាលំហអាកាសវិញ[61]។
- ដែនសមុទ្រ គឺជាលំហទឹកល្វឹងល្វើយដែលមានរហូតដល់ទៅ ៧៣% គ្របដណ្តប់លើភពផែនដី។ តំបន់ ឆ្នេរសមុទ្រកម្ពុជាដែលពោរពេញដោយភាពទាក់ទាញ គឺជាអចលទ្រព្យដែលមិនទាន់មានការអភិវឌ្ឍ ខ្លាំងក្លានៅឡើយទេ។ ឆ្នេរសមុទ្ររបស់ព្រះរាជាណាចក្រកម្ពុជាមានប្រវែង ៤៤០ គីឡូម៉ែត្រ ដែលលាត សន្ធឹងនៅតាមបណ្តោយនៃឈូងសមុទ្រថៃ ហើយរួមមានខេត្តចំនួន ៤ ដូចជាៈ

[59] មាត្រា ១៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩។

[60] មាត្រា ២ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។

[61] នីតិអន្តរជាតិសាធារណៈ លោកគ្រូ អ៊ឹម ឧត្តម។

- ខេត្តកោះកុង
- ខេត្តព្រះសីហនុ
- ខេត្តកំពត
- និងខេត្តកែប

ការកំណត់ព្រំដែនសមុទ្រដោយអនុលោមទៅតាមអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ។ អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រ បានអនុម័តនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨២ នៅទីក្រុង Montego Bay ប្រទេសJamaica។

**អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីនីតិសមុទ្រនេះបានកំណត់ដែនសមុទ្រដូចតទៅៈ**

- បន្ទាត់មូលដ្ឋាន ជាគោលការណ៍ដើម្បីកំណត់ដែនសមុទ្រ ចាំបាច់ណាស់ត្រូវតែគូសបន្ទាត់មូលដ្ឋាន។ បន្ទាត់មូលដ្ឋាន គឺជាខ្សែបន្ទាត់ទឹកនាចតាមបណ្តោយឆ្នេរ ដែលគេបង្កើតឡើងសម្រាប់វាស់តំបន់សមុទ្រ។ បន្ទាត់មូលដ្ឋានបានបែងចែកជា ២ ប្រភេទគឺបន្ទាត់មូលដ្ឋានធម្មតា និងបន្ទាត់មូលដ្ឋានត្រង់។
  - បន្ទាត់មូលដ្ឋានធម្មតា ជាបន្ទាត់ខ្សែទឹកនាចតាមបណ្តោយឆ្នេរដោយមានបញ្ជាក់នៅក្នុងផែនទី មាត្រដ្ឋានខ្នាតធំហើយទទួលស្គាល់ជាផ្លូវការដោយរដ្ឋជាប់ឆ្នេរ។
  - បន្ទាត់មូលដ្ឋានត្រង់វិញ គឺសំដៅទៅលើបន្ទាត់ដែលប្រើនៅពេលដែលឆ្នេរសមុទ្ររបស់រដ្ឋណាមួយ មានលក្ខណៈមិនត្រង់ស្មើ។ បន្ទាត់នេះត្រូវបានប្រើដើម្បីគូសភ្ជាប់ចំណុចនៅត្រង់មាត់ឆ្នេរ ឆ្នេរផត ជ្រោ កោះ រដ្ឋប្រជុំកោះ ដីដុះ ថ្មប៉ប្រះទឹក និង សមុទ្រ ព្រមទាំងឆកប្រវត្តិសាស្ត្រជាដើម។
- ដែនទឹកផ្ទៃក្នុង គឺជាតំបន់សមុទ្រដែលស្ថិតនៅផ្នែកខាងឆ្នេរសមុទ្ររបស់រដ្ឋ ហើយត្រូវរាប់បញ្ចូល ដូចជា កំពង់ផែ ឆក ពាម ដៃ សមុទ្រ។ល។ រដ្ឋជាប់ឆ្នេរមានសិទ្ធិ និងអធិបតេយ្យភាពពេញលេញក្នុងការគ្រប់គ្រងតំបន់នេះ។ នាវាបរទេសត្រូវសុំការអនុញ្ញាតពីរដ្ឋជាប់ឆ្នេរ មុននឹងឆ្លងកាត់តំបន់ដែនទឹកផ្ទៃក្នុង។ លើសពីនេះទៅទៀត រដ្ឋជាប់ឆ្នេរអាចប្រើប្រាស់នូវអំណាចយុត្តាធិការទាំងផ្នែករដ្ឋប្បវេណី និងព្រហ្មទណ្ឌទៅលើនាវាបរទេសទាំងឡាយណាដែលធ្វើនាវាចរណ៍ឆ្លងកាត់តំបន់ដែនទឹកផ្ទៃក្នុងនេះ។
- សមុទ្រដែនដី ត្រូវបានគេចាត់ទុកថាជាតំបន់នៅជាប់ដែនគោក។ សមុទ្រដែនដី ជាតំបន់សមុទ្រដែលវាស់ចេញពីបន្ទាត់មូលដ្ឋានឆ្ពោះទៅកាន់លំហសមុទ្រមានចម្ងាយ ១២ម៉ែល៍សមុទ្រ (ស្មើនឹង ២២ គីឡូម៉ែត្រ)។ នៅក្នុងតំបន់នេះរដ្ឋជាប់ឆ្នេរមានអធិបតេយ្យភាពលើដែនទឹក លំហអាកាស បាតសមុទ្រ និងដីក្រោមបាតសមុទ្រ។ អាស្រ័យហេតុនេះហើយ រដ្ឋជាប់ឆ្នេរមានសិទ្ធិទាំងស្រុងក្នុងការធ្វើអាជីវកម្ម

នៅបាតសមុទ្រ និងក្នុងដីក្រោមបាតសមុទ្រ។ ការធ្វើនាវាចរណ៍របស់នាវាបរទេស នៅក្នុងតំបន់សមុទ្រ ដែនដី គឺមានកម្រិត។

- តំបន់តភ្ជាប់ជាតំបន់សមុទ្រដែលវាស់ចេញពីបន្ទាត់មូលដ្ឋានឆ្ពោះទៅកាន់លំហសមុទ្រមានចម្ងាយ ២៤ ម៉ែល៍សមុទ្រ។ នៅក្នុងតំបន់តភ្ជាប់នេះ រដ្ឋជាប់ឆ្នេរអាចការពារការបំពានច្បាប់ និងបទប្បញ្ញត្តិស្ដីពីគយ សារពើពន្ធ អន្តោប្រវេសន៍ ឬសុខាភិបាលរបស់ខ្លួន។ ម្យ៉ាងវិញទៀត រដ្ឋជាប់ឆ្នេរក៏អាចធ្វើការដាក់ទោស ទៅលើការបំពានច្បាប់ និងបទប្បញ្ញត្តិដែលកើតឡើងនៅក្នុងតំបន់នេះបាន។ នៅក្នុងតំបន់តភ្ជាប់នេះ រដ្ឋដទៃមានសិទ្ធិក្នុងការធ្វើនាវាចរណ៍ សិទ្ធិក្នុងការហោះពីលើ ប៉ុន្តែពុំមានសិទ្ធិក្នុងការនេសាទ ការទាញយករ៉ែនោះទេ។ ចំណែកឯសិទ្ធិក្នុងការស្រាវជ្រាវវិទ្យាសាស្ត្រការដាក់ខ្សែកាបវិញ រដ្ឋដទៃត្រូវតែមានការព្រមព្រៀងពីរដ្ឋជាប់ឆ្នេរ។
- តំបន់សេដ្ឋកិច្ចផ្ដាច់មុខ ជាតំបន់សមុទ្រដែលវាស់ចេញពីបន្ទាត់មូលដ្ឋាន ហើយលាតសន្ធឹងទៅកាន់លំហសមុទ្រមានចម្ងាយ ២០០ម៉ែល៍សមុទ្រ (ស្មើនឹង ៣៧០គីឡូម៉ែត្រ)។ រដ្ឋជាប់ឆ្នេរមានសិទ្ធិពេញលេញ ក្នុងការរុករក ការធ្វើអាជីវកម្ម ការអភិរក្ស ការចាត់ចែងលើធនធានធម្មជាតិរួមមាន ទាំងធនធានធម្មជាតិមានជីវិត និងគ្មានជីវិតដែលស្ថិតនៅបាតសមុទ្រ និងដីក្រោមបាតសមុទ្រ។ រដ្ឋជាប់ឆ្នេរត្រូវគោរពសិទ្ធិ និងកាតព្វកិច្ចរបស់រដ្ឋដទៃផងដែរ នៅពេលដែលប្រើប្រាស់សិទ្ធិ និងបំពេញកាតព្វកិច្ចនៅក្នុងតំបន់សេដ្ឋកិច្ចផ្ដាច់មុខ។ នៅក្នុងតំបន់សេដ្ឋកិច្ចផ្ដាច់មុខរដ្ឋទាំងអស់ទោះជារដ្ឋជាប់ឆ្នេរក៏ដោយ ឬរដ្ឋមិនជាប់ឆ្នេរក៏ដោយ ក៏មានសេរីភាពក្នុងការធ្វើនាវាចរណ៍ ហោះពីខាងលើ ដាក់ខ្សែកាប ដាក់បំពង់បង្ហូរក្រោមសមុទ្រ ព្រមទាំងការប្រើប្រាស់ផ្សេងទៀតដែលស្របតាមច្បាប់អន្តរជាតិពាក់ព័ន្ធនឹងសេរីភាពទាំងនេះ។
- លំហសមុទ្រអន្តរជាតិ ជាតំបន់សមុទ្រដែលមិនមែនជាកម្មសិទ្ធិរបស់រដ្ឋណាមួយឡើយ។ គ្រប់បណ្ដាប្រទេសទាំងអស់នៅជុំវិញពិភពលោក មានសេរីភាពក្នុងការប្រើប្រាស់តំបន់លំហសមុទ្រអន្តរជាតិដែលមានដូចជា ការធ្វើនាវាចរណ៍ ការហោះពីលើ ការដាក់បំពង់បង្ហូរ ការដាក់ខ្សែកាប ការនេសាទ ការ ស្រាវជ្រាវវិទ្យាសាស្ត្រជាដើម។
- ខ្ពង់រាបបាតសមុទ្រ ជាដីនៅបាតសមុទ្រដែលដុះបន្តចេញពីដែនដីគោក។ យោងទៅតាមអនុសញ្ញា Montego Bay នៅឆ្នាំ១៩៨២ ស្ដីពីច្បាប់សមុទ្រ បានកំណត់តំបន់ខ្ពង់រាបបាតសមុទ្រ ថាតំបន់ខ្ពង់រាបបាតសមុទ្ររបស់បណ្ដារដ្ឋជាប់ឆ្នេររួមមាន៖ បាតសមុទ្រ និងដីក្រោមបាតសមុទ្រ ដែលស្ថិត

នៅហួសពី តំបន់សមុទ្រដែនដីរបស់រដ្ឋជាប់ឆ្នេរ ដែលជាការពន្លយចេញ នៃដែនដីគោករបស់រដ្ឋជាប់ឆ្នេរចុះទៅក្នុងទឹកសមុទ្រហូតដល់ជចោតខ្លាំងនៃបាតសមុទ្រ[62]។

យើងនិយាយបានថាទោះបីជាមានច្បាប់ម្រៅដែលកំណត់ពីព្រំដែនសមុទ្រក៏ពិតមែន ប៉ុន្តែបញ្ហាវិវាទនៅលើដែនសមុទ្រនៅតែកើតមានឡើងជៀសមិនរួចឡើយ។ ហេតុដូច្នេះទើបព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ បានកំណត់យ៉ាងច្បាស់ដោយរួមបញ្ចូលទាំងលំហអាកាស និងសមុទ្រដែលមានចំណងចងភ្ជាប់នឹងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

### ៣.១.១.២. ការអនុវត្តច្បាប់ព្រហ្មទណ្ឌចំពោះទីតាំងទូត ឬស្ថានកុងស៊ុលរបស់ព្រះរាជាណាចក្រកម្ពុជានៅឯបរទេស

មិនថាតែការកំណត់ត្រឹមទំហំដូចដែលបានចែងក្នុងមាត្រា ២ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ឬត្រឹមដែនគោក ដែនអាកាស និងដែនសមុទ្រប៉ុណ្ណោះទេ ក៏នៅមានទីកន្លែងមួយចំនួនទៀតដែលកំណត់ថាជាដែនដីនៃព្រះរាជាណាក្រកម្ពុជា ហើយច្បាប់ព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជាក៏មានអានុភាពអនុវត្តផងដែរ ដែលទីកន្លែងទាំងនោះរួមមាន ស្ថានទូត[63] ឬស្ថានកុងស៊ុល[64] របស់ព្រះរាជាណាចក្រកម្ពុជានៅឯបរទេស។ បើយើងក្រលែកទៅមើល **អនុសញ្ញាទីក្រុងវីយែនស្តីពី ទំនាក់ទំនងការទូត** ឆ្នាំ១៩៦១ (Vienna Convention on Diplomatic Relation 1961) នៃប្រការ ២២ បានកំណត់ថា៖

១. ទីតាំងនៃបេសកកម្មមិនអាចរំលោភបានឡើយ បណ្តាភ្នាក់ងារនៃរដ្ឋម្ចាស់ផ្ទះមិនអាចចូលក្នុងទីតាំងបេសកម្មរបស់ពួកគេទេ លើកលែងតែមានការយល់ព្រមពីប្រធានបេសកកម្ម។

២. រដ្ឋដែលជាម្ចាស់ផ្ទះ គឺស្ថិតនៅក្រោមកាតព្វកិច្ចពិសេសដើម្បីចាត់វិធានការសមស្របទាំងអស់ដើម្បីការពារបរិវេណនៃបេសកកម្មប្រឆាំងនឹងការឈ្លានពាន ឬការបំផ្លិចបំផ្លាញណាមួយនិងដើម្បីការពាររាល់ការរំខានដល់ សន្តិភាពនៃបេសកកម្ម ឬការចុះខ្សោយសេចក្តីថ្លៃថ្នូររបស់ខ្លួន។

៣. ទីកន្លែងនៃបេសកកម្ម គ្រឿងសង្ហារិម និងទ្រព្យសម្បត្តិផ្សេងទៀតរបស់ពួកគេ និងមធ្យោបាយនៃការដឹកជញ្ជូន បេសកកម្មនឹងមិនមានភាពស៊ាំពីការស្វែងរកភាពចាំបាច់ឯកសារភ្ជាប់ ឬការប្រតិបត្តិឡើយ[65]។

[62] អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ

[63] ស្ថានទូត ជាការិយាល័យ ឬនិវេសដ្ឋានផ្លូវការរបស់អគ្គរដ្ឋទូតនៅបរទេស

[64] ស្ថានកុងស៊ុល ជាការិយាល័យដែលបង្កើតឡើងដោយរដ្ឋមួយនៅក្នុងរាជធានី ឬទីតាំងក្រុងសំខាន់ៗរបស់រដ្ឋមួយទៀតក្នុងគោលបំណងជួយគាំទ្រ និងការពារប្រជាពលរដ្ឋរបស់គេក្នុងការធ្វើដំណើរ និងស្នាក់នៅទីនោះ

[65] ប្រការ ២២ នៃអនុសញ្ញាទីក្រុងវីយែន ស្តីពីទំនាក់ទំនងការទូតឆ្នាំ១៩៦១

ចំពោះដែនដីនៃព្រះរាជាណាចក្រកម្ពុជា មិនមែនសំដៅយកត្រឹមតែដែនដីដែលយើងបានដឹងនៅក្នុងស្ថានភាពថានៅលើទឹកដីកម្ពុជាប៉ុណ្ណោះទេ ក៏ប៉ុន្តែស្ថានទូត ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជានៅឯបរទេសក៏យើងចាត់ទុកថាគឺជាដែនដីនៃព្រះរាជាណាចក្រកម្ពុជាផងដែរ។

**៣.១.១.៣. ការអនុវត្តចំពោះអំពើដែលបានចាប់ផ្តើមប្រព្រឹត្តនៅកម្ពុជា**

ការអនុវត្តច្បាប់ព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា គឺអនុវត្តទៅលើករណីដែលមានធាតុផ្សំទាំងអស់មាននៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែមានករណីខ្លះ មិនមានធាតុផ្សំទាំងអស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាក៏ដោយ ក៏ច្បាប់ព្រហ្មទណ្ឌរបស់កម្ពុជាអាចយកទៅអនុវត្តបានដែរ ដោយចាត់ទុកថាបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាក្រកម្ពុជា។

យោងតាមមាត្រា ១៣ នៃក្រមព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០០៩ បានចែងថា៖ បទល្មើសត្រូវបានចាត់ទុកថាបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា នៅពេលដែលអំពើណាមួយនៃបទល្មើសនោះ បានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា[66]។

**៣.១.១.៤. ការកម្រិតនៃដែនដី**

ទោះបីពុំមានចែងជាក់លាក់នៅក្នុងមាត្រាណាមួយនៃក្រមព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជាក៏ដោយ ថាករណីណាខ្លះដែលច្បាប់ព្រហ្មទណ្ឌកម្ពុជាមិនអាចយកគោលការណ៍ដែនដីអនុវត្តបានក៏ពិតមែន ច្បាប់អន្តរជាតិបានទទួលស្គាល់នូវអភ័យឯកសិទ្ធិ ចំពោះឯកអគ្គរដ្ឋទូត និងភ្នាក់ងារទូត ព្រមទាំងក្រុមគ្រួសារផងដែរ។ ដោយអភ័យឯកសិទ្ធិមួយនេះគឺ ត្រូវបានទទួលស្គាល់ដោយអនុសញ្ញាទីក្រុងវីយែន ស្តីពីទំនាក់ទំនងការទូត ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៦១ (Vienna Convention on Diplomatic Relation 18 April1961) ហើយព្រះរាជាណាចក្រកម្ពុជា បានផ្តល់សច្ចាប័នលើអនុសញ្ញាទីក្រុងវីយែន នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៦៥ និងចូលជាធរមាននៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៦៥។ ដោយយើងអាចនិយាយបានថា អភ័យឯកសិទ្ធិ គឺជាមូលហេតុនៃការមិនដាក់ទោស ដោយសារតែស្ថានភាពពិសេសរបស់ចារីនៃបទល្មើសនៅពេលប្រព្រឹត្តបទល្មើសនោះ ដែលហេតុនាំឲ្យការចោទប្រកាន់ពីបទល្មើស មិនអាចធ្វើទៅបានឡើយ។ ដោយយើងអាចនិយាយបានថា អភ័យឯកសិទ្ធិមួយនេះ គឺទទួលបានមកពីរដ្ឋដែលជាម្ចាស់ផ្ទះ។

ដោយយោងតាមប្រការ ២៩ នៃអនុសញ្ញាទីក្រុងវីយែនស្តីពី ទំនាក់ទំនងការទូត បានចែងថា៖ បុគ្គលនៃភ្នាក់ងារទូតមិនអាចរំលោភបំពានបានឡើយ។ ភ្នាក់ងារទូតមិនទទួលខុសត្រូវចំពោះទម្រង់នៃការចាប់ខ្លួន ឬ

[66] មាត្រា ១៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩។

ការឃុំខ្លួនណាមួយឡើយ។ រដ្ឋដែលទទួលបានត្រូវគោរពភ្នាក់ងារទូត និងចាត់វិធានការសមស្របទាំងឡាយដើម្បីការពារការវាយប្រហាររបស់ខ្លួនទៅលើ សេរីភាព ឬសេចក្តីថ្លៃថ្នូររបស់ភ្នាក់ងារទូត [67]។

ភ្នាក់ងារការទូត គឺជាប្រធានបេសកកម្ម ឬជាសមាជិកបុគ្គលិកការទូតនៃបេសកកម្ម[68]។

មួយវិញទៀតប្រការ ៣៧ នៃអនុសញ្ញាទីក្រុងវីយែន ស្តីពីទំនាក់ទំនងការទូត បានចែងថា៖

១. សមាជិកគ្រួសារនៃភ្នាក់ងារការទូតដែលបង្កើតជាចំណែកនៃគ្រួសាររបស់គាត់ប្រសិនបើពួកគេមិនមែនជាសញ្ជាតិ នៃរដ្ឋទទួលបានសិទ្ធិ និងអភ័យឯកសិទ្ធិដែលមានចែងក្នុងមាត្រា ២៩ ដល់ ៣៦ ។

២. សមាជិកនៃបុគ្គលិករដ្ឋបាល និងបច្ចេកទេសនៃបេសកកម្មរួមជាមួយសមាជិក នៃក្រុមគ្រួសាររបស់ពួកគេ ដែលបង្កើតជាចំណែកនៃគ្រួសាររៀងៗខ្លួនប្រសិនបើពួកគេមិនមែនជាសញ្ជាតិ ឬមានទីលំនៅជាអចិន្ត្រៃយ៍នៅក្នុងរដ្ឋទទួលបានសិទ្ធិ និងអភ័យឯកសិទ្ធិដែលមានចែងក្នុងមាត្រា ២៩ ដល់ ៣៥ លើកលែងតែអភ័យឯកសិទ្ធិ និងយុត្តាធិការរដ្ឋបាលនៃរដ្ឋទទួល ដែលមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រា ៣១ មិនត្រូវលាតត្រដាងនូវសកម្មភាពដែលបានធ្វើនៅក្រៅមុខងាររបស់ខ្លួនឡើយ ពួកគេក៏នឹងទទួលបានឯកសិទ្ធិដូចមានចែងក្នុងមាត្រា ៣៦ កថាខណ្ឌទី១ ទាក់ទងនឹងមាត្រាដែលបាននាំចូលនៅពេលដំឡើងដំបូង។

៣. សមាជិកនៃបុគ្គលិកសេវាកម្មនៃបេសកកម្ម ដែលមិនមែនជាសញ្ជាតិ ឬមានទីលំនៅជាអចិន្ត្រៃយ៍នៅក្នុងរដ្ឋ ដែលទទួលបាននឹងមានអភ័យឯកសិទ្ធិ ទាក់ទងនឹងសកម្មភាពដែលបានអនុវត្តក្នុងពេលបំពេញភារកិច្ចរបស់ពួកគេលើកលែងពន្ធ និងអាករលើវិមាន ដែលពួកគេទទួលដោយហេតុផលការងារ និងការលើកលែងរបស់ពួកគេមានចែងក្នុងមាត្រា ៣៣ ។

៤. ការងារក្នុងន័យផ្សេងទៀតពួកគេអាចទទួលបានសិទ្ធិ និងអភ័យឯកសិទ្ធិតែក្នុងកម្រិតដែលទទួលបានដោយរដ្ឋ។ ទោះយ៉ាងណាក៏ដោយ រដ្ឋដែលទទួលបានត្រូវតែអនុវត្តយុត្តាធិការរបស់ខ្លួនលើមនុស្សទាំងនោះក្នុងលក្ខណៈមួយដែលមិនធ្វើឱ្យរំខានដល់ការអនុវត្តមុខងាររបស់បេសកកម្ម[69]។ មាត្រាមួយនេះបានបញ្ជាក់យ៉ាងច្បាស់ គឺលើកលែងតែពលរដ្ឋដែលជាម្ចាស់នៃរដ្ឋនោះ គឺមិនអាចទទួលបានអភ័យឯកសិទ្ធិឡើយ ដោយហេតុថា ពលរដ្ឋដែលមានសញ្ជាតិនៅរដ្ឋនោះ គឺត្រូវស្ថិតក្រោមច្បាប់របស់ប្រទេសនោះ។

ឧទាហរណ៍៖ មាននារីម្នាក់ជាជនជាតិខ្មែរបានរៀបអាពាហ៍ពិពាហ៍ជាមួយនឹងភ្នាក់ងារទូតប្រទេសបារាំង នៅឯប្រទេសថៃ គឺប្រាកដណាស់នារីដែលជាជនជាតិខ្មែរនោះនឹងទទួលបានអភ័យឯកសិទ្ធិដូចមានចែងក្នុងមាត្រា ៣៧ ខាងលើតែប្រសិនបើនារីជនជាតិខ្មែរមានសញ្ជាតិថៃផងនោះ គឺមិនទទួលបាន

[67] ប្រការ ២៩ នៃអនុសញ្ញាទីក្រុងវីយែន ស្តីពីទំនាក់ទំនងការទូត ឆ្នាំ១៩៦១។

[68] ប្រការ ១ ចំណុច (ង) នៃអនុសញ្ញាទីក្រុងវីយែន ស្តីពីទំនាក់ទំនងការទូត ឆ្នាំ១៩៦១។

[69] ប្រការ ៣៧ នៃអនុសញ្ញាទីក្រុងវីយែន ស្តីពីទំនាក់ទំនងការទូត ឆ្នាំ១៩៦១។

អភ័យឯកសិទ្ធិឡើយ ដោយហេតុថា ជនណាដែលមានសញ្ជាតិនៃរដ្ឋណាមួយ គឺត្រូវស្ថិតក្រោមច្បាប់ប្រទេស ឬរដ្ឋមួយនោះ។

### ៣.១.២. ការមិនអនុវត្តច្បាប់ព្រហ្មទណ្ឌនៅលើដែនដីកម្ពុជាតាមកិច្ចព្រមព្រៀងអន្តរជាតិ

ដូចទៅនឹងចំណុចការអនុវត្តច្បាប់ព្រហ្មទណ្ឌចំពោះទីតាំងទូត ឬស្ថានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជានៅរដ្ឋបរទេសដែរ ទោះបីជាមានការកំណត់អំពីដែនដីនៃព្រះរាជាណាចក្រកម្ពុជាក៏ដោយ ក៏មានទីកន្លែងមួយចំនួននៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលក្រមព្រហ្មទណ្ឌមិនអាចយកទៅអនុវត្តចំពោះបទល្មើសដែលបានកើតឡើងនៅទីតាំងនោះ។ ដោយសារតែកម្ពុជា បានផ្តល់សច្ចាប័នលើអនុសញ្ញាទីក្រុងវីយែន ចុះថ្ងៃទី ១៨ ខែមេសា ឆ្នាំ១៩៦១ ស្តីអំពីទំនាក់ទំនងការទូត និងបានចូលជាធរមាននៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៦៥។ ដូច្នេះ រាល់បទល្មើសព្រហ្មទណ្ឌ ទាំងឡាយណាដែលបានប្រព្រឹត្តនៅក្នុងទីតាំងស្ថានទូត ឬស្ថានកុងស៊ុលរបស់រដ្ឋណាមួយក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា តុលាការកម្ពុជាគឺមិនមានសមត្ថកិច្ចឡើយ[70] លើកលែងតែក្នុងករណី ដែលបទល្មើសដែលបានប្រព្រឹត្តនោះមានពលរដ្ឋខ្មែរជាជនល្មើស ឬជាជនរងគ្រោះ។

ទីស្ថានបេសកកម្មគឺសំដៅដល់ដីធ្លី និងអគារដែលសម្រាប់បម្រើការដល់បេសកកម្មការទូត ដោយរាប់បញ្ចូលទាំងនិវេសនដ្ឋានរបស់ប្រមុខការទូតនោះផងដែរ។

ជាគោលការណ៍ ភ្នាក់ងារអាជ្ញាធររបស់រដ្ឋម្ចាស់ផ្ទះត្រូវហាមឃាត់ មិនអាចឱ្យចូលទៅក្នុងទីស្ថានបេសកកម្មនេះបានទេ ប៉ុន្តែក្នុងករណីខ្លះភ្នាក់ងាររដ្ឋម្ចាស់ផ្ទះត្រូវបង្ខំចិត្តរំលោភលើអភ័យឯកសិទ្ធិនៃស្ថានបេសកកម្មនេះ ដើម្បីដោះស្រាយស្ថានការណ៍ទាល់ច្រកណាមួយ (ឧទាហរណ៍ដូច ជាករណីវិបត្តិចំណាប់ខ្មាំងក្នុងស្ថានទូតជប៉ុន ប្រចាំនៅក្រុងលីម៉ា នៃប្រទេសប៉េរ៉ូ នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៦ ស្ថានទូតជប៉ុនប្រចាំក្រុងលីម៉ា នៃប្រទេសប៉េរូ បានរៀបចំពិធីជប់លៀងមួយនៅក្នុងនិវេសនដ្ឋានលោកឯកអគ្គរាជទូតជប៉ុន Morihisa Aoki ដើម្បីអបអរសាទបុណ្យខួបកំណើតព្រះចៅអធិរាជជប៉ុន។ ស្ថានទូតបានអញ្ជើញឯកអគ្គរដ្ឋទូតនានា និងមន្ត្រីជាន់ខ្ពស់ជាច្រើនរូបទៀតរបស់ប៉េរូ ប្រមាណ ៦០០នាក់ មកចូលរួមក្នុងពិធីនោះដែរ។

ក្នុងពិធីជប់លាងនោះ ពួកឧទ្ទាមចលនាបដិវត្ត Tupac Amuru បានបន្លំខ្លួនចូល ធ្វើជាអ្នកបម្រើព្រមទាំងបានផ្ទុះអាវុធ និងចាប់អ្នកចូលរួមទាំងអស់ក្នុងកម្មវិធីនោះជាចំណាប់ខ្មាំង។ ក្រុមឧទ្ទាមបានទាមទារឱ្យដោះលែងមេដឹកនាំរបស់គេដែលកំពុងជាប់ពន្ធនាគារជាថ្នូរនឹងការដោះលែងចំណាប់ខ្មាំងទាំងនោះ។ ការចរចារ

[70] មាត្រា ២២ នៃសន្ធិសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៦៣ ស្តីពីទំនាក់ទំនងការទូត។

រយៈពេល ៣ខែរវាងក្រុមឧទ្ទាម និងរដ្ឋាភិបាលប៉េរូដើម្បីស្វែងរកដំណោះស្រាយ ប៉ុន្តែត្រូវបរាជ័យដោយរដ្ឋាភិបាលប៉េរូបដិសេធមិនអាចធ្វើតាមការទាមទាររបស់ពួកឧទ្ទាមនោះបាន។

ការចរចារដ៏វែងអន្លាយនេះ បានផ្តល់ឱកាសឱ្យកងទ័ពប៉េរូ ជីករូងសម្ងាត់ក្រោមដីមួយ សម្រាប់ចូលទៅដល់ក្រោមអគារនិវេសនដ្ឋាននោះតែម្តង។ នៅថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៩៧ ( យុទ្ធនាការរំដោះចំណាប់ខ្មាំងបានមកដល់កងទ័ពពិសេសប៉េរូបានចូលតាមរូងក្រោមដីទៅកំទេចក្រុមឧទ្ទាម ហើយបានរំដោះចំណាប់ខ្មាំងប្រកបដោយភាពជោគជ័យ។

ព្រឹត្តិការណ៍រំដោះចំណាប់ចំណាប់ខ្មាំង ដឹកនាំដោយប្រធានាធិបតីប៉េរូ Alberto Fujimuri នេះ ត្រូវបានសកលលោកជាពិសេសសាធារណជប៉ុនបានអបអរសាទរយ៉ាងខ្លាំង។ លោកនាយករដ្ឋមន្ត្រីជប៉ុន Ryutaro Hashimoto បានចេញដំណើរជាបន្ទាន់ពីទីក្រុងតូក្យូទៅកាន់ទីក្រុងលីម៉ា ដើម្បីសំដែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះប្រទេសប៉េរូ ក្នុងការបញ្ចប់វិបត្តិចំណាប់ខ្មាំងដ៏ស្មុគស្មាញទោះបីជាការចូលទៅរំដោះចំណាប់ខ្មាំង បែបនេះអាចចាត់ទុកជាការរំលោភអភ័យឯកសិទ្ធិ នៃស្ថានបេសកកម្មការទូតរបស់ជប៉ុនក៏ដោយ។ ព្រោះដើម្បីរក្សាការសម្ងាត់នៃផែនការរំដោះនេះកុំឱ្យខូចខ្វាយប្រទេសប៉េរូពុំបានផ្តល់ដំណឹងពីការជីករូងក្រោមដី ឬក៏បានសុំការអនុញ្ញាតពីភាគីជប៉ុន ជាមុនដើម្បីចូលទៅរំដោះចំណាប់ខ្មាំងក្នុងនិវេសនដ្ឋាននោះឡើយ។

ក្រៅពីការហាមឃាត់ ពុំអនុញ្ញាតឱ្យភ្នាក់ងាររបស់រដ្ឋម្ចាស់ផ្ទះចូលទៅក្នុងទីស្ថានទូតដោយគ្មានការយល់ព្រមពីស្ថានបេសកកម្មនោះ រដ្ឋម្ចាស់ផ្ទះមានកាតព្វកិច្ចពិសេសមួយទៀតគឺការពារទីស្ថានបេសកកម្មការទូតពីអំពើរុកគួនរំខានពីខាងក្រៅ ដូចជាការរារាំងមិនឱ្យបុគ្គលណាមួយចូលទៅក្នុងស្ថានបេសកកម្មដោយគ្មានការអនុញ្ញាត ឬការពារកុំឱ្យមានការចោលគ្រឿងផ្ទុះទៅក្នុងទីស្ថាននោះ។

### ៣.១.៣. ការចាត់ទុកថាជាដែនដីនៃព្រះរាជាណាចក្រកម្ពុជា

យើងបាននិយាយនៅក្នុងចំណុចខាងលើ ច្បាប់ព្រហ្មទណ្ឌត្រូវយកមកអនុវត្តផងដែរ ចំពោះទីកន្លែងមួយចំនួន ដែលត្រូវបានចាត់ទុកថាជាដែនដីនៃព្រះរាជាណាចក្រកម្ពុជានៅពេលមានបទល្មើសបានកើតឡើង។ បទល្មើសមួយចំនួនអាចប្រព្រឹត្តមិនមែននៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាទាំងស្រុងនោះទេ ប៉ុន្តែច្បាប់ព្រហ្មទណ្ឌរបស់កម្ពុជាយើងបានចាត់ទុកថាបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជារបស់យើងផងដែរ នៅក្នុងនោះច្បាប់កម្ពុជាយើងបានចែងកំណត់ថាជាប្រភេទបទល្មើសដែលចាត់ទុកថាបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា[71]។

[71] ប្រសាសន៍របស់ ឯកឧត្តម កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

### ៣.១.៣.១. បទល្មើសដែលប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើគ្រប់បទល្មើសក្នុងបុគ្គលជាជនល្មើសទាំងអស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា លើកលែងតែមានសន្ធិសញ្ញាអន្តរជាតិបញ្ញត្តខុសពីនេះ។

"ដែនដី" សំដៅដល់ដែនដីដែលស្ថិតនៅក្រោមអធិបតេយ្យភាពនៃព្រះរាជាណាចក្រកម្ពុជា ដោយរួមបញ្ចូលទាំងលំហអាកាស និងសមុទ្រ ។

ការអនុវត្តបទល្មើសដែលប្រព្រឹត្តលើដែនដីកម្ពុជា សំដៅដល់គ្រប់ធាតុផ្សំនៃបទល្មើសទាំងអស់ដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ហើយជនល្មើសក៏ប្រព្រឹត្តបទល្មើសលើទឹកដីកម្ពុជាដែរ។

### ៣.១.៣.២. បទល្មើសដែលចាត់ទុកថាបានប្រព្រឹត្តនៅកម្ពុជា

ដូចដែលបានដឹងហើយថាគោលការណ៍ដែនដីនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា គឺសំដៅលើករណីដែលធាតុផ្សំទាំងអស់មាននៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែក៏មានករណីផ្សេងទៀតដែលច្បាប់ព្រហ្មទណ្ឌកម្ពុជា អាចយកទៅអនុវត្តបានបើទោះបីជាបទល្មើសនោះមិនមានធាតុផ្សំទាំងអស់នៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាក៏ដោយ។ មាត្រា ១៣ នៃក្រមព្រហ្មទណ្ឌកម្ពុជាបានបញ្ញត្តិថា « បទល្មើសត្រូវបានចាត់ថាប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា នៅពេលដែលអំពើណាមួយនៃបទល្មើសនោះបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា » មានន័យថា បើទោះបីជាមិនមានធាតុផ្សំទាំងអស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាក៏ដោយ ក៏ច្បាប់ព្រហ្មទណ្ឌកម្ពុជាអាចយកទៅអនុវត្តបានផងដែរ ប្រសិនបើមានធាតុផ្សំណាមួយកើតមាននៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ឧទាហរណ៍៖ ករណីមានអំពើចាប់ជំរិតមួយបានកើតឡើងនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែការប្រគល់ប្រាក់គឺបានធ្វើឡើងនៅលើដែនដីនៃរដ្ឋបរទេសណាមួយ ដូច្នេះបើទោះបីជាមិនមានធាតុផ្សំទាំងអស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាក៏ច្បាប់ព្រហ្មទណ្ឌកម្ពុជានៅតែមានអានុភាពអនុវត្តបានដែរ។

បទល្មើសដែលចាត់ទុកថាបានប្រព្រឹត្តនៅកម្ពុជា រួមបញ្ចូលទាំងអំពើផ្តើមគំនិត ឬសមគំនិតដែលត្រូវបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា តាមបញ្ញត្តិនៃមាត្រា ១៧ ក្នុងក្រមនេះ ប៉ុន្តែសម្រាប់អំពើទាំងពីរនេះ គឺអនុវត្តចំពោះតែបទល្មើសជាបទឧក្រិដ្ឋ និងមជ្ឈិមតែប៉ុណ្ណោះហើយក៏ត្រូវមានលក្ខខណ្ឌពីរដែលត្រូវបំពេញផងដែរ លក្ខខណ្ឌទាំងនោះមានដូចជា៖

- បទល្មើសត្រូវបានផ្តន្ទាទោសតាមច្បាប់កម្ពុជាផង និងច្បាប់បរទេសផង
- អត្ថិភាពនៃបទល្មើសត្រូវបានបញ្ជាក់ដោយសេចក្តីសម្រេចស្ថាពររបស់តុលាការបរទេស[72]។

[72] មាត្រា ១៧ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩។

ករណីមួយទៀតអំពីទំហំផ្ទៃដី ដែនសមុទ្រ ឬដែនអាកាសដែលច្បាប់ព្រហ្មទណ្ឌរបស់កម្ពុជាមានវិសាលភាពអនុវត្តលើទំហំផ្ទៃដី ដែនសមុទ្រ ក៏នៅមានទីកន្លែងមួយចំនួនត្រូវចាត់ទុកថាបានប្រព្រឹត្តនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។

តាមក្រមព្រហ្មទណ្ឌ បទល្មើសដែលត្រូវបានចាត់ទុកថាប្រព្រឹត្តនៅលើដែនដី នៃព្រះរាជាណាចក្រកម្ពុជា កាលបើបទល្មើសនោះត្រូវបានប្រព្រឹត្តៈ

- នៅក្នុងនាវាដែលមានសញ្ជាតិកម្ពុជាទោះបីជានាវានោះស្ថិតនៅទីណាក៏ដោយ[73]
- នៅក្នុងអាកាសយានមានសញ្ជាតិកម្ពុជាទោះបីជានាវានោះស្ថិតនៅទីណាក៏ដោយ [74]

ក្រៅតែពីចំណុចទាំងពីរខាងលើនេះ ក្រមព្រហ្មទណ្ឌកម្ពុជាក៏បានប្រគល់សមត្ថកិច្ចឱ្យតុលាការកម្ពុជាបន្ថែមទៀតចំពោះបទល្មើសដែលបានកើតឡើងនៅក្នុងនាវាបរទេស ហើយដែលអាជ្ញាធរកម្ពុជាបានទទួលការអនុញ្ញាតឱ្យពិនិត្យមើល ឬចាប់តាមអំណាចនៃកិច្ចព្រមព្រៀងអន្តរជាតិ[75]។

**ក. បទល្មើសដែលប្រព្រឹត្តក្នុងនាវាកម្ពុជា**

យោងតាមមាត្រា ១៤ បទល្មើសដែលបានប្រព្រឹត្ត នៅក្នុងនាវាកម្ពុជាៈ ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងនាវាដែលមានសញ្ជាតិខ្មែរ ទោះបីជានាវានោះស្ថិតនៅទីណាក៏ដោយ [76]។ ពាក្យថានាវា មានន័យថានាវាប្រភេទណាក៏ដោយ ទោះបីមិនស្ថិតជាប់អចិន្ត្រៃយ៍ទៅនឹងសមុទ្ររាប់បញ្ចូលទាំងនាវាដើរដោយកម្លាំងថាមពល នាវាមុជទឹក ឬនាវាបណ្តែតទឹកផ្សេងៗទៀត [77] ឲ្យតែមានសញ្ជាតិខ្មែរ ឬមានទង់សម្គាល់ទង់ជាតិខ្មែរកំណត់សម្គាល់នាវាដែលមានសញ្ជាតិខ្មែរ គឺជានាវាដែលបានចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ទោះបីជានាវានោះស្ថិតនៅទីណាក៏ដោយប្រសិនបើមានការប្រព្រឹត្តបទល្មើសនៅលើនាវា គឺច្បាប់ព្រហ្មទណ្ឌត្រូវបានយកទៅអនុវត្ត។

**ខ.បទល្មើសដែលប្រព្រឹត្តក្នុងនាវាបរទេស**

យោងតាមមាត្រា ១៥ បទល្មើសដែលបានប្រព្រឹត្តនៅក្នុងនាវាបរទេសៈ ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងនាវាបរទេស ដែលអាជ្ញាធរកម្ពុជាបានទទួលការអនុញ្ញាតឱ្យពិនិត្យមើល ឬឱ្យចាប់នាវាតាមអំណាចនៃកិច្ចព្រមព្រៀងអន្តរជាតិ គឺសំដៅដល់ការព្រមព្រៀង

[73] មាត្រា ១៤ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩។

[74] មាត្រា ១៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩។

[75] មាត្រា ១៥ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩។

[76] មាត្រា ១៤ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩។

[77] មាត្រា ១ នៃច្បាប់ស្តីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃអនុសញ្ញា ស្តីពីការបង្ក្រាបអំពើខុសច្បាប់ទៅ នឹងសុវត្ថិភាពការធ្វើនាវាចរណ៍តាមដែនសមុទ្រ ឆ្នាំ២០០៥។

អនុញ្ញាតឲ្យអាជ្ញាធរកម្ពុជាពិនិត្យមើល ឬចាប់នាវានោះ។ មានន័យថាជាប្រភេទបទល្មើសដែលបានប្រព្រឹត្តនៅក្នុងនាវាបរទេស ប៉ុន្តែតាមអានុភាពនៃកិច្ចព្រមព្រៀងអន្តរជាតិ ឬសន្ធិសញ្ញាអន្តរជាតិ ឬអនុសញ្ញាអន្តរជាតិនោះ យើងអាចមានសិទ្ធិចូលទៅពិនិត្យមើល ឬត្រូវបានគេស្នើសុំឲ្យជួយអន្តរាគមន៍ដើម្បីទៅពិនិត្យមើលនៅក្នុងស្ថានភាពនោះ។ ករណីប្រសិនបើមានបទល្មើសកើតឡើងនោះប្រាកដណាស់បទល្មើសនោះ គឺស្ថិតនៅក្រោមសមត្ថកិច្ចនៃច្បាប់ព្រហ្មទណ្ឌរបស់ប្រទេសកម្ពុជា។ ច្បាប់ព្រហ្មទណ្ឌរបស់កម្ពុជាគឺមានអានុភាពអនុវត្តទៅលើករណីនោះទោះបីជានាវាបរទេសក៏ដោយ[78]។

ជាក់ស្តែង**មាត្រា ២៧ នៃអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ** បានចែងថា៖

យុត្តាធិការព្រហ្មទណ្ឌលើនាវាបរទេស

១. យុត្តាធិការព្រហ្មទណ្ឌរបស់រដ្ឋជាប់ឆ្នេរសមុទ្រមិនគួរយកមកប្រើប្រាស់លើនាវាបរទេសដែលឆ្លងកាត់ដែនសមុទ្រដើម្បីចាប់ខ្លួនជនណាម្នាក់ ឬធ្វើការស៊ើបអង្កេតលើបទល្មើសដែលបានប្រព្រឹត្តលើនាវាក្នុងអំឡុងពេលឆ្លងកាត់ឡើយលើកលែងតែករណីដូចខាងក្រោម៖

ក. ប្រសិនបើផលវិបាកនៃបទល្មើសបន្តប៉ះពាល់ដល់រដ្ឋជាប់ឆ្នេរសមុទ្រ។

ខ. ប្រសិនបើបទល្មើសជាប្រភេទបទល្មើសមួយដែលរំខានសន្តិភាពរបស់ប្រទេស ឬសណ្តាប់ធ្នាប់ល្អនៃដែនសមុទ្រ។

គ. ប្រសិនបើមានការស្នើសុំជំនួយពីអាជ្ញាធរមូលដ្ឋានពីសំណាក់ម្ចាស់នាវា ឬភ្នាក់ងារការទូត ឬមន្ត្រីកុងស៊ុលរបស់រដ្ឋមានទង់ជាតិលើនាវា។ ឬ

ឃ. ប្រសិនបើវិធានការនោះចាំបាច់ ដើម្បីបង្ក្រាបការជួញដូរថ្នាំណាកូទិន ឬសាធាតុប៉ះពាល់ផ្លូវចិត្តខុសច្បាប់។

២. បញ្ញត្តខាងលើមិនប៉ះពាល់សិទ្ធិរបស់រដ្ឋជាប់ឆ្នេរសមុទ្រក្នុងការចាត់វិធានការណាមួយដែលអនុញ្ញាតដោយច្បាប់របស់ខ្លួនក្នុងគោលបំណងចាប់ខ្លួន ឬស៊ើបអង្កេតលើនាវាដែលឆ្លងកាត់ដែនសមុទ្ររបស់ខ្លួនបន្ទាប់ពីនាវាចាកចេញពីផ្ទៃទឹកក្នុង។

៣. ក្នុងករណីដែលចែងក្នុងកថាខណ្ឌទី១ និងទី២ ប្រសិនបើប្រធាននាវាស្នើសុំរដ្ឋជាប់ឆ្នេរត្រូវជូនដំណឹងភ្នាក់ងារទូត ឬមន្ត្រីកុងស៊ុលនៃរដ្ឋដែលមានទង់ជាតិលើនាវាមុនពេលចាត់វិធានការណាមួយ និងត្រូវសម្រួលទំនាក់ទំនងរវាងភ្នាក់ងារការទូត ឬមន្ត្រីកុងស៊ុលនោះជាមួយនឹងនាវិក។

[78] ប្រសាសន៍របស់ ឯកឧត្តម កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

៤. ក្នុងការពិចារណាថាតើគួរធ្វើការចាប់ខ្លួនឬយ៉ាងណា ឬរបៀបណាអាជ្ញាធរមូលដ្ឋានត្រូវគិតពីផលប្រយោជន៍នៃការធ្វើនាវាចរណ៍។

៥. លើកលែងតែមានចែងក្នុងភាគទី១២ ឬទាក់ទងនឹងការល្មើសច្បាប់ និងបទបញ្ញត្តិដែលអនុម័តអនុលោមតាមភាគីទី៥ រដ្ឋជាប់ឆ្នេរមិនអាចចាត់វិធានការណាមួយលើនាវាបរទេសដែលឆ្លងកាត់ដែនសមុទ្រដើម្បីចាប់ខ្លួនមនុស្សណាម្នាក់ ឬធ្វើការស៊ើបអង្កេតលើបទល្មើសដែលបានប្រព្រឹត្តមុនពេលនាវាចូលក្នុងដែនសមុទ្ររបស់ខ្លួនប្រសិនបើនាវានោះដែរធ្វើដំណើរពីកំពុងផែបរទេស គ្រាន់តែឆ្លងកាត់ដែនសមុទ្រមិនបានចូលក្នុងដែនទឹកខាងក្នុងទេ។

**គ. បទល្មើសដែលបានប្រព្រឹត្តនៅក្នុងអាកាសយានកម្ពុជា**

យោងតាមមាត្រា ១៦ បទល្មើសដែលបានប្រព្រឹត្តនៅក្នុងអាកាសយានកម្ពុជា៖ ក្នុងរឿងព្រហ្មទណ្ឌច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងអាកាសយានដែលចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជាទោះបីជាអាកាសយាននោះស្ថិតនៅទីណាក៏ដោយ[79]។ គឺសំដៅដល់អាកាសយានទាំងឡាយណាដែលមានសញ្ជាតិខ្មែរ កំណត់សម្គាល់អាកាសយានដែលមានសញ្ជាតិខ្មែរ គឺសំដៅដល់អាកាសយានដែលបានចុះបញ្ជីការនៅកម្ពុជា ទោះបីជាអាកាសយាននោះទៅដល់ទីណាក៏ច្បាប់ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាអាចយកទៅអនុវត្តបានគ្រប់ទីកន្លែង ដែលអាកាសយាននោះស្ថិតនៅ។ អាកាសយានដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា និងមានសញ្ជាតិខ្មែរ ហើយក្នុងរយៈពេលដែលការចុះបញ្ជីនោះនៅមានសុពលភាពអាកាសយាននោះពុំមានសិទ្ធិចុះបញ្ជីនៅរដ្ឋណាមួយផ្សេងទៀតបានទេ។ ហើយអាកាសយានដែលបានចុះបញ្ជីនៅរដ្ឋណាមួយរួចហើយ ពុំមានសិទ្ធិចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជាបានទេ ក្នុងរយៈពេលដែលនៅក្នុងរដ្ឋផ្សេងនោះមានសុពលភាពនៅឡើយ[80]។

យោងតាម **មាត្រា ៤៧ ច្បាប់ស្តីពី អាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា** បានចែងថា៖ ត្រូវចាត់ទុកថាជាអ្នកប្រព្រឹត្តឧក្រិដ្ឋកម្ម ជនណាដែលស្ថិតនៅលើអាកាសយានកំពុងហោះហើរ បានប្រព្រឹត្តអំពើណាមួយដូចខាងក្រោម៖

- ការចាប់ពង្រត់អាកាសយានដោយប្រើកម្លាំង
- ការគំរាមកំហែង ការបំភិតបំភ័យ ការដណ្តើមកាន់កាប់ត្រួតត្រាអាកាសយាន ឬការរឹបអូស

[79] មាត្រា ១៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩។

[80] មាត្រ ៦ នៃច្បាប់ស្តីពី អាកាសចរស៊ីវិល។

o ការប៉ុនប៉ងប្រព្រឹត្តអំពើខាងលើអ្នកចូលរួមប្រព្រឹត្ត និងអ្នកសមគំនិតជាមួយដើម្បីប្រព្រឹត្តអំពើខាងលើត្រូវចាត់ទុកជាអ្នកប្រព្រឹត្តឧក្រិដ្ឋកម្មដែរ[81]។

## ៣.២. បទល្មើសដែលប្រព្រឹត្តក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា

បទល្មើសព្រហ្មទណ្ឌមួយត្រូវបានប្រព្រឹត្តនៅលើដែនដីនៃប្រទេសកម្ពុជា ដោយជនមានសញ្ជាតិកម្ពុជាម្នាក់ទៅលើជនកម្ពុជាណាម្នាក់ទៀតជាការពិតឥតមន្ទិលដែលថាតុលាការព្រហ្មទណ្ឌកម្ពុជាមានសមត្ថកិច្ចលើករណីបទល្មើសដែលបានប្រព្រឹត្តនោះ។

ក្រៅពីអំពីបញ្ហាអនុវត្តច្បាប់ព្រហ្មទណ្ឌទៅលើបទល្មើសដែលបានប្រព្រឹត្តនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាក៏បានចែងអំពីសមត្ថកិច្ច ឬអានុភាពអនុវត្តច្បាប់ព្រហ្មទណ្ឌទៅលើបទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជាផងដែរ។

### ៣.២.១. ការអនុវត្តច្បាប់ព្រហ្មទណ្ឌតាមគោលការណ៍សញ្ជាតិ

#### ៣.២.១.១. បទល្មើសដែលមានជនល្មើសជាពលរដ្ឋខ្មែរ

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើគ្រប់បទឧក្រិដ្ឋដែលប្រព្រឹត្តដោយពលរដ្ឋខ្មែរនៅក្រៅដែនដីនៃព្រះរាជាណាចក្រម្ពុជា។ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទមជ្ឈិមដែលប្រព្រឹត្តដោយពលរដ្ឋខ្មែរនៅក្នុងប្រទេសណាមួយ ប្រសិនបើអំពើនោះត្រូវបានផ្តន្ទាទោសតាមច្បាប់នៃប្រទេសនោះផងដែរ។ បទប្បញ្ញត្តិទាំងអស់ត្រូវអនុវត្តផងដែរ ទោះបីជាជនជាប់ចោទបានទទួលសញ្ជាតិខ្មែរក្រោយអំពើដែលចោទប្រកាន់នេះក៏ដោយ ។[82] ជាករណីដែលបន្ទាប់ពីខ្លួនបានប្រព្រឹត្តអំពើល្មើសនៅបរទេស ជននោះរត់គេចខ្លួនមកជ្រកកោននៅកម្ពុជា និងទទួលបានសញ្ជាតិខ្មែរដោយសង្ឃឹមថាគេចផុតពីទណ្ឌកម្មគ្រប់ប្រភេទ។ បទប្បញ្ញត្តិ គឺបានចែងយ៉ាងច្បាស់អំពីជនល្មើសដែលជាពលរដ្ឋខ្មែរប្រព្រឹត្តបទល្មើសនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

**ក. ករណីបទឧក្រិដ្ឋ**

ចំពោះបទឧក្រិដ្ឋ ជនល្មើសដែលជាពលរដ្ឋខ្មែរប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជាគឺច្បាប់ព្រហ្មទណ្ឌកម្ពុជាមានអានុភាពអនុវត្តទៅលើជនល្មើសដែលប្រព្រឹត្តបទល្មើសនេះតែម្តង នេះមានន័យថាច្បាប់ព្រហ្មទណ្ឌកម្ពុជាអាចធ្វើការដាក់ទោសទៅលើជននេះបានផងដែរ។

[81] មាត្រា ៤៧ នៃច្បាប់ស្តីពី អាកាសចរស៊ីវិល។
[82] មាត្រា ១៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩។

ក្នុងករណីនេះ គឺមានន័យថានៅពេលដែលពលរដ្ឋខ្មែរណាម្នាក់បានប្រព្រឹត្តអំពើណាមួយនៅលើទឹកដីនៃរដ្ឋបរទេស ហើយអំពើនោះត្រូវបានច្បាប់ព្រហ្មទណ្ឌកម្ពុជាបានចាត់ទុកថាជាបទឧក្រិដ្ឋ ដូច្នេះ ច្បាប់ព្រហ្មទណ្ឌកម្ពុជា គឺមានអានុភាពអនុវត្តទៅលើជនល្មើសដែលជាពលរដ្ឋខ្មែរ ទោះបីជាអំពើនោះពុំត្រូវបានច្បាប់ព្រហ្មទណ្ឌបរទេសកំណត់ថាជាបទល្មើសក៏ដោយ។

**ខ. ចំពោះបទមជ្ឈិម**

ពលរដ្ឋខ្មែរដែលជាជនល្មើសប្រព្រឹត្តនៅក្រៅប្រទេសកម្ពុជាអាចផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌកម្ពុជាបាន គឺទាល់តែបទល្មើសដែលគាត់ប្រព្រឹត្តនោត្រូវបានប្រទេសក្រៅនោះគេកំណត់ថា គឺជាបទល្មើសហើយត្រូវផ្តន្ទាទោសផងដែរ។ ប្រសិនបើជាប្រទេសនោះគេមិនកំណត់អំពើហ្នឹងថាជាបទល្មើសដែលត្រូវផ្តន្ទាទោសទេ គឺករណីនេះច្បាប់ព្រហ្មទណ្ឌកម្ពុជាយើងមិនអាចយកទៅអនុវត្តចំពោះបទល្មើសនេះទេ ចំពោះករណីបទមជ្ឈិម។[83]

ក្នុងករណីដែលពលរដ្ឋខ្មែរណាម្នាក់បានប្រព្រឹត្តអំពើល្មើសណាមួយជាបទមជ្ឈិមនៅលើទឹកដីនៃរដ្ឋបរទេស ច្បាប់ព្រហ្មទណ្ឌកម្ពុជាក៏មានអានុភាពអនុវត្តទៅលើជនល្មើសជាពលរដ្ឋខ្មែរនោះបានដែរ ប៉ុន្តែករណីដែលអំពើនោះត្រូវបានច្បាប់ព្រហ្មទណ្ឌបរទេសកំណត់ថាជាបទល្មើសហើយត្រូវបានផ្តន្ទាទោសដែរ។ ឧទាហរណ៍៖ ករណីបទល្មើសរួមភេទជាមួយនឹងញាតិលោហិត ឬញាតិពន្ធ[84] ដែលច្បាប់ព្រហ្មទណ្ឌកម្ពុជាកំណត់ថាជាបទល្មើសមជ្ឈិមនឹងត្រូវផ្តន្ទាទោសពី១ (មួយ)ខែ ទៅ១(មួយ)ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន)រៀល ទៅ ២.០០០.០០០(ពីរលាន)រៀល។ ប្រសិនបើពលរដ្ឋខ្មែរណាម្នាក់បានប្រព្រឹត្តបទល្មើសនេះលើទឹកដីនៃរដ្ឋបរទេសណាមួយ ហើយរដ្ឋបរទេសនោះមិនបានកំណត់អំពើរួមភេទជាមួយញាតិលោហិត ឬញាតិពន្ធថាជាបទល្មើសនោះទេ ដូច្នេះ ច្បាប់ព្រហ្មទណ្ឌកម្ពុជាក៏គ្មានអានុភាពអនុវត្តទៅលើជនប្រព្រឹត្តដែលជាពលរដ្ឋខ្មែរនោះបានដែរ ប៉ុន្តែក្នុងករណីដែលច្បាប់នៃរដ្ឋដែលអំពើនោះបានកើតឡើងកំណត់ថាជាបទល្មើស និងត្រូវផ្តន្ទាទោសដែរនោះ ដូច្នេះ ច្បាប់ព្រហ្មទណ្ឌកម្ពុជា គឺមានអានុភាពអនុវត្តលើជនដែលបានប្រព្រឹត្តអំពើនោះ។

សូមបញ្ជាក់ក្នុងករណីទាំងពីរខាងលើនេះ(បទល្មើសដែលប្រព្រឹត្តដោយពលរដ្ឋខ្មែរ ក្នុងករណីបទឧក្រិដ្ឋ និងបទល្មើសដែលប្រព្រឹត្តដោយពលរដ្ឋខ្មែរក្នុងករណីបទមជ្ឈិម) បទប្បញ្ញត្តិនៃមាត្រា១៩ នៃក្រមព្រហ្មទណ្ឌ

[83] ប្រសាសន៍ ឯកឧត្តម ប៊ុន ហ៊ុន ក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី ក្រមព្រហ្មទណ្ឌនៃព្រះរាជណាចក្រកម្ពុជា។

[84] មាត្រា ៣៥២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩។

កម្ពុជាយកអនុវត្តបានដែរ បើទោះបីជាជនជាប់ចោទបានទទួលសញ្ជាតិខ្មែរក្រោយអំពើដែលបានចោទប្រកាន់នោះក៏ដោយ។

### ៣.២.១.២. បទល្មើសដែលមានជនរងគ្រោះជាពលរដ្ឋខ្មែរ

ព្រហ្មទណ្ឌកម្ពុជាត្រូវបានអនុវត្តទៅលើគ្រប់បទឧក្រិដ្ឋ ដែលប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជាដោយពលរដ្ឋខ្មែរ ឬដោយជនបរទេសទៅលើជនរងគ្រោះដែលមានសញ្ជាតិខ្មែរ នៅក្នុងពេលដែលបទល្មើសត្រូវបានប្រព្រឹត្ត"។[85] បទបញ្ញត្តិនេះចែងតែចំពោះបទឧក្រិដ្ឋប៉ុណ្ណោះ គឺមិនមានចែងចំពោះបទមជ្ឈិម ឬលហុនោះទេ។ យើងអាចនិយាយបានថា ប្រសិនបើពលរដ្ឋកម្ពុជាណាម្នាក់ ឬច្រើននាក់ត្រូវបានជនល្មើសប្រព្រឹត្តបទល្មើសដែលជាប្រភេទបទឧក្រិដ្ឋទៅលើពលរដ្ឋខ្មែរណាម្នាក់ ឬច្រើននាក់នៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ទោះបីជាជនល្មើសនោះគឺជាពលរដ្ឋខ្មែរ ឬក៏មិនមែនជាខ្មែរក៏ដោយ គឺថាច្បាប់ព្រហ្មទណ្ឌកម្ពុជាមានអានុភាពអនុវត្តទៅលើបទល្មើសមួយនោះ។[86] ប៉ុន្តែបើសិនជាប្រព្រឹត្តបទមជ្ឈិម ឬបទលហុ គឺនៅក្នុងច្បាប់កម្ពុជាមិនមានចែងនោះទេ ដូច្នេះច្បាប់ព្រហ្មទណ្ឌកម្ពុជាមិនមានអានុភាពអនុវត្តនោះទេ ព្រោះវាជាសមត្ថកិច្ចរបស់ប្រទេសដែលមានពលរដ្ឋកម្ពុជាជាជនរងគ្រោះដែលកំពុងរស់នៅក្នុងប្រទេសនោះ។ សរុបមកវិញ យើងអាចនិយាយបានថា ទាក់ទងនឹងសញ្ជាតិជនរងគ្រោះដែលជាពលរដ្ឋខ្មែរនេះ គឺមានតែសម្រាប់តែបទឧក្រិដ្ឋតែប៉ុណ្ណោះ នៅពេលដែលបទឧក្រិដ្ឋមួយនេះបានប្រព្រឹត្តនៅឯក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដោយមានពលរដ្ឋខ្មែរជាជនរងគ្រោះ។

### ក. ករណីបទឧក្រិដ្ឋ

យោងមាត្រា ២០ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ នៃក្រមព្រហ្មទណ្ឌកម្ពុជា បានបញ្ញត្តថា "ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវបានអនុវត្តទៅលើគ្រប់បទឧក្រិដ្ឋ ដែលប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជាដោយពលរដ្ឋខ្មែរ ឬដោយជនបរទេសទៅលើជនរងគ្រោះដែលមានសញ្ជាតិខ្មែរ នៅក្នុងពេលដែលបទល្មើសត្រូវបានប្រព្រឹត្ត" ក្នុងករណីនេះ គឺច្បាប់ព្រហ្មទណ្ឌមានចែងសម្រាប់តែបទឧក្រិដ្ឋដែលមានពលរដ្ឋខ្មែរជាជនរងគ្រោះប៉ុណ្ណោះ ចំពោះបទមជ្ឈិម និងលហុគឺអនុវត្តមិនបានទេ។

[85] យោងមាត្រា ២០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩។

[86] ប្រសាសន៍ ឯកឧត្តម ប៊ុន ហ៊ុន អនុប្រធានគាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌ ក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីពី ក្រមព្រហ្មទណ្ឌនៃព្រះរាជណាចក្រកម្ពុជា។

### ៣.២.១.៣. លក្ខខណ្ឌនៃការចោទប្រកាន់

ទាក់ទងទៅនឹងបទបញ្ញត្តិ បទឧក្រិដ្ឋ ឬបទមជ្ឈិមប្រព្រឹត្តដោយជនជាតិខ្មែរ និងជនរងគ្រោះជាជនជាតិខ្មែរ ការចោទប្រកាន់អាចប្រព្រឹត្តទៅបានតាមបណ្ដឹងរបស់អយ្យការតែប៉ុណ្ណោះ។ ការចោទប្រកាន់ត្រូវតែមានបណ្ដឹងពីជនរងគ្រោះ ឬពីសិទ្ធិវន្ត[87] ឬបណ្ដឹងបរិហារ[88] ជាផ្លូវការរបស់អាជ្ញាធរនៃប្រទេសដែលជាទីកន្លែងដែលជាអំពើនោះបានប្រព្រឹត្ត[89]។ ទាក់ទងនឹងបញ្ហានេះ ទោះបីជាគាត់ជាជនល្មើសដែលជាពលរដ្ឋខ្មែរក៏ដោយ ឬក៏ជាជនរងគ្រោះជាពលរដ្ឋខ្មែរក៏ដោយ អាចដំណើរការនីតិវិធីនៃការចោទប្រកាន់បានទាល់តែខាងស្ថាប័នអយ្យការជាអ្នកធ្វើការប្ដឹងចោទ ហើយការប្ដឹងចោទនេះធ្វើទៅបានទាល់តែមានបណ្ដឹងអំពីជនរងគ្រោះ ឬពីសិទ្ធិវន្ត ឬក៏មានបណ្ដឹង បរិហារជាផ្លូវការរបស់អាជ្ញាធរនៃប្រទេសដែលជាទីកន្លែងដែលបានប្រព្រឹត្តអំពើនោះ។ ព្រោះមានតែស្ថាប័នអយ្យការតែប៉ុណ្ណោះដែលអាចធ្វើចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសុំឲ្យអនុវត្តច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ និងយុត្តាធិការជំនុំជម្រះ[90]។ មិនត្រឹមតែប៉ុណ្ណោះ ព្រះរាជអាជ្ញាថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យប្ដឹង និងពាក្យបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក។ ព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ។ មុននឹងសម្រេចព្រះរាជអាជ្ញា បើកការស៊ើបអង្កេតបឋម ឬបង្គាប់ឲ្យធ្វើការស្រាវជ្រាវបន្ថែម។ ក្នុងករណីមានបទល្មើសធ្ងន់ធ្ងរ ព្រះរាជអាជ្ញារាយការណ៍ជូនអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលត្រូវរាយការណ៍បន្តជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។[91] នេះជាលក្ខខណ្ឌនៃដំណើការនីតិវិធី ប្រសិនបើមិនមានការប្ដឹងដូចលក្ខខណ្ឌដែលមានចែងក្នុងបទបញ្ញត្តិនេះទេ គឺមិនអាចដំណើរការនីតិវិធីបាននោះទេ។

### ៣.២.២. បទល្មើសដែលប្រឆាំងនឹងកម្ពុជា

ក្រៅពីបទល្មើសដែលត្រូវបានកំណត់សមត្ថកិច្ចដោយឈរលើគោលការណ៍សញ្ជាតិ ក៏មានបទល្មើសព្រហ្មទណ្ឌពិសេសមួយចំនួនទៀត បើទោះបីជាជនល្មើសមានសញ្ជាតិអ្វីក៏ដោយ និងទោះបីជារដ្ឋបរទេសនោះគ្មានច្បាប់កំណត់ថាជាបទល្មើសក៏ដោយ ឱ្យតែបទល្មើសនោះត្រូវបានប្រព្រឹត្ត ហើយដែលច្បាប់កម្ពុជាកំណត់ថាជាបទឧក្រិដ្ឋនោះ គឺតុលាការកម្ពុជាមានសមត្ថកិច្ច។ ជាទូទៅប្រភេទនៃបទល្មើសទាំងនោះ គឺភាគច្រើនពាក់ព័ន្ធនឹងការប្រឆាំង ឬធ្វើឱ្យប៉ះពាល់ដល់សន្តិសុខសណ្ដាប់ធ្នាប់ និងផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា

---

[87] សិទ្ធិវន្ត គឺជាអ្នកមានសិទ្ធិណាមួយ អ្នកមានឧបនិស្ស័យអនុវត្តសិទ្ធណាមួយ។

[88] បណ្ដឹងបរិហារ គឺជាបណ្ដឹងដែលមានគោលបំណងលាតត្រដាងពីអត្ថិភាពនៃបទល្មើសណាមួយ។

[89] មាត្រា ២១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩។

[90] មាត្រា៤ កថាខណ្ឌទី ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវបានប្រកាសអោយប្រើយព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ នៅថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០០៧។

[91] មាត្រា ៤០ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

ហើយត្រូវបានសមត្ថកិច្ចរបស់តុលាការកម្ពុជាបានតម្រូវឲ្យទទួលស្គាល់ ដោយហេតុថាមានការបំពានដល់អត្ថប្រយោជន៍កម្ពុជា។ ដូច្នេះ យើងសូមធ្វើការបកស្រាយដូចខាងក្រោម៖ **៣.២.២.១ បទល្មើសដែលប្រឆាំងនឹងសុវត្ថិភាពនៃព្រះរាជាណាចក្រកម្ពុជា ៣.២.២.២ បទល្មើសក្លែងត្រាផ្លូវការនៃព្រះរាជាណាចក្រកម្ពុជា ៣.២.២.៣ បទល្មើសក្លែងរូបិយវត្ថុ និងធនបត្រជាតិនៃព្រះរាជាណាចក្រកម្ពុជា ៣.២.២.៤ បទល្មើសប្រឆាំងភ្នាក់ងារទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា និង៣.២.២.៥ បទល្មើសប្រឆាំងនឹងទីតាំងទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា។**

### ៣.២.២.១. បទល្មើសដែលប្រឆាំងនឹងសុវត្ថិភាពនៃកម្ពុជាព្រះរាជាណាចក្រកម្ពុជា

បើនិយាយពីបទល្មើសប្រឆាំងនឹងសុវត្ថិភាពនៃព្រះរាជាណាចក្រកម្ពុជា គឺមានពីររួមមាន៖ ការរំលោភបំពានដល់អង្គព្រះមហាក្សត្រ និងការប៉ះពាល់ដល់សន្តិសុខនៃរដ្ឋ។

**ក. ការរំលោភបំពានដល់អង្គព្រះមហាក្សត្រ៖** យោងតាមមាត្រា ៤៣៣ ដល់ ៤៣៨ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា មិនមានចែងអំពីអំពើបរិហារកេរ្តិ៍ប្រមាថដល់ព្រះមហាក្សត្រនោះទេ មានតែចែងពីអំពើរំលោភបំពានក្នុងករណីដែលមានការរំលោភបំពានអង្គព្រះមហាក្សត្រ។ មាត្រា ៤៣៣ បទរាជឃាតកម្មចែងថា៖ រាជឃាតកម្ម គឺជាឃាតកម្មចំពោះព្រះមហាក្សត្រ ត្រូវផ្តន្ទាទោសអស់មួយជីវិត។ ដោយយើងអាចនិយាយបានថា អំពើដែលជនណា ឬជាក្រុមណាមានការចាត់តាំង[92] (ចារី សហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត ឬដោយឆន្ទៈដោយផ្ទាល់របស់ចារី) ដែលបានប្រព្រឹត្តបទល្មើសត្រូវមានទោស ដោយយោងតាមបទបញ្ញត្តិនេះ។ វិធានការណ៍ការពារដល់ព្រះមហាក្សត្រ តាមរដ្ឋធម្មនុញ្ញទោះជាជន ដែលប្រព្រឹត្តបទល្មើសនោះ ជាជនដែលចេញពីឋានៈក្សត្រក៏ដោយត្រូវតែទទួលទោសនូវអំពើដែលបានប្រព្រឹត្ត។ មាត្រា ៤៣៤ បទធ្វើទារុណកម្ម ឬអំពើឃោរឃៅចំពោះអង្គព្រះមហាក្សត្រចែងថា៖ ទារុណកម្ម ឬអំពើឃោរឃៅចំពោះអង្គព្រះមហាក្សត្រត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំទៅ ២០ឆ្នាំ។ មាត្រា៤៣៥ បទហិង្សាចំពោះអង្គព្រះមហាក្សត្រ ចែងថា៖ អំពើហិង្សាប្រព្រឹត្តដោយចេតនាចំពោះអង្គព្រះមហាក្សត្រ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ឆ្នាំទៅ ១៥ឆ្នាំ។ មាត្រា ៤៣៦ ស្ថានទម្ងន់ទោសដោយសារការកាត់អវយវៈ ឬពិការភាព ចែងថា៖ អំពើហិង្សាប្រព្រឹត្តដោយចេតនាចំពោះអង្គព្រះមហាក្សត្រ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំទៅ ២០ឆ្នាំ កាលបើអំពើនេះនាំឲ្យមានការកាត់អវយវៈ ឬពិការភាពជាអចិន្ត្រៃយ៍ដល់អង្គព្រះមហាក្សត្រ។ មាត្រា៤៣៧ ស្ថានទម្ងន់ទោសដោយសារការចូលទិវង្គត ចែងថា៖ អំពើហិង្សាប្រព្រឹត្តដោយចេតនាចំពោះអង្គព្រះមហាក្សត្រ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ឆ្នាំទៅ ៣០ឆ្នាំ

[92] ក្រុមមានការចាត់តាំង គឺជាការប្រមូលផ្តុំដែលបានកើតឡើង ឬជាសន្ធិដ្ឋិភាពដែលបានធ្វើឡើង ដើម្បីត្រៀមរៀបចំ ឬប្រព្រឹត្តបទល្មើសមួយ ឬច្រើន។

កាលបើអំពើនេះ នាំឲ្យមានការចូលទិវង្គត ដោយគ្មានចេតនានឹងធ្វើឲ្យមានការចូលទិវង្គតទេ។ មាត្រា៤៣៧ (ស្ទួន) បទប្រមាថចំពោះអង្គព្រះមហាក្សត្រ ចែងថា ៖ ការប្រមាថ គឺជាវាចាកាយវិការ សំណេរ គំនូរ ឬវត្ថុដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរនៃបុគ្គល។ ការប្រមាថចំពោះអង្គព្រះមហាក្សត្រ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១ (មួយ) ឆ្នាំ ទៅ៥ (ប្រាំ) ឆ្នាំ និងការពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ១០.០០០.០០០ (ដប់លាន) រៀល។

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមនេះចំពោះបទប្រមាថចំពោះអង្គព្រះមហាក្សត្រ។ នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើនដូចតទៅនេះ ៖

១. ការរំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមនេះ។

២. ការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រមនេះ។

៣. ការហាមឃាត់ចំពោះការធ្វើសកម្មភាពណាមួយ ឬច្រើនតាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមនេះ។

៤. ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៦ (ការបិទគ្រឹះស្ថាន) នៃក្រមនេះ។

៥. ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ។

៦. ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស តាមបែបបទកំណត់ដោយមាត្រា១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា ១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ។

៧. ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស តាមបែបបទកំណត់ដោយមាត្រា ១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ។

៨. ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមនេះ។

៩. ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍) នៃក្រមនេះ ។

**ខ. ការប៉ះពាល់ដល់សន្តិសុខនៃរដ្ឋ គឺសំដៅដល់អំពើដូចជា៖**

- **អំពើក្បត់ជាតិ និងចារកម្ម៖** កាលបើបទល្មើសប្រព្រឹត្តដោយពលរដ្ឋខ្មែរ ឬដោយយោធិនខ្មែរ និងជាចារកម្ម កាលបើបទល្មើសនេះប្រព្រឹត្តដោយបុគ្គលជាជនបរទេសដទៃទៀត។[93]
- **ឧបឃាត និងការរួមគំនិតក្បត់៖** បទឧបឃាត គឺជាការប្រព្រឹត្តអំពើហិង្សាមួយ ឬច្រើន ក្នុងគោលបំណងបង្កឲ្យមានគ្រោះថ្នាក់ដល់ស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជា ឬនាំឲ្យមានការប៉ះពាល់ដល់បូរណភាពនៃដែនដីជាតិ។[94]
- **អំពើរួមគំនិតក្បត់៖** គឺជាគម្រោងដែលបង្កើតឡើងដោយមនុស្សច្រើននាក់ដើម្បីប្រព្រឹត្តឧបឃាត កាលបើគម្រោងនេះត្រូវបានសម្តែងចេញជារូបរាងច្បាស់លាស់ដោយអំពើជាក់ស្តែងមួយ ឬច្រើន។[95]
- **កុបកម្ម៖** គឺជាអំពើហិង្សាជាសមូហភាពដែលអាចនាំឲ្យមានគ្រោះថ្នាក់ដល់ស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជា ឬនាំឲ្យមានការប៉ះពាល់ដល់បូរណភាពនៃដែនដីជាតិ។[96]
- **ការដណ្តើមយកអំណាចបញ្ជា និងការបង្កើតកងកម្លាំងប្រដាប់អាវុធ ៖** អំពើដណ្តើមយកអំណាចយោធាជាអំពើដណ្តើមដោយគ្មានសិទ្ធិ ឬគ្មានការអនុញ្ញាតពីអាជ្ញាធរស្របច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ទៅ ៣០ឆ្នាំ។[97]
- **ការង្កើតកងកម្លាំងប្រដាប់អាវុធ** ជាការគ្មានសិទ្ធិ ឬគ្មានការអនុញ្ញាតពីអាជ្ញាធរស្របច្បាប់ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ទៅ ៣០ឆ្នាំ។[98]
- **ការប៉ះពាល់ដល់សន្តិសុខនៃកងយោពលខេមរភូមិន្ទ៖** មានន័យថា ជាការញុះញង់ឲ្យយោធិនចូលបម្រើរដ្ឋបរទេស ឬភ្នាក់ងារបរទេស ឬជាការរារាំងដំណើរការជាធម្មតានៃសម្ភារៈយោធា។

[93] មាត្រា ៤៣៩ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩។
[94] មាត្រា ៤៥១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ ។
[95] មាត្រា ៤៥៣ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩។
[96] មាត្រា ៤៥៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩។
[97] មាត្រា ៤៦១ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩។
[98] មាត្រា ៤៦៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩។

០ ការប៉ះពាល់ដល់ការសម្ងាត់នៃការការពារជាតិ៖ គឺលក្ខណៈជាការសម្ងាត់នៃការការពារជាតិ គឺព័ត៌មាន វិធី វត្ថុ ឯកសារ សលាកបត្រ ឬទិន្នន័យព័ត៌មានវិទ្យា ដែលការផ្សព្វផ្សាយត្រូវបានកម្រិត។[99]

### ៣.២.២.២. បទល្មើសក្លែងត្រាផ្លូវការ

ត្រាផ្លូវការរបស់ក្រសួង ស្ថាប័ន រដ្ឋអំណាចគ្រប់ជាន់ថ្នាក់ នីមួយត្រូវមានរូបភាពប្រាសាទកំពូលបីជុំវិញរង្វង់ ដែលសរសេរអក្សរឈ្មោះកម្ពុជានៅខាងលើ និងឈ្មោះអង្គភាពនៅខាងក្រោម។ ដោយទណ្ឌកម្មទាក់ទងបទល្មើសក្លែងត្រាមួយនេះ គឺមានចែងលាក់ជាក់ក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាក្រកម្ពុជាបច្ចុប្បន្នតាមបទញ្ញត្តិមាត្រា ៦៦១ បទក្លែងត្រាផ្លូវការរបស់ព្រះរាជាណាចក្រកម្ពុជា បានចែងថា៖ ការក្លែងបន្លំត្រាផ្លូវការរបស់ព្រះរាជាណាចក្រកម្ពុជាត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ពីរ ទៅ ប្រាំឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ រៀល ទៅ ១០.០០០.០០០ រៀល។ មាត្រា ៦៦២ បទប្រើប្រាស់ត្រាក្លែង បានចែងថា៖ ការប្រើប្រាស់ត្រាផ្លូវការរបស់ព្រះរាជាណាក្រកម្ពុជាដែលក្លែង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំទៅ ៥ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០រៀល ទៅ ១០.០០០.០០០ រៀល។ មាត្រា ៦៦៣ បទក្លែងប្រដាសដែលមានក្បាលលិខិតផ្លូវការ បានចែងថា៖ ការក្លែងបន្លំប្រដាសដែលមានក្បាលលិខិតផ្លូវការប្រើប្រាស់ ដោយអាជ្ញាធរសាធារណៈនោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី មួយ ខែ ទៅមួយឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ រៀល ទៅ ២.០០០.០០០ រៀល។ មាត្រា ៦៦៤ បទប្រើប្រាស់ក្រដាសក្លែងដែលមានក្បាលលិខិតផ្លូវការ បានចែងថា៖ ការប្រើប្រាស់ក្រដាសក្លែងដែលមានក្បាលលិខិតផ្លូវការ ប្រើប្រាស់ដោយអាជ្ញាធរសាធារណៈត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី មួយខែ ទៅមួយឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ រៀល ទៅ ២.០០០.០០០ រៀល។ មាត្រា ៦៦៥ បទផលិតក្រដាសពុម្ពដែលបង្កើតឲ្យមានការភាន់ច្រឡំ បានចែងថា៖ ការធ្វើ ការលក់ ការចែកចាយ ឬការប្រើប្រាស់ ក្រដាស ពុម្ពជាមួយនឹងក្រដាសអាជ្ញាធរសាធារណៈ ដែលមានភាពប្រហាក់ប្រហែលគ្នា ដែលអាចបង្កើតឲ្យមាន ការភ័ន្តច្រឡំនៅក្នុងស្មារតីរបស់សាធារណជន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ខែទៅ ១ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០ រៀល ទៅ ២.០០០.០០០ រៀល។ ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងផ្នែកនេះត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ។

### ៣.២.២.៣. បទល្មើសក្លែងរូបិយវត្ថុ និងធនបត្រជាតិនៃព្រះរាជាណាចក្រកម្ពុជា

ពាក្យថារូបិយវត្ថុ គឺជាអ្វីដែលគេទទួលស្គាល់ជាទូទៅ និងត្រូវបានគេប្រើប្រាស់ដោយផ្ទាល់នៅក្នុងការទិញទំនិញ សេវានានា ឬអាចហៅម្យ៉ាងទៀតថា ជាមធ្យោបាយនៃការចាយវាយទូទាត់បំណុលដែលត្រូវបានគេ

[99] មាត្រា ៤៧៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩។

ទទួលស្គាល់ជាសកល។ រីឯធនបត្រជាតិ គឺជារូបិយវត្ថុដែលប្រើក្នុងព្រះរាជាណាក្រកម្ពុជា ដែលផលិតដោយធនាគារជាតិកម្ពុជា។

ហើយអ្នកដែលក្លែងរូបិយវត្ថុ និងធនបត្រជាតិ ត្រូវផ្តន្ទាទោសតាមក្រមព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជាយោងតាមមាត្រា ៦៤៥ បទក្លែងបន្លំរូបិយវត្ថុដែលមានតម្លៃនីត្យានុកូល បានចែងថាៈ ការក្លែងបន្លំក្រដាសប្រាក់ ឬកាសដែលជារូបិយវត្ថុមានតម្លៃនីត្យានុកូលនៅព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ឆ្នាំទៅ ៣០ឆ្នាំ ឬអស់មួយជីវិត។ មាត្រា ៦៤៦ បទក្លែងបន្លំរូបិយបណ្ណដែលមានតម្លៃនីត្យានុកូល បានចែងថាៈ ការក្លែងបន្លំរូបិយបណ្ណដែលមានតម្លៃនីត្យានុកូលដែលបោះពុម្ពផ្សាយដោយស្ថាប័នបរទេស ឬអន្តរជាតិ ដែលមាននីតិសម្បទា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំទៅ ២០ឆ្នាំ។ មាត្រា ៦៤៧ ការដាក់ឲ្យធ្វើចរាចរណ៍រូបិយវត្ថុ និងរូបិយបណ្ណក្លែង ចែងថាៈ ការដាក់ឲ្យធ្វើចរាចរណ៍រូបិយវត្ថុ ឬរូបិយបណ្ណក្លែងដែលមានចែងក្នុងមាត្រា ៦៤៥ និង ៦៤៦ នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ទៅ ១០ឆ្នាំ។ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីដប់ឆ្នាំ ទៅម្ភៃឆ្នាំ កាលបើបទល្មើសនេះបានប្រព្រឹត្តជាក្រុមមានការចាត់តាំង។ មាត្រា ៦៤៨ បទ សន្និធិរូបិយវត្ថុ[100] និងរូបិយបណ្ណក្លែង ចែងថាៈ អំពើដឹកជញ្ជូន ឬសន្និធិរូបិយវត្ថុ ឬរូបិយបណ្ណក្លែងដែលមានចែងក្នុងមាត្រា ៦៤៥ និង ៦៤៦ នៃក្រមនេះដើម្បីយកទៅដាក់ឲ្យធ្វើចរាចរណ៍ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ទៅ ១០ឆ្នាំ។ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំទៅ ២០ឆ្នាំ កាលបើបទល្មើសនេះបានប្រព្រឹត្តជាក្រុមមានការចាត់តាំង។ មាត្រា ៦៤៩ បទក្លែងបន្លំរូបិយវត្ថុ និងរូបិយបណ្ណដែលអស់តម្លៃនីត្យានុកូល ចែងថាៈ ការក្លែងបន្លំរូបិយវត្ថុ ឬរូបិយបណ្ណដែលអស់តម្លៃនីត្យានុកូលនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ឆ្នាំទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ រៀល ទៅ ៦.០០០.០០០ រៀល។ មាត្រា ៦៥០ បទកាន់កាប់ដោយខុសច្បាប់នូវសម្ភារៈផលិតរូបិយវត្ថុនិងរូបិយបណ្ណ ចែងថាៈ ការកាន់កាប់ដោយគ្មានការអនុញ្ញាត នូវឧបករណ៍ និងសម្ភារៈដែលជាពិសេស សម្រាប់ធ្វើរូបិយវត្ថុ ឬរូបិយបណ្ណ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ ។ មាត្រា ៦៥១ បទដាក់ឲ្យធ្វើចរាចរណ៍ជាថ្មី នូវរូបិយវត្ថុ និងរូបិយបណ្ណក្លែង ចែងថាៈ អំពើរបស់បុគ្គលណាដែលបានទទួលរូបិយវត្ថុ ឬរូបិយបណ្ណ ក្លែងដែលមានចែងក្នុងមាត្រា ៦៤៥ និង មាត្រា ៦៤៦ នៃក្រមនេះ ដោយគិតថាជារូបិយវត្ថុ ឬរូបិយបណ្ណពិត ហើយយកទៅដាក់ឲ្យធ្វើចរាចរណ៍ជាថ្មី ក្រោយពីបានដឹងថាជារបស់ក្លែងនោះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីរ ១ថ្ងៃ ទៅ ៦ថ្ងៃ និងពិន័យជាប្រាក់ពី ១០០ ០០០ រៀល ទៅ ១០ ០០០ ០០០ រៀល។ មាត្រា ៦៥២ ការលើកលែងឲ្យរួចផុតពីទោស ចែងថាៈ បុគ្គលណាដែលបានប៉ុនប៉ងប្រព្រឹត្តបទល្មើសណាមួយ ក្នុងចំណោមបទល្មើសដែលមានចែងក្នុងផ្នែកនេះ នឹងត្រូវ

[100] សំនិធិ ឬសន្និធិៈ ការសន្សំទុក ការសំចៃ ឬការទុកសំចៃ។

បានលើកលែងឲ្យរួចផុតពីទោស ប្រសិនបើបុគ្គលនោះ បានធ្វើឲ្យបទល្មើសនោះមិនបានសម្រេច និងនាំឲ្យដឹងពីអត្តសញ្ញាណជាយថាហេតុរបស់ជនល្មើសផ្សេងៗទៀត ដោយបានឲ្យដំណឹងដល់អាជ្ញាធររដ្ឋបាល ឬតុលាការ។

### ៣.២.២.៤. បទល្មើសប្រឆាំងភ្នាក់ងារទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា

រដ្ឋនីមួយៗអាចធ្វើទំនាក់ទំនងការទូតរវាងរដ្ឋរបស់ខ្លួនទៅនឹងរដ្ឋផ្សេងមួយទៀតដោយមានអ្នកតំណាង របស់ខ្លួនមាននៅក្នុងរដ្ឋមួយនោះដើម្បីជាអ្នកការពារផលប្រយោជន៍របស់រដ្ឋ និងកាត់បន្ថយជម្លោះជាដើម។ ភ្នាក់ងារការទូត គឺជាប្រធានបេសកកម្មឬជាសមាជិកបុគ្គលិកការទូតនៃបេសកកម្ម។[101] មន្ត្រីកុងស៊ុលជាជនណាដែលទទួលបន្ទុកបំពេញមុខងារកុងស៊ុលដោយគិតទាំងប្រធានប៉ុស្តិ៍កុងស៊ុលផងដែរ ។[102]

ដោយយោងតាមប្រការ ២៩ នៃអនុសញ្ញាទីក្រុងវីយែនស្តីពី ទំនាក់ទំនងការទូត ឆ្នាំ១៩៦១ បានចែងថា៖ បុគ្គលនៃភ្នាក់ងារការទូតមិនអាចរំលោភបានឡើយ។ គាត់មិនទទួលខុសត្រូវចំពោះទម្រង់នៃការចាប់ខ្លួន ឬការឃុំខ្លួនណាមួយឡើយ។ រដ្ឋដែលទទួលបានត្រូវគោរពភ្នាក់ងារទូត និងចាត់វិធានការសមស្របទាំងឡាយដើម្បីការពារការវាយប្រហាររបស់ខ្លួនទៅលើសេរីភាព ឬសេចក្តីថ្លៃថ្នូររបស់ភ្នាក់ងារទូត។

ចំណែកឯប្រការ ៤១ នៃច្បាប់ស្តីពី ការអនុម័តយល់ព្រមលើអនុសញ្ញាទីក្រុងវីយែនស្តីពី ទំនាក់ទំនងកុងស៊ុល ឆ្នាំ២០០៥ ចែងថា៖ សិទ្ធិមិនត្រូវគេបំពានមន្ត្រីកុងស៊ុល

១. មន្ត្រីកុងស៊ុលមិនអាចត្រូវចាប់ខ្លួន ឬឃុំខ្លួនបណ្តោះអាសន្នរង់ចាំការកាត់ទោសឡើយលើកលែងតែមានបទឧក្រិដ្ឋធ្ងន់ធ្ងរ និងបន្ទាប់ពីមានសេចក្តីសម្រេចណាមួយពីអាជ្ញាធរមានសមត្ថកិច្ចតុលាការ។

២. លើកលែងតែករណីដូចចែងក្នុងកថាខណ្ឌ១ នៃប្រការនេះមន្ត្រីកុងស៊ុលមិនអាចត្រូវជាប់ពន្ធនាគារ ឬនៅក្រោមរូបភាពណាមួយផ្សេងទៀតនៃការកំរិតសេរីភាពផ្ទាល់ខ្លួនរបស់គេបានឡើយ លើកលែងតែមានការអនុវត្តនូវសេចក្តីសម្រេចជាស្ថាពររបស់តុលាការ។

៣. កាលណាមានបណ្តឹងព្រហ្មទណ្ឌ ត្រូវដាក់ប្តឹងចោទប្រកាន់ចំពោះមុខមន្ត្រីកុងស៊ុលណាម្នាក់ មន្ត្រីនោះត្រូវតែចូលបង្ហាញខ្លួននៅចំពោះមុខអាជ្ញាធរសមត្ថកិច្ច។ ក៏ប៉ុន្តែបណ្តឹងនោះត្រូវធ្វើដោយការគោរពដោយសារតួនាទីជាផ្លូវការរបស់មន្ត្រីនោះ និងធ្វើឲ្យរំខានតិចបំផុតដល់ការបំពេញមុខងារកុងស៊ុល លើកលែងតែករណីដូចមានចែងក្នុង កថាខណ្ឌទី១ នៃប្រការនេះ។ ចំពោះបញ្ហាដែលចែងក្នុងកថាខណ្ឌទី១ នៃប្រការនេះប្រសិនបើ

[101] ប្រការ ១ ចំណុច (ង) នៃអនុសញ្ញាទីក្រុងវីយែន ស្តីពីទំនាក់ទំនងការទូត ឆ្នាំ១៩៦១។

[102] ប្រការ ១ ចំណុច (ឃ) នៃអនុសញ្ញាស្តីពី ការអនុម័តយល់ព្រមលើអនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ទំនងកុងស៊ុល ឆ្នាំ២០០៥។

មានការចាំបាច់ត្រូវឃុំខ្លួនមន្ត្រីកុងស៊ុលណាម្នាក់ ការប្តឹងចោទប្រកាន់ចំពោះមន្ត្រីនោះត្រូវធ្វើក្នុងរយៈពេលដ៏ខ្លីបំផុត។

### ៣.២.២.៥. បទល្មើសប្រឆាំងនឹងទីតាំង ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា

ទីតាំងនៃបេសកកម្ម គឺជាអាគារ ឬផ្នែកខ្លះនៃអាគារ និងដីនៅលើដីដោយមិនគិតពីកម្មសិទ្ធិដែលត្រូវបានប្រើសម្រាប់គោលបំណងនៃបេសកកម្មរួមទាំងលំនៅដ្ឋានរបស់ប្រធានបេសកកម្ម។[103]ចំណែកឯទីស្ថានកុងស៊ុល ជាអគារ ឬបណ្តាផ្នែកនៃអគារ និងផ្ទៃដីបន្តភ្ជាប់ ទោះជាកម្មសិទ្ធិរបស់ជនណាក៏ដោយដែលត្រូវប្រើប្រាស់ផ្តាច់មុខសម្រាប់ផលប្រយោជន៍របស់ប៉ុស្តិ៍កុងស៊ុល។[104] ស្ថានកុងស៊ុលជាការិយាល័យដែលបង្កើតឡើងដោយរដ្ឋមួយនៅក្នុងរាជធានី ឬទីក្រុងសំខាន់ៗរបស់រដ្ឋមួយទៀតក្នុងគោលបំណងជួយគាំទ្រ និងការពារប្រជាពលរដ្ឋរបស់គេក្នុងការធ្វើដំណើរ និងស្នាក់នៅទីនោះ។

តាមប្រការ ២២ នៃអនុសញ្ញាទីក្រុងវីយែន ស្តីពីទំនាក់ទំនងការទូត ឆ្នាំ១៩៦១ បានចែងថា៖

១. ទីតាំងនៃបេសកកម្មមិនអាចរំលោភបានឡើយ បណ្តាភ្នាក់ងារនៃរដ្ឋដែលបានទទួលមិនចូលក្នុងទីតាំងបេសកម្មរបស់ពួកគេទេលើកលែងតែមានការយល់ព្រមពីប្រធានបេសកកម្ម។

២. រដ្ឋដែលទទួលបានគឺស្ថិតនៅក្រោមកាតព្វកិច្ចពិសេស ដើម្បីចាត់វិធានការសមស្របទាំងអស់ដើម្បីការពារបរិវេណនៃបេសកកម្មប្រឆាំងនឹងការឈ្លានពាន ឬការបំផ្លិចបំផ្លាញណាមួយ និងដើម្បីការពាររាល់ការរំខានដល់សន្តិភាពនៃបេសកកម្ម ឬការចុះខ្សោយសេចក្តីថ្លៃថ្នូររបស់ខ្លួន។

៣. ទីតាំងនៃបេសកកម្ម គ្រឿងសង្ហារិម និងទ្រព្យសម្បត្តិផ្សេងទៀត និងមធ្យោបាយដឹកជញ្ជូនបេសកកម្មត្រូវតែមានភាពស៊ាំនឹងការរុករកភាពចាំបាច់ឯកសារភ្ជាប់ ឬការប្រតិបត្តិ។

រីឯច្បាប់ស្តីពី ការអនុម័តយល់ព្រមលើអនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ទំនងកុងស៊ុល ឆ្នាំ២០០៥ ប្រការ ៣១ បានចែងថា៖ សិទ្ធិមិនត្រូវបានគេបំពារបំពាននៃបណ្តាប៉ុស្តិ៍កុងស៊ុល

១. បណ្តាទីឋានកុងស៊ុលមិនត្រូវគេបំពានបានក្នុងបែបបទដែលមានចែងក្នុងប្រកាសនេះ។

២. អាជ្ញាធរនៃរដ្ឋម្ចាស់ផ្ទះ មិនអាចចូលទៅក្នុងភាគណាមួយនៃប៉ុស្តិ៍កុងស៊ុល ដែលប៉ុស្តិ៍កុងស៊ុលប្រើប្រាស់ដាច់មុខសម្រាប់ការងាររបស់ខ្លួនឡើយ លើកលែងតែមានការយល់ព្រមពីប្រធានប៉ុស្តិ៍កុងស៊ុល ឬពីជនដែលប្រធានប៉ុស្តិ៍កុងស៊ុលបានចាត់តាំង ឬពីប្រធានបេសកកម្មទូតនៃរដ្ឋដាក់កុងស៊ុល។ ក៏ប៉ុន្តែការយល់ព្រមពី

[103] មាត្រា ១ ចំណុច ( ឈ ) នៃអនុសញ្ញាទីក្រុងវីយែន ស្តីពីទំនាក់ទំនងការទូត ឆ្នាំ១៩៦១

[104] មាត្រា ១ ចំណុច ( ញ ) ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើអនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ទំនងកុងស៊ុល ឆ្នាំ២០០៥

ប្រធានប៉ុស្តិ៍ កុងស៊ុលអាចសន្មតថាបានទទួលក្នុងករណីមានអគ្គីភ័យ ឬមហន្តរាយផ្សេងទៀតដែលតំរូវឲ្យមាន វិធានការណ៍ ការពារជាបន្ទាន់។

៣. ដោយស្ថិតនៅក្រោម ខ ទាំងឡាយក្នុងកថាខណ្ឌទី២ នៃប្រការនេះ រដ្ឋម្ចាស់ផ្ទះមានកាតព្វកិច្ចពិសេសក្នុង ការចាត់គ្រប់វិធានាការណ៍សមស្រប ដើម្បីការពារទីស្ថានកុងស៊ុលកុំឲ្យមានគេលុកលុយ ឬធ្វើឲ្យខូចខាតនិង ដើម្បីកុំឲ្យភាពសុខសាន្តរបស់ប៉ុស្តិ៍កុងស៊ុលត្រូវល្អក់កករ ឬក៏ភាពថ្លៃថ្នូររបស់ប៉ុស្តិ៍កុងស៊ុលត្រូវអាប់អោន។

៤. បណ្ណាទីប៉ុស្តិ៍កុងស៊ុលគ្រឿងសង្ហារឹម និងទ្រព្យសម្បត្តិនៃប៉ុស្តិ៍កុងស៊ុល ក៏ដូចជាមធ្យោបាយដឹកជញ្ជូនរបស់ ប៉ុស្តិ៍កុងស៊ុល មិនអាចធ្វើជាកម្មវត្ថុនៃកំណែនសម្រាប់កិច្ចការពារជាតិ ឬការប្រើប្រាស់ជាសាធារណៈតាមរូប ភាពណាមួយឡើយ។ បើសិនជាចាំបាច់ត្រូវបានការដកហូតទ្រព្យសម្បត្តិសម្រាប់គោលបំណងនេះ គេត្រូវចាត់ វិធានការសមស្រប ដើម្បីជៀសវាងកុំឲ្យមានឧបសគ្គដល់ការបំពេញមុខងារកុងស៊ុល ហើយប្រាក់សំណងនឹង ត្រូវបានប្រគល់ជូនទៅរដ្ឋដាក់កុងស៊ុលវិញឲ្យបានរួសរាន់ និងគ្រប់គ្រាន់។

### ៣.២.៣. ការមិនចោទប្រកាន់ត្រួតគ្នា និងទោស

តាមច្បាប់កម្ពុជា ពុំមានការចោទប្រកាន់ណាមួយអាចប្រព្រឹត្តប្រឆាំងនឹងបុគ្គលណាម្នាក់ ដែលត្រូវ បាន ជំនុំជម្រះជាស្ថាពរនៅឯបរទេសចំពោះបទល្មើសដដែល ហើយក្នុងករណីដែលមានការផ្តន្ទាទោស បុគ្គល នោះ បង្ហាញថាខ្លួនបានអនុវត្តទោសរបស់ខ្លួនរួចហើយ ឬក៏ទោសដែលត្រូវបានរលត់ដោយអាជ្ញាយុកាល[105]។ យើង អាចនិយាយបានថាមាត្រានេះ គឺមានគោលបំណង និងការការពាររាល់ការចោទប្រកាន់ពីរដង ឬធ្វើការ ជំនុំជម្រះ ពីរដងលើបទល្មើសតែមួយ ហើយក៏មិនអាចធ្វើការចោទប្រកាន់បានលើអាជ្ញាអស់ជំនុំឡើយ។ តុលាការកម្ពុជា ពុំអាចបើកសវនាការសារឡើងវិញ ឬក៏សម្រេចផ្តន្ទាទោស និងដាក់ឱ្យអនុវត្តទោសចំពោះ បុគ្គលណាម្នាក់ដែលត្រូវបានជំនុំជម្រះជាស្ថាពរនៅឯបរទេស ឬបានអនុវត្តទោសរួចរាល់ ឬបានផុត រលត់អាជ្ញាយុកាលដោយយោងតាមច្បាប់បរទេសរួចរាល់បានឡើយ។

ដោយយោងតាមមាត្រា ២០ អំពីការជំនុំជម្រះតែមួយលើក នៃច្បាប់ស្តីពីលក្ខន្តិកៈទីក្រុងរ៉ូមស្តីពី តុលាការព្រហ្មទណ្ឌអន្តរជាតិ បានចែងថា៖

១. លើកលែងតែមានចែងក្នុងច្បាប់លក្ខន្តិកៈនេះ គ្មានជនណាម្នាក់ត្រូវបានជំនុំជម្រះដោយតុលាការទាក់ទងលើ ការប្រព្រឹត្តដែលបានបង្កើតជាមូលដ្ឋាននៃបទល្មើសព្រហ្មទណ្ឌដែលជននោះត្រូវបានតុលាការសម្រេចឲ្យមាន ពិរុទ្ធភាព (អោយមានទោស) ឬសម្រេចឲ្យរួចខ្លួន (គ្មានទោស) ម្តងរួចទៅហើយនោះទេ។

---

[105] មាត្រា ២៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

២. គ្មានជនណាម្នាក់ត្រូវបានជំនុំជម្រះនៅក្នុងតុលាការមួយទៀត ចំពោះបទល្មើសព្រហ្មទណ្ឌដែលមានចែងនៅក្នុងមាត្រា៥ ដោយជននោះត្រូវបានតុលាការសម្រេចឲ្យមានពិរុទ្ធភាព ឬគ្មានពិរុទ្ធភាពរួចទៅហើយនោះទេ។

៣. គ្មានជនណាម្នាក់ ដែលត្រូវបានជំនុំជម្រះដោយតុលាការផ្សេងទៀតចំពោះការប្រព្រឹត្តដែលបានពណ៌នាផងដែរនៅក្នុងមាត្រា ៦ ៧ ឬ ៨ ត្រូវជំនុំជម្រះដោយតុលាការទាក់ទងទៅលើការប្រព្រឹត្តដូចគ្នាតែមួយទេ លើកលែងតែដំណើរការទាំងឡាយនៅក្នុងតុលាការមួយផ្សេងទៀតនោះ៖

**ក**. ត្រូវបានធ្វើឡើងសម្រាប់គោលបំណងលាក់បាំងជនដែលពាក់ព័ន្ធ ពីការទទួលខុសត្រូវខាងព្រហ្មទណ្ឌសម្រាប់បទល្មើសដែលឋិតនៅក្នុងយុត្តាធិការនៃតុលាការ។

**ខ**. បើមិនអញ្ចឹងទេត្រូវបានធ្វើឡើងដោយគ្មានឯករាជ្យ ឬដោយគ្មានភាពស្របតាមបទដ្ឋាននៃដំណើរការត្រឹមត្រូវតាមច្បាប់ដែលទទួលស្គាល់ដោយច្បាប់អន្តរជាតិ ហើយត្រូវបានធ្វើឡើងតាមរបៀបមួយ ដែលក្នុងកាលៈទេសៈនានាមិនស្របតាមចេតនាខ្លួនជនដែលពាក់ព័ន្ធនោះមករកយុត្តិធម៌[106]។

សរុបមកចំពោះបទល្មើសដែលប្រព្រឹត្តនៅក្រៅប្រទេស តុលាការកម្ពុជាគឺមានសមត្ថកិច្ចដោយយោងតាមការអនុវត្តច្បាប់ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចំពោះបទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដី ដែលនៅក្នុងនោះរួមមានករណីបទល្មើសប្រព្រឹត្តពលរដ្ឋដែលមានសញ្ជាតិខ្មែរចំពោះបទល្មើសជាបទឧក្រិដ្ឋ និងបទមជ្ឈិម និងនៅគ្រប់បទឧក្រិដ្ឋ ដែលជនរងគ្រោះមានសញ្ជាតិខ្មែរ ព្រមទាំងករណីបទឧក្រិដ្ឋដោយឡែកមួយចំនួន ទៀតដែលបានប្រព្រឹត្តមកលើកម្ពុជា។ ការកំណត់អំពីសមត្ថកិច្ចចំពោះបទល្មើសនៅក្រៅប្រទេស គឺជាគោលការណ៍មួយដើម្បីធានាការពារដល់សិទ្ធិ និងផលប្រយោជន៍របស់ប្រជនពលរដ្ឋខ្មែរ និងក៏ដូចជាការពារដល់ផលប្រយោជន៍របស់កម្ពុជា ដោយហេតុថាច្បាប់នៅឯបរទេសនោះ អាចមានការផ្តន្ទាទោសធ្ងន់ធ្ងរជាងច្បាប់នៅកម្ពុជា ឬក៏មានភាពចន្លោះប្រហោងណាមួយដែលនាំឱ្យជនល្មើសរួចផុតពីការផ្តន្ទាទោសជាអាទិ៍។ ព្រះរាជាណាចក្រកម្ពុជា គោរពនូវគោលការណ៍អធិបតេយ្យភាព និងមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់រដ្ឋបរទេស ហេតុដូចនេះ ដើម្បីអនុវត្តនូវសមត្ថកិច្ចនៃច្បាប់កម្ពុជានេះបាន គឺត្រូវតែមានការព្រមព្រៀងឯកភាពពីរដ្ឋបរទេសនោះតាមរយៈការចុះកិច្ចព្រមព្រៀងទ្វេភាគី។

ជាចុងក្រោយ បើទោះបីជាឧក្រិដ្ឋកម្មមួយ ឬមជ្ឈិមកម្មមួយត្រូវបានប្រព្រឹត្តនៅបរទេស ច្បាប់ព្រហ្មទណ្ឌកម្ពុជានឹងប្រកាសទទួលស្គាល់សមត្ថកិច្ចរបស់ខ្លួន ចំពោះអ្នកផ្តើមគំនិត ឬអ្នកសមគំនិត ឱ្យតែអ្នកផ្តើមគំនិត ឬអ្នកសមគំនិតនេះបានប្រព្រឹត្តសកម្មភាពជាសម្ភារៈ នៃការផ្តើមគំនិត ឬសមគំនិត នៅលើដែនដីកម្ពុជា ហើយបទល្មើសត្រូវតែផ្តន្ទាទោសដោយច្បាប់កម្ពុជា និងច្បាប់បរទេស ព្រមទាំងអត្ថិភាពនៃបទល្មើសកើតចេញ

---

[106] មាត្រា ២០ នៃច្បាប់ស្តីពី លក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ

ពីសេចក្តីសម្រេចជាស្ថាពររបស់តុលាការបរទេស។ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសទាំងឡាយដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ មាត្រា ១២ គោលការណ៍ដែនដីនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជាក្នុងរឿងក្តីព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសទាំងឡាយដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ដែនដីនៃព្រះរាជាណាចក្រកម្ពុជារួមបញ្ចូលទាំងលំហអាកាស និងសមុទ្រដែលមានចំណងចងភ្ជាប់នឹងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅព្រះរាជាណាចក្រកម្ពុជា ពិតជាមានសារៈសំខាន់ណាស់សម្រាប់អ្នកសិក្សា ក៏ដូចជាអ្នកអនុវត្តច្បាប់គ្រប់រូប ជាពិសេសសម្រាប់ ចៅក្រម ព្រះរាជអាជ្ញា នគរបាលយុត្តិធម៌។ល។ ហើយអ្វីដែលពិសេសជាងនេះទៅទៀតនោះវាពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ទណ្ឌិតដែលបានទទួលនូវផលប្រយោជន៍ពីការចូលជាធរមាននៃអត្ថបទច្បាប់ថ្មី ឬក្រមព្រហ្មទណ្ឌថ្មីនេះទៅលើគោលការណ៍ប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ដែលលុបចោលបទល្មើសណាមួយដែលខ្លួនបានប្រព្រឹត្តនៅក្នុងសម័យអន្តរកាល ហើយក្រោយមកក៏មានក្រមព្រហ្មទណ្ឌថ្មីយើងនេះបានចូលជាធរមាន ហើយបានលុបចោលនូវអំពើដែលបានប្រព្រឹត្តនោះចេញដោយពុំចាត់ ក្រោយមានការលុបចោលនូវបទល្មើសណាមួយដែលបានប្រព្រឹត្តថាជាបទល្មើសនោះទេ។ នេះក៏សម្រេចបានថានៅក្នុងសម័យអន្តរកាល ឬប្រព្រឹត្តមុនការចូលជាធរមាននៃក្រមព្រហ្មទណ្ឌថ្មីយើងនេះ ហើយអំពើនោះត្រូវច្បាប់ ក្រោយនេះពុំបានចាត់ថាជាបទល្មើសទេនោះ ហេតុនេះនាំអោយទណ្ឌិត ឬជនជាប់ចោទទាំងអស់ដែលត្រូវបាន ព្រះរាជអាជ្ញាបានបើកការស៊ើបអង្កេត ឬក៏សម្រេចចោទប្រកាន់ហើយនោះ ត្រូវតែបញ្ឈប់ការចោទប្រកាន់ ឬបញ្ឈប់ការអនុវត្តទោសតែម្តង។ នេះហើយជាអត្ថប្រយោជន៍ដែលជនល្មើសបានទទួលនៅក្រោមអានុភាពនៃច្បាប់ព្រហ្មទណ្ឌថ្មីនេះ ដោយសារការលុបចោលនូវបទល្មើសណាមួយ។

ចំពោះការអនុវត្តទោសដែលស្រាលជាង ឬធ្ងន់ជាងវិញ ក៏មានការចាំបាច់សម្រាប់ការអនុវត្តផងដែរ ដោយសារថា ចៅក្រមដែលសម្រេចសេចក្តីពីបញ្ហារណាមួយទៅលើអំពើណា ដែលបានប្រព្រឹត្តក្រោមកិច្ចនៃច្បាប់ចាស់ តែពុំទាន់បានចូលជាស្ថាពរនៅឡើយ ដោយសារតែមានការប្តឹងបន្តផ្សេងៗទៀត។ លុះក្រោយមកច្បាប់ថ្មី ក៏បានចែងពីអំពើដែលបានប្រព្រឹត្តដូចគ្នា គ្រាន់តែខុសគ្នានូវអតិប្បមារ និងអប្បមារប៉ុណ្ណោះ ដែលច្បាប់ថ្មីស្រាលជាងច្បាប់ចាស់នោះ គឺត្រូវអនុវត្តភ្លាមតែម្តង? ឬអាចនិយាយបានថាច្បាប់ថ្មីមានអានុភាពប្រតិសកម្មក្រោយការចូលជាធរមានចំពោះទោសដែលស្រាលជាង។ ក៏ប៉ុន្តែក្រមថ្មីនេះបានបញ្ជាក់បន្ថែមថា " ការផ្តន្ទាទោសដែលចូលជាស្ថាពរហើយនោះ ត្រូវអនុវត្តទោះបីទោសដែលប្រកាសនោះធ្ងន់ធ្ងរយ៉ាងណាក៏ដោយ " ។ នេះអាចបញ្ជាក់បានថាច្បាប់ថ្មីមានអានុភាពប្រតិសកម្មទៅលើអំពើណាដែលបានប្រព្រឹត្តហើយត្រូវបានតុលាការសម្រេចផ្តន្ទាទោសដែលមិនទាន់ចូលជាស្ថាពរប៉ុណ្ណោះ បើសិនតុលាការបានសម្រេចផ្តន្ទាទោស និងសេចក្តីសម្រេចនោះបានចូលជាស្ថាពរហើយ ទោសដែលចេញពីសេចក្តីសម្រេចនោះត្រូវតែអនុវត្ត ទោះបីជាទោសនេះធ្ងន់ធ្ងរជាងច្បាប់ថ្មីយ៉ាងណាក៏ដោយ។

ហើយចំពោះគោលការណ៍នៃការអនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងលំហវិញ គឺការអនុវត្ត ឬជាការកំណត់នូវភាពក្នុងដែនដី ឬក៏ក្រៅដែនដីនៃសមត្ថកិច្ចរបស់ច្បាប់ព្រហ្មទណ្ឌកម្ពុជា។ ចំពោះភាពជាដែនដី ច្បាប់ព្រហ្មទណ្ឌកម្ពុជា គឺមានវិសាលភាពអនុវត្តនៅលើដែនដីជាតិកម្ពុជាទាំងមូលដែលរួមមាន ដែនទឹក ដែនគោក ដែនអាកាស ជាដើម។ តែអំពើខ្លះពុំបានប្រព្រឹត្ត ឬក៏សម្រេចផលនៅកម្ពុជាទេ តែច្បាប់បានចាត់ថា " បទល្មើសត្រូវបានចាត់ ថាប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជានៅពេលដែលអំពើណាមួយនៃបទល្មើសនោះ បានប្រព្រឹត្តនៅ លើដែនដីនៃព្រះរាជាណាចក្រកម្ពុជា" ។ នេះសរបញ្ជាក់អោយឃើញថា បើទោះបីជាបទល្មើសណាមួយបាន ប្រព្រឹត្តនៅលើទឹកដីកម្ពុជា ឬក៏ប្រព្រឹត្តនៅរដ្ឋបរទេសក៏ដោយអោយតែមានបំពេញនូវល័ក្ខខណ្ឌណាមួយដែល ចេញពីកម្ពុជានោះ បទល្មើសនេះចាត់ថាបានប្រព្រឹត្តនៅកម្ពុជាផងដែរ។ ហើយចំពោះគោលការណ៍នៃការអនុវត្ត ច្បាប់ក្រៅដែនដីវិញ ក៏ច្បាប់ព្រហ្មទណ្ឌកម្ពុជានៅតែមានអានុភាពអនុវត្តផងដែរ បើទោះបីជាបទល្មើសនោះប្រព្រឹត្តនៅបរទេសក៏ដោយ តែដោយសារបទល្មើសនេះមានការជាប់ពាក់ព័ន្ធនឹងអធិបតេយ្យភាពរបស់កម្ពុជា ដូចជា **គោលការណ៍សញ្ជាតិ និងបទឧក្រិដ្ឋប្រឆាំងកម្ពុជា**។ ហើយដែលគោលការណ៍សញ្ជាតិនេះ គឺគិតទាំងជនល្មើស និងជនរងគ្រោះជាពលរដ្ឋខ្មែរទាំងពីរភេទហើយបើទោះបីជាជននេះបានទទួលសញ្ជាតិខ្មែរ ក្រោយអំពើចោទប្រកាន់ក៏ត្រូវទទួលបាននូវអត្ថប្រយោជន៍នេះផងដែរ។

សរុបជារួមមកវិញ ដែនអនុវត្តច្បាប់ព្រហ្មទណ្ឌនៅព្រះរាជាណាចក្រកម្ពុជាគឺពិតជាមានភាពចាំបាច់ក៏ដូចជាសារៈសំខាន់ខ្លាំងណាស់សម្រាប់ អ្នកអនុវត្តច្បាប់ដូចជា ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី នគរបាលយុត្តិធម៌ ពិសេសពិតជាមានភាពចាំបាច់យ៉ាងខ្លាំងចំពោះទណ្ឌិតដែលបានទទួលប្រយោជន៍ពី ច្បាប់ដែលលុបចោលបទល្មើស និងភាពប្រតិសកម្មនៃបទល្មើសដែលស្រាលជាងផងដែរ។ ហើយចំពោះគោលការណ៍នៃភាពជាដែនដីទាំងក្នុង និងក្រៅដែនដីក៏បានផ្តល់ភាពចាំបាច់ខ្លាំងដល់ជនល្មើស ក៏ដូចជាជនរងគ្រោះ ដែលជាជនជាតិខ្មែរផងដែរ។

# អនុសាសន៍

# អនុសាសន៍

ដោយបានឆ្លងកាត់ការស្រាវជ្រាវអស់រយៈពេលយ៉ាងយូរកន្លងមកនេះ ដែលពាក់ព័ន្ធនឹងប្រធានបទស្តីអំពី « **ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅព្រះរាជាណាចក្រកម្ពុជា** » យើងសង្កេតឃើញថាច្បាប់ដែលសភាបាន អនុម័តនៅមានភាពល្អប្រសើរយ៉ាងក្រៃលែង។ ការរៀបចំ និងការអនុម័តច្បាប់ គឺជាដំណាក់កាលសំខាន់មួយ ដែលឆ្លុះបញ្ចាំងពីការស្ថាបនាលទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ សម្រាប់ព្រះរាជាណាចក្រកម្ពុជា។ ដោយឡែកការអននុវត្តច្បាប់ ក៏ជាតំណាក់កាលសំខាន់ចម្បងផងដែរ ដើម្បីប្រសិទ្ធភាពនៃច្បាប់នោះ។ ហេតុដូច្នេះ ហើយការអប់រំ និងការផ្សព្វផ្សាយក្រមព្រហ្មទណ្ឌនេះ គឺជាដំណាក់កាលបន្ទាប់ដែលក្រសួងយុត្តិធម៌ត្រូវខិតខំរៀបចំឲ្យទូលំទូលាយបំផុតក្នុងគោលដៅលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋ និងអ្នកអនុវត្តច្បាប់ទូទាំងប្រទេស។ ក៏ប៉ុន្តែការអនុវត្តផ្សេងៗនៅតែមានខ្វះចន្លោះត្រង់ថា៖

**១. ការផ្សព្វផ្សាយ៖** ដូចយើងបានដឹងស្រាប់មកហើយថា ក្រោយការប្រកាសអោយប្រើនូវក្រមព្រហ្មទណ្ឌថ្មីយើងនេះ គឺក្រសួងយុត្តិធម៌ បានសហការជាមួយនឹងក្រសួងព័ត៌មានក្នុងការផ្សព្វផ្សាយនូវច្បាប់ថ្មីនេះ តាមរយៈមធ្យោបាយទូរគមនាគម៍ផ្សេងៗ ដើម្បីអោយអ្នកអនុវត្តច្បាប់ទាំងឡាយ ក៏ដូចជាពលរដ្ឋខ្លួនមានការយល់ដឹងអោយបានកាន់តែច្រើនអំពីបញ្ហាផ្លូវច្បាប់។ ប៉ុន្តែការផ្សព្វផ្សាយបែបនេះនៅមានភាពខ្វះចន្លោះ ព្រោះថាបើសិនជាអាជ្ញាធរមានសមត្ថកិច្ចបានធ្វើការផ្សព្វផ្សាយ ដោយមានការចុះផ្ទាល់ជាមួយពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួនដើម្បីផ្សព្វផ្សាយ នោះច្បាប់ដែលបានប្រកាសអោយប្រើនេះ គឺកាន់តែមានប្រសិទ្ធភាពអនុវត្ត ហើយពលរដ្ឋខ្លួនក៏យល់ដឹងច្រើនលើបញ្ហាផ្លូវច្បាប់ដែរ។

**២. ការចូលរួម៖** ការចូលរួមនៅក្នុងន័យនេះ គឺចង់សំដៅដល់ការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងការចូលរួមសម្តែងជាមតិយោបល់ទាំងឡាយណាដែលខ្លួនយល់ឃើញចំពោះថាគួរ ឬមិនគួរនៅពេលដែលសភាធ្វើការអនុម័តនូវអត្ថបទច្បាប់ណាមួយ ព្រោះថាបើសិនណាច្បាប់ដែលចេញសម្រាប់អោយពលរដ្ឋអនុវត្តតែច្បាប់នោះ ចេញមកពលរដ្ឋធ្វើការប្រឆាំង ឬសម្តែងការមិនពេញចិត្តផ្សេងៗ អញ្ចឹងតើច្បាប់នោះអនុវត្តទៅបានន័យអ្វី បើពលរដ្ឋខ្លួនអត់គាំទ្រផងនោះ។

**៣. ការអប់រំបណ្តុះបណ្តាល៖** ការបណ្តុះបណ្តាលនេះ គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ប្រទេសជាតិនានានៅទូទាំងសាកលលោក ព្រោះថាបើច្បាប់ចែងមកល្អហើយ តែមន្ត្រីអនុវត្តមិនល្អនោះប្រាកដណាស់ និងធ្វើអោយរាស្ត្ររងទុក្ខទឹកភ្នែកជាក់ជាមិនខាន។ ដូច្នេះ គុណភាពមន្ត្រី គឺត្រូវតែមានសមត្ថភាព និងចំណេះជំនាញពិតប្រាកដទើបអាចអោយសង្គមជាតិខ្លួនរីកចម្រើនបន្តរទៅមុខបានពិសេសក៏បានធ្វើអោយពលរដ្ឋខ្លួនមានភាពកក់ក្តៅ និងទំនុកចិត្តកាន់តែច្រើនទៅលើមន្ត្រីអនុវត្តផងដែរ។

# ឯកសារយោង

## ១. ប្រភពឯកសារជាបទដ្ឋានគតិយុត្ត

### ក. បទដ្ឋានគតិយុត្តជាតិ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានប្រកាសឲ្យប្រើប្រាស់ជាផ្លូវការដោយព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩
- ច្បាប់ព្រហ្មទណ្ឌអន្តរកាល ត្រូវបានចូលជាធរមាននៅថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩២
- បទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជា ក្នុងសម័យអន្តរកាល ដោយសេចក្តីសម្រេចចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ សេចក្តីព្រាង ក្រមព្រហ្មទណ្ឌថ្មី ចុះថ្ងៃទី៥ ខែមិនា ឆ្នាំ២០០៣
- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០៨០៧/០២៤ នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧
- ច្បាប់ស្តីពីអាកាសចរស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០១០៨/០០៣ នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៧
- អនុក្រឹត្យស្តីពី សន្តិសុខនាវា និង សន្តិសុខបបនីយកណ្ឌផែ ត្រូវបានប្រកាសអោយប្រើដោយ អនុក្រឹត្យ លេខ ៤០ អនក្រសក នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៦
- សេចក្តីពន្យល់អំពីក្រមព្រហ្មទណ្ឌ រៀបរៀងដោយ ឯកឧត្តម សេង នាង ចៅក្រមតុលាការកំពូល

### ខ. បទដ្ឋានគតិយុត្តអន្តរជាតិ

- កតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និងនយោបាយ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦
- អនុសញ្ញាស្តីពី ការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៤៨
- សេចក្តីប្រកាសជាសកលស្តីពី សិទ្ធិមនុស្ស ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨
- អនុសញ្ញាស្តីពី សិទ្ធិកុមារ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩

- សន្ធិសញ្ញាស្តីពី បត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ចុះថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ១៩៦៣
- សន្ធិសញ្ញាស្តីពី បត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៦៣
- សន្ធិសញ្ញាស្តីពី បត្យាប័នរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៦៣
- អនុសញ្ញាអង្គការសហប្រជាជាតិស្តីពី ច្បាប់សមុទ្រ
- អនុសញ្ញាទីក្រុងវីយែនស្តីពី ទំនាក់ទំនងការទូត ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៦១ ព្រះរាជាណាចក្រកម្ពុជា បានផ្តល់សច្ចាប័នលើអនុសញ្ញាទីក្រុងវីយែន ស្តីពីទំនាក់ទំនងការទូត នៅថ្ងៃទី៣១ ខែសីហា ១៩៦៥ និងចូលជាធរមាននៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៦៥ ច្បាប់ស្តីពី លក្ខន្តិកៈទីក្រុងរ៉ូមស្តីពី តុលាការព្រហ្មទណ្ឌអន្តរជាតិ
- ច្បាប់ស្តីពី ការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃអនុសញ្ញាស្តីពី ការបង្ក្រាបអំពើខុសច្បាប់ទៅនឹងសុវត្ថិភាពនៃការធ្វើនាវាចរណ៍តាមដែនសមុទ្រ ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៥/០២៦ នៅថ្ងៃទី២៣ ខែ វិច្ឆិកា ឆ្នាំ២០០៥
- ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើអនុសញ្ញាទីក្រុងវីយែនស្តីពី ទំនាក់ទំនងកុងស៊ុល ប្រកាសឲ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០៤០៥/០០៧ នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ ២០០៥

## ២. ឯកសារជាសៀវភៅ

- នីតិព្រហ្មទណ្ឌទូទៅ រៀបរៀងដោយសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ កែសម្រួលដោយលោកស្រី ចាំង ស៊ីណាត ឆ្នាំ២០១២
- នីតិព្រហ្មទណ្ឌថ្នាក់បរិញ្ញាបត្រ រៀបរៀងដោយសាស្ត្រាចារ្យ ហ៊ី សោភា ប្រធានតុលាការខេត្តកណ្តាល
- បាឋកថាស្តីពីគោលការណ៍គ្រឹះធំៗនៃក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ដែលរៀបរៀងដោយឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
- មេរៀននីតិព្រហ្មទណ្ឌខ្មែរ ក្រោមសហប្រតិបត្តិការបារាំង គម្រោងទ្រទ្រង់នីតិរដ្ឋ
- សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ដែនអនុវត្តច្បាប់ព្រហ្មទណ្ឌ ឆ្នាំ២០០៩ របស់និស្សិតឈ្មោះ ឡឹក សាលីន និង លី ឆោម សាស្ត្រាចារ្យណែនាំ លោក ហោ សុភ័ណ្ឌ

- សារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ដែនអនុវត្តន៍ក្នុងលំហនៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩ របស់និស្សិតឈ្មោះ ហោ ឈុនឡុង និង អ៊ឹង សុផា សាស្ត្រាចារ្យណែនាំ លី ច័ន្ទតុលា
- នីតិព្រហ្មទណ្ឌទូទៅខ្មែរ រៀបរៀង និងវាយអត្ថបទដោយ កៅ សីហា កំពុងសិក្សាថ្នាក់បណ្ឌិតច្បាប់ សាស្ត្រាចារ្យច្បាប់ និងជាមន្ត្រីរាជការនៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ឆ្នាំ២០១៣
- នីតិព្រហ្មទណ្ឌ៖ ផ្នែកទូទៅ រៀបរៀងដោយ សាន ប៊ុនធឿន ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

### ៣. ប្រភពឯកសារផ្សេងៗ

- ប្រសាសន៍របស់ ឯកឧត្តម កើត រឹទ្ធ ឯកឧត្តម ប៊ុន ហុន ឯកឧត្តម ផូវ សំភី ក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ ស្តីពី ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលរៀបចំឡើងដោយក្រសួងយុត្តិធ៌សហការជាមួយ ក្រសួងព័ត៌មាន តាមរយៈទូរទស្សន៍ជាតិកម្ពុជា ឆ្នាំ២០១០
- អត្ថបទស្តីពី គោលការនីត្យានុគោលភាពនៃបទល្មើស និងទោស ដោយ ផៃ ចេងសេង ការផ្សាយរបស់ ក្រុមត្រាជូ
- ការពន្យល់បន្ថែមពីអត្ថបទច្បាប់នៃគេហទំព័រ Law Asia ។

# ឧបសម្ព័ន្ធ

**UNITED NATIONS**
UNITED NATIONS TRANSITIONAL
AUTHORITY IN CAMBODIA
(UNTAC)

**NATIONS UNIES**
AUTORITE PROVISOIRE DES NATIONS
UNIES AU CAMBODGE
(APRONUC)

# បទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ
# ច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌ
# សំរាប់អនុវត្តនៅប្រទេសកម្ពុជា
# ក្នុងសម័យអន្តរកាល




*PROVISIONS RELATING TO THE JUDICIARY AND CRIMINAL LAW AND PROCEDURE APPLICABLE IN CAMBODIA DURING THE TRANSITIONAL PERIOD*

*DISPOSITIONS RELATIVES AU SYSTEME JUDICIAIRE AU DROIT PENAL ET ALA PROCEDURE PENALE APPLICABLES AU CAMBODGE PENDANTLA PERIODE TRANSITOIRE*

២១៩៧

# <u>បទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌ សំរាប់អនុវត្តនៅប្រទេសកម្ពុជា ក្នុងសម័យអន្តរកាល</u>

សេចក្តីសំរេចចុះថ្ងៃទី ១០ កញ្ញា ១៩៩២

**ក្រុមប្រឹក្សាជាតិជាន់ខ្ពស់** ដែលចាប់ពីពេលនេះទៅហៅថា «SNC» អេស អិន ស៊ី

- <u>ដោយសំអាងលើ</u>អំណាចទាំងឡាយ ដែលប្រគល់ឡើងតាមមាត្រា ៣ នៃកិច្ចព្រមព្រៀងស្តីអំពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជាចុះថ្ងៃទី ២៣ តុលា ១៩៩១ ដែលចាប់ពីពេលនេះទៅហៅថា «កិច្ចព្រមព្រៀង» ទុកដូចជាអង្គការពេញច្បាប់តែមួយគត់ ហើយជាព្រភពនៃអាជ្ញាធរកម្ពុជា,

- <u>ដោយរំលឹកឡើងវិញ</u>នូវមាត្រា៦ នៃកិច្ចព្រមព្រៀងដែលនៅក្នុងនោះ SNC បានប្រគល់ជូនដល់អង្គការសហប្រជាជាតិ នូវអំណាចទាំងអស់ដែលចាំបាច់សំរាប់អនុវត្តកិច្ចព្រមព្រៀង,

- <u>ដោយរំលឹកបន្ថែមទៀតថា</u> ក្រុមប្រឹក្សាសន្តិសុខ នៃអង្គការសហប្រជាជាតិ តាមរយៈសេចក្តីសម្រេចចិត្ត ៧៤៥ (១៩៩២) បានរៀបចំអាជ្ញាធរបណ្តោះអាសន្ន នៃអង្គការសហប្រជាជាតិនៅប្រទេសកម្ពុជា ដែលចាប់ពីពេលនេះតទៅហៅថា «អ៊ុនតាក់» ស្របតាមមាត្រា ២ នៃកិច្ចព្រមព្រៀង ដើម្បីបំពេញតួនាទីភារកិច្ច ដែលចែងឡើងក្នុងឧបសម្ព័ន្ធទី១ នៃកិច្ចព្រមព្រៀង,

- <u>ដោយយល់ថា</u> អ៊ុនតាក់ ត្រូវបានទទួលបេសកកម្មមួយ, ស្របតាមមាត្រា ៦ និង ១៦ នៃកិច្ចព្រមព្រៀងប៉ារីស និងផ្នែក ខ និង ង នៃឧបសម្ព័ន្ធទី១, ក្នុងការត្រួតពិនិត្យផ្ទាល់ ឬ ការពិនិត្យត្រួតត្រាលើវិស័យទាំងឡាយ ស្តីអំពីការរក្សារបៀបរៀបរយ និងការគោរពច្បាប់, ការការពារសិទ្ធិមនុស្ស, ការអនុវត្តន៍ច្បាប់ និងដំណើរការក្នុងប្រព័ន្ធតុលាការ,

- <u>ដោយយល់ឃើញថែមទៀតថា</u> ភាគីទាំងឡាយនៃកិច្ចព្រមព្រៀង បានទទួលស្គាល់ដោយជាក់លាក់, ក្នុងមាត្រា១៥, ថាមនុស្សគ្រប់រូបនៅប្រទេសកម្ពុជា និងជនភៀសខ្លួនទាំងអស់ និងជនផ្លាស់ប្តូរទីកន្លែងទាំងអស់នៅកម្ពុជា ត្រូវមានសិទ្ធិ និងសេរីភាពដែលមានចែងនៅក្នុងសេចក្តីថ្លែងការណ៍សាកលស្តីអំពីសិទ្ធិមនុស្ស និងក្នុងបណ្តាកិច្ចព្រមព្រៀងអន្តរជាតិទាំងឡាយដែលទាក់ទងនឹងសិទ្ធិមនុស្ស

- ដោយយល់ឃើញម្យ៉ាងទៀតថា SNC បានយល់ព្រមចូលរួមក្នុង កតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ព្រមទាំង កតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិខាងវិស័យសេដ្ឋកិច្ចសង្គម និងវប្បធម៌ នៅថ្ងៃទី ២០ មេសា ១៩៩២ ហើយថាឧបករណ៍ទាំងនេះបានចូលជាធរមាននៅប្រទេសកម្ពុជានៅថ្ងៃ ២៦ សីហា ១៩៩២,

- ដោយមានកង្វល់ថា បណ្តារចនាសម្ព័ន្ធ, ច្បាប់ និងស្ថាប័នតុលាការនៅប្រទេសកម្ពុជាមិនបំពេញអោយបានពេញលេញតាមការតម្រូវរបស់កិច្ចព្រមព្រៀងប៉ារីស ព្រមទាំងពេលខ្លះមានការខ្វះខាតមួយផ្នែក ឬពុំទាន់មានអ្វីទាល់តែសោះ ហើយបើតាមការពិនិត្យពិច័យ គឺមិនសមស្របដើម្បីធានាអោយមានរបៀបរៀបរយ និងសិទ្ធិមនុស្ស នៅតាមទីកន្លែងនានាជាច្រើនក្នុងដែនដី,

- ដោយទទួលស្គាល់ថា ការទាំងនេះត្រូវនៅក្រោមការទទួលខុសត្រូវរបស់ UNTAC ដើម្បីសំរួលការរៀបចំរចនាសម្ព័ន្ធទាំងឡាយ ច្បាប់ និងស្ថាប័នតុលាការ នៅកន្លែងណាដែលខ្វះខាត ហើយជួយកែលំអកន្លែងណាដែលមានរួចហើយ ដើម្បីអោយសមស្របតាមការតម្រូវចាំបាច់នៃកិច្ចព្រមព្រៀង,

- ដោយមានជំនឿជាក់ទៅលើសេចក្តីត្រូវការជាបន្ទាន់ ដើម្បីបង្ហាញយ៉ាងច្បាស់ជូនភាគីកម្ពុជា នូវក្បួនច្បាប់ដែលត្រូវអនុវត្តទូទាំងប្រទេសកម្ពុជា និង នីតិវិធីតុលាការ ដែលត្រូវយកមកប្រតិបត្តិ ដើម្បីធានាអោយមានការអនុវត្តន៍ជាក់ស្តែង ក្នុងដំណាក់កាលអន្តរកាល,

- ដោយជឿជាក់ថែមទៀតថា ការអនុវត្តន៍ក្បួនច្បាប់ និងនីតិវិធីនេះ ជាការចាំបាច់ដើម្បីធានាបរិយាកាសនយោបាយអព្យាក្រឹត និងរៀបចំការបោះឆ្នោតសេរី និងតាមសមធម៌,

**ជូរច្នះ អនុម័ត** យកបទបញ្ញត្តិអស់ទាំងនេះ ដែលពាក់ព័ន្ធដល់របៀបចាត់ចែងតុលាការច្បាប់ព្រហ្មទ័ណ្ឌ និងនីតិវិធីព្រហ្មទ័ណ្ឌ សំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងរយៈពេលអន្តរកាល ហើយ **ធ្វើសំណូមពរ** ជាឱឡារិកដល់ភាគីកម្ពុជាទាំងអស់ ដើម្បីអោយអនុវត្តដោយសុទ្ធចិត្តរហូតដល់សភានីតិបញ្ញត្តិ ដែលកើតឡើងពីការបោះឆ្នោត កែសំរួលបញ្ញត្តិទាំងនេះ ឬអនុម័តយកច្បាប់ថ្មីទៀតនៅក្នុងវិស័យនេះ ។

# ព្រះរាជក្រម

នស/រកម/១១០៩/០១៧

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៦ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ក្រម

# ព្រហ្មទណ្ឌ

# គន្ថីទី ១

# បទប្បញ្ញត្តិទូទៅ

## មាតិកាទី ១

## ច្បាប់ព្រហ្មទណ្ឌ

### ជំពូកទី ១

### គោលការណ៍ទូទៅ

**មាត្រា ១.–** ដែនអនុវត្តនៃច្បាប់ព្រហ្មទណ្ឌ

ច្បាប់ព្រហ្មទណ្ឌកំណត់បទល្មើស ចង្អុលបង្ហាញបុគ្គលដែលអាចត្រូវបានប្រកាសថាជាអ្នកទទួលខុសត្រូវចំពោះបទល្មើស និងកំណត់ទោស ព្រមទាំងរបបនៃការអនុវត្តទោសនេះ ។

នៅក្នុងករណីចាំបាច់ បទដ្ឋានគតិយុត្តដែលចេញដោយអង្គការនីតិប្រតិបត្តិអាចចែងពីបទលហុដែលត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់ប៉ុណ្ណោះ ។

**មាត្រា ២.–** និយមន័យ និងចំណាត់ថ្នាក់នៃបទល្មើស

ច្បាប់បញ្ញត្តថា អំពើខ្លះរបស់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបង្កចលាចលដល់សង្គមជាបទល្មើស ។ បទល្មើសត្រូវបានចាត់ថ្នាក់ជា បទឧក្រិដ្ឋ បទមជ្ឈិម និង បទលហុ នៅតាមទម្ងន់នៃបទល្មើសនោះ ។

**មាត្រា ៣.–** គោលការណ៍នីត្យានុកូលភាព

មានតែអំពើដែលបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន ។

មានតែទោសដែលមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន នៅពេលដែលបទល្មើស ត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន ។

**មាត្រា ៤.–** ចេតនាប្រព្រឹត្តបទល្មើស

គ្មានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត ។

ប៉ុន្តែក្នុងករណីដែលច្បាប់បានចែងទុកមុន បទល្មើសមួយអាចកើតចេញពីការមិនប្រុងប្រយ័ត្ន ការខ្ជីខ្ជា ការធ្វេសប្រហែស ឬ ការមិនគោរពកាតព្វកិច្ចដោយឡែកណាមួយ ។

**មាត្រា ៥.–** ការបកស្រាយច្បាប់ព្រហ្មទណ្ឌ

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់ត្រូវបកស្រាយយ៉ាងតឹងរ៉ឹង ។ ចៅក្រមមិនអាចពង្រីកវិសាលភាពអនុវត្ត ឬ ប្រព្រឹត្តតាមសទិសភាពបានឡើយ ។

**មាត្រា ៦.–** ការប្រកាសទោស

គ្មានទោសណាមួយដែលអាចត្រូវយកមកអនុវត្តបានឡើយ ប្រសិនបើទោសនោះ មិនត្រូវបានប្រកាសដោយតុលាការទេ ។

**មាត្រា ៧.–** លក្ខខណ្ឌនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ដែនអនុវត្តច្បាប់កម្ពុជាក្នុងលំហ ត្រូវបានកំណត់ដោយបទប្បញ្ញត្តិនៃក្រមនេះ លើកលែងតែមានសន្ធិសញ្ញាអន្តរជាតិ ។

**មាត្រា ៨.–** អវត្តមាននៃនិទណ្ឌភាពក្នុងបទល្មើសធ្ងន់ធ្ងរខាងនីតិមនុស្សធម៌អន្តរជាតិ

បទប្បញ្ញត្តិនៃក្រមនេះ ពុំអាចនាំឱ្យមានការបង្កើតនូវស្ថានភាពយុត្តិនិសេធ ចំពោះជនរងគ្រោះនៃបទល្មើសធ្ងន់ធ្ងរ ដែលកំណត់ដោយច្បាប់ដោយឡែកទាក់ទងដល់ការរំលោភនីតិមនុស្សធម៌អន្តរជាតិ ទំនៀមទម្លាប់អន្តរជាតិ ឬ អនុសញ្ញាអន្តរជាតិ ដែលទទួលស្គាល់ដោយព្រះរាជាណាចក្រកម្ពុជាឡើយ ។

## ជំពូកទី ២

## ការអនុវត្តច្បាប់ព្រហ្មទណ្ឌនៅក្នុងពេលវេលា

**មាត្រា ៩.–** ការអនុវត្តច្បាប់ដែលលុបចោលបទល្មើស

បទប្បញ្ញត្តិថ្មីដែលលុបចោលបទល្មើសណាមួយនោះត្រូវអនុវត្តភ្លាម ។ អំពើដែលប្រព្រឹត្តនៅមុនបទប្បញ្ញត្តិនេះចូលជាធរមាន មិនអាចត្រូវចោទប្រកាន់ទៀតឡើយ ។ ការចោទប្រកាន់ដែលកំពុងប្រព្រឹត្តទៅនោះ ត្រូវបញ្ចប់ ។

ប្រសិនបើការផ្តន្ទាទោសជាស្ថាពរត្រូវបានប្រកាសរួចមកហើយ ទោសដែលចេញអំពីការផ្តន្ទាទោសនេះ មិនត្រូវអនុវត្តទេ ឬ ត្រូវតែឈប់អនុវត្ត ។

ការអនុវត្តច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង ឬ ធ្ងន់ជាង

ប្បញ្ញត្តិថ្មីដែលចែងអំពីទោសដែលស្រាលជាងត្រូវអនុវត្តភ្លាម ។ ប៉ុន្តែការផ្តន្ទា-

ទោសដែលជាស្ថាពរហើយនោះ ត្រូវអនុវត្ត ទោះបីទោសដែលប្រកាសនោះធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ។

បទប្បញ្ញត្តិថ្មីដែលចែងអំពីទោសធ្ងន់ជាង នឹងត្រូវអនុវត្តតែទៅលើអំពើដែលបានប្រព្រឹត្តក្រោយការចូលជាធរមាននៃបទប្បញ្ញត្តិនោះ ។

**មាត្រា ១១.-** សុពលភាពនៃកិច្ចនីតិវិធី

ការអនុវត្តភ្លាមនៃបទប្បញ្ញត្តិថ្មី គ្មានអានុភាពទៅលើសុពលភាពនៃកិច្ចនីតិវិធី ដែលបានបំពេញស្របតាមបទប្បញ្ញត្តិចាស់ឡើយ ។

## ជំពូកទី ៣
## ការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជានៅក្នុងលំហ
### ផ្នែកទី ១
### បទល្មើសដែលបានប្រព្រឹត្ត ឬ ចាត់ទុកថាបានប្រព្រឹត្តនៅលើដែនដី នៃព្រះរាជាណាចក្រកម្ពុជា

**មាត្រា ១២.-** គោលការណ៍ដែនដីនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសទាំងឡាយដែលបានប្រព្រឹត្តទៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

ដែនដីនៃព្រះរាជាណាចក្រកម្ពុជា រួមបញ្ចូលទាំងលំហអាកាស និងសមុទ្រ ដែលមានចំណងចងភ្ជាប់នឹងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១៣.-** ទីកន្លែងប្រព្រឹត្តបទល្មើស

បទល្មើសត្រូវបានចាត់ទុកថាប្រព្រឹត្តទៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជានៅពេលដែលអំពើណាមួយនៃបទល្មើសនោះ បានប្រព្រឹត្តទៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១៤.-** បទល្មើសដែលបានប្រព្រឹត្តនៅក្នុងនាវាកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងនាវា [illegible] សញ្ជាតិខ្មែរ ទោះបីជានាវានោះស្ថិតនៅទីណាក៏ដោយ ។

**មាត្រា ១៥.-** បទល្មើសដែលបានប្រព្រឹត្តនៅក្នុងនាវាបរទេស

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងនាវាបរទេសដែលអាជ្ញាធរកម្ពុជាបានទទួលការអនុញ្ញាតឱ្យពិនិត្យមើល ឬ ឱ្យចាប់នាវាតាមអំណាចនៃកិច្ចព្រមព្រៀងអន្តរជាតិ ។

**មាត្រា ១៦.-** បទល្មើសដែលបានប្រព្រឹត្តនៅក្នុងអាកាសយានកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសដែលប្រព្រឹត្តនៅក្នុងអាកាសយានដែលចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ទោះបីជាអាកាសយាននោះស្ថិតនៅទីណាក៏ដោយ ។

**មាត្រា ១៧.-** ការអនុវត្តច្បាប់ព្រហ្មទណ្ឌកម្ពុជាចំពោះអំពើដែលបានចាប់ផ្តើមប្រព្រឹត្តនៅកម្ពុជា

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបុគ្គលគ្រប់រូបដែលជាអ្នកផ្តើមគំនិត ឬ អ្នកសមគំនិតនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងបទឧក្រិដ្ឋ ឬ បទមជ្ឈិម ដែលប្រព្រឹត្តនៅឯបរទេស ប្រសិនបើលក្ខខណ្ឌទាំងពីរចូលខាងក្រោមនេះ ត្រូវបានបំពេញ :

-បទល្មើសត្រូវផ្តន្ទាទោសតាមច្បាប់កម្ពុជា និងតាមច្បាប់បរទេសផង និង

-អត្ថិភាពនៃបទល្មើស ត្រូវបានបញ្ជាក់ដោយសេចក្តីសម្រេចជាស្ថាពររបស់តុលាការបរទេស ។

**មាត្រា ១៨.-** ការកំណត់បទល្មើសប្រព្រឹត្តដោយនីតិបុគ្គល

ការដាក់ឈ្មោះបទល្មើសដែលប្រព្រឹត្តដោយនីតិបុគ្គលថាជា បទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុ ត្រូវកំណត់ដោយទណ្ឌកម្មដែលទទួលរងដោយរូបវន្តបុគ្គល ។

## ផ្នែកទី ២

## បទល្មើសដែលបានប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា

**មាត្រា ១៩.-** បទឧក្រិដ្ឋ ឬ បទមជ្ឈិមប្រព្រឹត្តដោយពលរដ្ឋខ្មែរ

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើគ្រប់បទឧក្រិដ្ឋដែលប្រព្រឹត្តដោយពលរដ្ឋខ្មែរនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទមជ្ឈិមដែលប្រព្រឹត្តដោយពលរដ្ឋខ្មែរ នៅក្នុងប្រទេសក្រៅណាមួយ ប្រសិនបើអំពើនោះត្រូវបានផ្តន្ទាទោសតាមច្បាប់នៃប្រទេសនោះផងដែរ ។

បទប្បញ្ញត្តិទាំងនេះត្រូវអនុវត្តផងដែរ ទោះបីជាជនជាប់ចោទបានទទួលសញ្ជាតិខ្មែរក្រោយអំពើដែលចោទប្រកាន់នេះក៏ដោយ ។

**មាត្រា ២០.- ជនរងគ្រោះជាជនជាតិខ្មែរ**

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវបានអនុវត្តទៅលើគ្រប់បទឧក្រិដ្ឋដែលប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជាដោយពលរដ្ឋខ្មែរ ឬ ដោយជនបរទេសទៅលើជនរងគ្រោះដែលមានសញ្ជាតិខ្មែរ នៅក្នុងពេលដែលបទល្មើសត្រូវបានប្រព្រឹត្ត ។

**មាត្រា ២១.- ការធ្វើបណ្តឹងចោទប្រកាន់**

នៅក្នុងករណីដែលមានចែងនៅក្នុងមាត្រា ១៩(បទឧក្រិដ្ឋ ឬ បទមជ្ឈិមប្រព្រឹត្តដោយពលរដ្ឋខ្មែរ) និងមាត្រា ២០(ជនរងគ្រោះជាជនជាតិខ្មែរ) នៃក្រមនេះ ការចោទប្រកាន់អាចប្រព្រឹត្តទៅបានតាមបណ្តឹងរបស់អយ្យការតែប៉ុណ្ណោះ ។ ការចោទប្រកាន់ត្រូវតែមានបណ្តឹងពីជនរងគ្រោះ ឬ ពីសិទ្ធិវន្ត ឬ បណ្តឹងបរិហារជាផ្លូវការរបស់អាជ្ញាធរនៃប្រទេសដែលជាទីកន្លែងដែលអំពើនោះបានប្រព្រឹត្ត ។

**មាត្រា ២២.- សមត្ថកិច្ចដោយឡែកចំពោះបទឧក្រិដ្ឋដោយឡែក**

ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើស ដែលប្រព្រឹត្តនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា ហើយបើបទល្មើសនោះជា :

១-បទល្មើសប្រឆាំងនឹងសុវត្ថិភាពនៃព្រះរាជាណាចក្រកម្ពុជា ។

២-បទល្មើសក្លែងត្រាផ្លូវការនៃព្រះរាជាណាចក្រកម្ពុជា ។

៣-បទល្មើសក្លែងរូបិយវត្ថុ និងធនបត្រជាតិ ដែលមានតម្លៃស្របច្បាប់នៅព្រះរាជាណាចក្រកម្ពុជា ។

៤-បទល្មើសប្រឆាំងនឹងភ្នាក់ងារទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ។

៥-បទល្មើសប្រឆាំងនឹងទីតាំងទូត ឬកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២៣.- ការមិនចោទប្រកាន់ត្រួតគ្នា និងទោស

ពុំមានការចោទប្រកាន់ណាមួយអាចប្រព្រឹត្តប្រឆាំងនឹងបុគ្គលណាម្នាក់ ដែលត្រូវបានជំនុំជម្រះជាស្ថាពរនៅបរទេសចំពោះអំពើល្មើសដដែល ហើយក្នុងករណីដែលមានការផ្តន្ទាទោស បុគ្គលនោះបានបង្ហាញថាខ្លួនបានអនុវត្តទោសរបស់ខ្លួនរួចហើយ ឬ ក៏ទោសត្រូវបានរលត់ដោយការផុតអាជ្ញាយុកាល ។

## មាតិកាទី ២

## ការទទួលខុសត្រូវព្រហ្មទណ្ឌ

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ២៤.-** គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

បុគ្គលម្នាក់ៗ ទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ ។

**មាត្រា ២៥.-** និយមន័យនៃចារី

ត្រូវចាត់ទុកជាចារី ចំពោះបុគ្គលណាដែលប្រព្រឹត្តបទល្មើសដែលត្រូវចោទប្រកាន់។

ត្រូវចាត់ទុកជាចារីផងដែរ ចំពោះបុគ្គលណាដែលប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬ ក្នុងករណីដែលច្បាប់បានចែងទុក ចំពោះបទមជ្ឈិម ។

**មាត្រា ២៦.-** និយមន័យនៃសហចារី

ត្រូវចាត់ទុកជាសហចារី កាលណាមានបុគ្គលច្រើននាក់ បានព្រមព្រៀង ប្រព្រឹត្តបទល្មើសរួមគ្នាដោយផ្ទាល់ ។

ត្រូវចាត់ទុកជាសហចារីផងដែរ កាលណាមានបុគ្គលច្រើននាក់បានព្រមព្រៀងប៉ុនប៉ងប្រព្រឹត្តបទឧក្រិដ្ឋ ឬ បទមជ្ឈិមដោយផ្ទាល់ក្នុងករណីដែលច្បាប់បានចែងទុក ។

**មាត្រា ២៧.-** និយមន័យនៃការប៉ុនប៉ង

ការប៉ុនប៉ងក្នុងបទឧក្រិដ្ឋ ឬ ក្នុងករណីដែលច្បាប់បានចែងទុកក្នុងបទមជ្ឈិម អាចត្រូវផ្តន្ទាទោសបាន កាលណាលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ :

-ចារីបានចាប់ផ្តើមអនុវត្តបទល្មើស មានន័យថា ចារីបានប្រព្រឹត្តអំពើដែល

ឆ្នាំទី ២ លេខ ២ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០២ រាជកិច្ច ទំព័រ ៧៥

នស/រកម/០១០២/០០៤

# ព្រះរាជក្រម

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ដែលរដ្ឋសភាបានអនុម័តកាល ពីថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៧ នីតិកាលទី ២ និងដែលព្រឹទ្ធសភាបានអនុម័តលើកចោលពុំពិចារណាលើច្បាប់នេះព្រោះមិនស្របនឹងទម្រង់ច្បាប់ កាលពីថ្ងៃទី០៦ ខែ ធ្នូ ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើក ទី ៦ នីតិកាលទី ១ ប៉ុន្តែដោយយោងតាមវាក្យខ័ណ្ឌទី១ និងទី២ នៃមាត្រា១១៣ថ្មី នៃរដ្ឋធម្មនុញ្ញ គណៈកម្មាធិការអចិន្ត្រៃយ៍របស់រដ្ឋសភាបានពិនិត្យឃើញថា អត្ថបទច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ដែលរដ្ឋសភាបានពិនិត្យរួចហើយ។ ដែលព្រឹទ្ធសភាមិនព្រមផ្តល់យោបល់លើខ្លឹមសារនៃច្បាប់នេះត្រូវចាត់ទុកជាជាបករការ ហើយ ដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

# ច្បាប់
# ស្តីពី
# ស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ

**មាត្រា ១.- គោលបំណង**

ច្បាប់នេះមានគោលបំណងកំណត់ស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ដើម្បីពង្រឹងវិស័យសន្តិសុខសាធារណៈ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.- មធ្យោបាយបង្ហាញភស្តុតាង**

១-សាក្សីទាំងអស់ដែលមានឈ្មោះក្នុងសំណុំរឿង រួមទាំងមន្ត្រីនគរបាលយុត្តិធម៌ផង ត្រូវតែបានអនុញ្ញាតនិយាយជូនតុលាការស្តាប់ ។ សាក្សីអាចត្រូវសួរដេញដោលពីសំណាក់ភាគីរដ្ឋប្បវេណី ឬទីប្រឹក្សា ពីសំណាក់ជនជាប់ចោទ ឬទីប្រឹក្សា ហើយនិងពីសំណាក់ព្រះរាជអាជ្ញា ។

២-នៅពេលជំនុំជម្រះ ភស្តុតាងទាំងអស់រួមទាំងកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ផង ត្រូវលើកយកមកជជែកវែកញែក ហើយភស្តុតាងនិងកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ទាំងនោះ មិនអាចចាត់ទុកជាភស្តុតាងដែលមិនអាចច្រានចោលបានទេ ។

៣-បណ្តាពាក្យសារភាពរបស់ជនជាប់ចោទទាំងឡាយ ដែលមិនស៊ីសង្វាក់គ្នាទៅនឹងដើមកំណើតនៃភស្តុតាងទេនោះ នោះក្នុងករណីណាក៏ដោយ មិនអាចចាត់ទុកជាមូលដ្ឋានសម្រាប់ផ្តន្ទាទោសបានឡើយ ។ ពាក្យសារភាពដែលបានមកអំពីការបង្ខិតបង្ខំតាមបែបណាមួយក៏ដោយ ត្រូវទុកជាមោឃៈ ។ ការសុំទុកជាមោឃៈនេះត្រូវស្នើទៅចៅក្រមដោយទីប្រឹក្សារបស់ជនជាប់ចោទនៅមុនពេលកាត់ក្តី ។

៤-អ្នកការពារជនជាប់ចោទអាចយកសាក្សីខ្លួនមកបង្ហាញតុលាការ ហើយអាចជូនភស្តុតាងខ្លួនទៅតុលាការ ។

៥-សាក្សីទាំងអស់ ទាំងខាងដើមចោទ ទាំងខាងចុងចោទ អាចទទួលការបង្គាប់ឱ្យបង្ហាញខ្លួនចំពោះមុខតុលាការតាមរយៈដីកានាំខ្លួនរបស់តុលាការ ក្នុងករណីមិនព្រមប្រព្រឹត្តតាមការនាំខ្លួនរបស់តុលាការត្រូវពិន័យជាប្រាក់ពី ៥០.០០០ (ហាំម៉ឺន)រៀល ទៅ ៥០០.០០០ (ហាសិបម៉ឺន)រៀល ។

**មាត្រា ៣.- ឃាតកម្មគិតទុកជាមុន**

១-ជនណាដែលសម្លាប់ឬប៉ុនប៉ងសម្លាប់ជនណាម្នាក់ទៀត ក្រោយពីបានគិតទុកជាមុននូវបទឧក្រិដ្ឋរបស់ខ្លួនឬដោយបានរៀបចំការលួចស្ទាក់ ឬដែលបានសម្លាប់ ឬប៉ុនប៉ងសម្លាប់ជនណាម្នាក់ទៀតក្នុងពេលដែលខ្លួនប្រព្រឹត្តចោរកម្ម ឬរំលោភសេពសន្ថវៈ ត្រូវជាប់ទោសពីបទឧក្រិដ្ឋឃាតមនុស្សឃាតគិតទុកជាមុន ហើយត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារតម្រូវឱ្យធ្វើការពី ១៥ឆ្នាំ ទៅ ២០ឆ្នាំ ឬអស់មួយជីវិត ។

២-ការគិតទុកជាមុន គឺគម្រោងធ្វើឡើងមុនអំពើហឹង្សាទៅលើរូបបុគ្គលណាម្នាក់ ។

ការលួចស្ទាក់គឺការឃ្លាំចាំបុគ្គលណាម្នាក់ ក្នុងរយៈពេលណាមួយដើម្បីប្រព្រឹត្តអំពើហិង្សាទៅលើបុគ្គលនោះ ។

**មាត្រា ៤.- អំពើមនុស្សឃាតដោយចេតនា**

ជនណាដែលសម្លាប់មនុស្សដោយចេតនាឬប៉ុនប៉ងសម្លាប់ជនណាដោយចេតនាដោយគ្មានស្ថានទម្ងន់ណាដែលមានចែងក្នុងមាត្រា ៣ ដោយបានប្រើ ឬមិនបានប្រើអាវុធក្ដី ត្រូវជាប់ទោសពីបទឧក្រិដ្ឋឃាតមនុស្សឃាតដោយចេតនា ហើយត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារតម្រូវឱ្យធ្វើការពី ១០ ទៅ ១៥ឆ្នាំ ។

ជនណាដែលសម្លាប់មនុស្សដោយចេតនាដោយឃោរឃៅក្នុងកាលៈទេសៈនិងក្នុងទីកន្លែងតែមួយបណ្ដាលឱ្យជនណាម្នាក់ឬច្រើននាក់ស្លាប់ ត្រូវជាប់ទោសពីបទឧក្រិដ្ឋឃាតមនុស្សឃាតដោយចេតនា ហើយត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារតម្រូវឱ្យធ្វើការពី ១៥ឆ្នាំ ទៅ ២០ឆ្នាំ ឬអស់មួយជីវិត ។

មាត្រា ៥.- បទរំលោភសេពសន្ថវៈ

១-ជនណាក៏ដោយដែលរំលោភសេពសន្ថវៈ ឬប៉ុនប៉ងរំលោភសេពសន្ថវៈលើជនណាម្នាក់ទៀត ទោះបីភេទដូចគ្នាឬមិនដូចគ្នាក៏ដោយ ត្រូវមានទោសពីបទរំលោភសេពសន្ថវៈ ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ឆ្នាំ ទៅ ១៥ឆ្នាំ ។

២-បទរំលោភសេពសន្ថវៈគឺគ្រប់អំពើបញ្ចូលអង្គជាតិឬមធ្យោបាយផ្សេងទៀតដោយឃោរឃៅ ដោយបង្ខំ ឬដោយមិនដឹងខ្លួនជាមុន ។

ប្រសិនបើការរំលោភសេពសន្ថវៈបានប្រព្រឹត្តឡើងដោយការគំរាមកំហែងដោយអាវុធទៅលើស្ត្រីមានផ្ទៃពោះ លើជនមានជំងឺ ឬជនមានសតិវិបល្លាស ឬពិការរាងកាយ ឬលើអនីតិជន អាយុតិចជាង ១៥ឆ្នាំ ធ្វើឡើងដោយមានអ្នកប្រព្រឹត្តម្នាក់ ឬច្រើននាក់ ឬដោយអ្នកសមគំនិត ឬបើការសេពសន្ថវៈត្រូវប្រព្រឹត្តឡើងដោយជនដែលមានអំណាចលើអ្នករងគ្រោះ ទណ្ឌកម្មដែលត្រូវអនុវត្តគឺដាក់ពន្ធនាគារតម្រូវឱ្យធ្វើការពី ១៥ឆ្នាំ ទៅ ២០ឆ្នាំ ។

មាត្រា ៦.- អំពើប្លន់

អំពើប្លន់ ជាការបន្លំនិងជាការជំរិតយកទ្រព្យសម្បត្តិអ្នកដទៃ តាមគ្រប់រូបភាព ដោយផ្ទាល់ក្តី ដោយប្រយោលក្តី ក្នុងបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ។

ជនណាដែលបានលួច ឬប៉ុនប៉ងលួចជនណាម្នាក់ទៀតដោយមានស្ថានទម្ងន់ទោសណាមួយដូចខាងក្រោម :

-ការលួចធ្វើដោយអំពើហិង្សាមានអាវុធ ឬអត់អាវុធ បណ្តាលឬមិនបណ្តាលឱ្យមានរបួស

-ឬការលួចនោះបានធ្វើឡើងដោយមានគ្នាច្រើន ឬដោយការកាប់គាស់ទម្លុះ ទម្លាយ បំផ្លិចបំផ្លាញ ត្រូវផ្តន្ទាទោសពីបទឧក្រិដ្ឋប្លន់ ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ ។

-ការលួចធ្វើដោយអំពើហិង្សាមានអាវុធក្តី ឬអត់អាវុធក្តី បណ្តាលឱ្យស្លាប់ម្ចាស់ទ្រព្យ ក្រុមគ្រួសារ ឬអ្នកការពារ អ្នកថែរក្សា ត្រូវមានទោសពីបទឧក្រិដ្ឋឃាតកម្មគិតទុកជាមុន ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារតម្រូវឱ្យធ្វើការពី ១៥ឆ្នាំ ទៅ ២០ឆ្នាំ ឬអស់មួយជីវិត ។

**មាត្រា ៧.-** ការចាប់ជំរិតនិងការបង្ខាំងមនុស្សដោយខុសច្បាប់

១-ជនណាដែលគ្មានបញ្ជាពីអាជ្ញាធរតុលាការ បានចាប់ខ្លួន ឬឃុំខ្លួន ឬបង្ខាំងខ្លួន មនុស្សណាក៏ដោយត្រូវមានទោស :

-ដាក់ពន្ធនាគារពី ៣ឆ្នាំ ទៅ ៥ឆ្នាំ បើការបង្ខាំងខ្លួននោះមានរយៈពេលតិចជាង ១ខែ

-ដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ បើការបង្ខាំងខ្លួន ឬការឃុំខ្លួននោះមានរយៈពេលលើសពី ១ខែ ។

២-ជនណាដែលគំរាមតាមគ្រប់រូបភាព តាមមធ្យោបាយណាក៏ដោយ ដើម្បីកំណត់ឱ្យប្រគល់ជាប្រាក់ ឬជាទ្រព្យសម្បត្តិ ក្នុងបំណងដែលខ្លួនចង់បាននោះ ត្រូវមានទោសពីបទឧក្រិដ្ឋជំរិត ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ទៅ ១០ឆ្នាំ ។

៣-ជនណាដែលប្រព្រឹត្តដោយចេតនា ចាប់ខ្លួនជនណាម្នាក់ ឬច្រើននាក់ យកមកឃុំខ្លួន ឬបង្ខាំងខ្លួន ឬគំរាមធ្វើទារុណកម្មដោយគ្រប់រូបភាពបណ្តាលឱ្យជនណាម្នាក់ស្លាប់ក្តី ឬមិនស្លាប់ក្តី ហើយគំរាមឱ្យតតិយជន ឬជនរងគ្រោះប្រគល់ជាប្រាក់ ឬទ្រព្យសម្បត្តិ ឬអ្វីផ្សេងទៀត ដើម្បីជាថ្នូរទៅតាមបំណងរបស់ខ្លួនត្រូវមានទោសពីបទឧក្រិដ្ឋចាប់ជំរិតនិងបង្ខាំងមនុស្សខុសច្បាប់ ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារតម្រូវឱ្យធ្វើការពី ១៥ឆ្នាំ ទៅ ២០ឆ្នាំ ឬអស់មួយជីវិត ។

**មាត្រា ៨.-** ការលើកលែងទោស

ចំពោះបទឧក្រិដ្ឋនិងបទឧក្រិដ្ឋតម្រូវឱ្យធ្វើការ នៅក្រោមមិនត្រូវគិតពីស្ថានក្រាប្រណីទោស ឬបន្ធូរបន្ថយទោសក្រោមអប្បបរមា ឬលើកលែងទោសបានឡើយ ។ ចំពោះបទមជ្ឈិមដែលមិនប៉ះពាល់ដល់របៀបរៀបរយសាធារណៈធ្ងន់ធ្ងរទេ អាចត្រូវលើកលែងទោសទាំងមូល ឬមួយផ្នែកបាន ។ ក្នុងករណីនេះ ជនដែលបានប្រព្រឹត្តបទល្មើសមិនត្រូវទទួលរងទណ្ឌកម្មចប់ចុងចប់ដើមទេ ប្រសិនបើខ្លួនមិនបានប្រព្រឹត្តបទល្មើសមួយផ្សេងទៀតដែលមានចែងក្នុងបណ្តាមាត្រាមុនៗក្នុងរយៈពេល ៥ឆ្នាំ ក្រោយពីការកាត់ទោសរបស់ខ្លួន ។

**មាត្រា ៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ១០.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមករា ឆ្នាំ ២០០២

ក្នុងព្រះបរមនាម និងតាមព្រះរាជក្រាសំបង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

នស.០២.០១.០០៥

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ហត្ថលេខា

ស ខេង យូ ហុកគ្រី

លេខ : ០៧ ច.ល

ចំលងចែក

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមករា ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ីវិន-តាន

# សន្ធិសញ្ញា
# ស្តីពី បត្យាប័ន
# រវាង
# ព្រះរាជាណាចក្រកម្ពុជា
# និង
# សាធារណរដ្ឋប្រជាមានិតចិន

*****************

ព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋប្រជាមានិតចិន ដែលតទៅនេះកំណត់ហៅថា "ភាគីចុះកិច្ចព្រមព្រៀង"

ដោយមានបំណងពង្រឹងកិច្ចសហប្រតិបត្តិការដ៏មានប្រសិទ្ធិភាព រវាងប្រទេសទាំងពីរ ក្នុងការកំចាត់ឧក្រិដ្ឋកម្ម ឈរលើមូលដ្ឋានគោរពអធិបតេយ្យភាពគ្នាទៅវិញទៅមក សមភាព និង ផលប្រយោជន៍ទាំងសងខាង តាមការចុះសន្ធិសញ្ញាបត្យាប័ន

បានព្រមព្រៀងគ្នាដូចតទៅ :

## ប្រការទី ១
## កាតព្វកិច្ចត្រូវធ្វើបត្យាប័ន

ដោយអនុលោមតាមបទបញ្ញត្តិទាំងឡាយនៃសន្ធិសញ្ញានេះ ភាគីចុះកិច្ចព្រមព្រៀងមានភារកិច្ចធ្វើបត្យាប័នទៅភាគីម្ខាងទៀតនូវជនទាំងឡាយណា ដែលត្រូវបានឃើញនៅលើដែនដីនៃភាគីចុះកិច្ចព្រមព្រៀងណាមួយ ហើយជនទាំងនោះកំពុងត្រូវគេតាមចាប់ខ្លួន ដើម្បីធ្វើការចោទប្រកាន់ ដើម្បីធ្វើការជំនុំជំរះក្តី ឬ ដើម្បីអោយទទួលទោស ឬ អនុវត្តទណ្ឌកម្ម តាមទោសកំណត់នៅលើទឹកដីរបស់ភាគីម្ខាងទៀត ចំពោះបទល្មើសដែលអាចធ្វើបត្យាប័នបានណាមួយ ។

## ប្រការទី ២
## បទល្មើសដែលអាចធ្វើបត្យាប័នបាន

១.ក្នុងស្មារតីនៃសន្ធិសញ្ញានេះ បទល្មើសដែលអាចធ្វើបត្យាប័នបាន គឺជាបទល្មើសដែលអាចផ្តន្ទាទោសតាមធរមាននៃច្បាប់របស់ភាគីចុះកិច្ចព្រមព្រៀងទាំងពីរ ដោយការដាក់ពន្ធនាគារ ឬ ដោយរូបភាពផ្សេងទៀតនៃការឃុំឃាំង សំរាប់រយៈពេលលើសពីមួយឆ្នាំឡើងទៅ ឬ ការផ្តន្ទាទោសណាមួយដែលធ្ងន់ជាងនេះ ។

២.កាលណាមានសំណើបត្យាប័នពាក់ព័ន្ធដល់បុគ្គលណាម្នាក់ ដែលត្រូវបានកាត់ទោសជាប់ពន្ធនាគារ ឬ ការឃុំឃាំងតាមរូបភាពណាមួយផ្សេងទៀត ធ្វើឡើងដោយតុលាការរបស់ភាគីដាក់សំណើចំពោះបទល្មើសដែលអាចធ្វើបត្យាប័នណាមួយ បត្យាប័នអាចនឹងផ្តល់បាន លុះត្រាតែទោសកំណត់ដែលត្រូវទទួលរួចមាននៅក្នុងសាលក្រម នៅសល់យ៉ាងតិចបំផុត ៦ ខែទៀត ។

៣.ក្នុងស្មារតីប្រការនេះ ការកំណត់ថាបទល្មើសណាមួយ ជាបទល្មើសប្រឆាំងនឹងអង្គច្បាប់នៃភាគីទាំងពីរ គឺមិនសំខាន់ត្រង់ថាអង្គច្បាប់នៃភាគីចុះកិច្ចព្រមព្រៀង ចាត់ទុកអំពើដែលបង្កនូវបទល្មើសនោះ ក្នុងប្រភេទនៃបទល្មើសដូចគ្នា ឬ កំណត់បទល្មើសដោយពាក្យពេចន៍ដូចគ្នានោះទេ ។

៤.កាលណាការបត្យាប័នត្រូវបានផ្តល់អោយ ក្នុងស្មារតីនៃបទល្មើសដែលអាចធ្វើបត្យាប័នណាមួយ បត្យាប័ននេះក៏អាចផ្តល់អោយចំពោះបទល្មើសផ្សេងទៀត ដែលចែងក្នុងសំណើបត្យាប័ននេះ ហើយដែលមានលក្ខណៈគ្រប់គ្រាន់សំរាប់ធ្វើបត្យាប័ន លើកលែងតែរយៈពេលផ្តន្ទាទោស ឬ ឃុំឃាំង ដែលមានចែងក្នុងកថាខណ្ឌទី ១ និង ២ របស់ប្រការនេះ ។

## ប្រការទី ៣
## មូលដ្ឋាននៃការបដិសេធដាច់ខាត

ក្នុងក្របខណ្ឌនៃសន្ធិសញ្ញានេះ បត្យាប័ននឹងមិនអនុញ្ញាតិអោយធ្វើបានឡើយ ក្នុងករណីណាមួយដូចខាងក្រោមនេះ ៖

១.ភាគីទទួលសំណើយល់ឃើញថា បទល្មើសជាកម្មវត្ថុនៃបត្យាប័ន ដែលធ្វើឡើងដោយភាគីដាក់សំណើ ជាបទល្មើសនយោបាយ ។ ការយោងទៅលើបទល្មើសនយោបាយ ពុំត្រូវរាប់បញ្ចូលនូវការធ្វើឃាត ឬ ប៉ុនប៉ងធ្វើឃាត ឬ ការបំពារបំពានលើរូបកាយរបស់ប្រមុខរដ្ឋ ឬ ប្រមុខរដ្ឋាភិបាល ឬ សមាជិកគ្រួសារនៃរជនទាំងនោះ ។

២.ភាគីទទួលសំណើមានមូលដ្ឋានច្បាស់លាស់ ដើម្បីសន្និដ្ឋានថាសំណើបត្យាប័នធ្វើឡើងដោយភាគីដាក់សំណើ មានគោលបំណងប្រើនីតិវិធីព្រហ្មទណ្ឌប្រឆាំង ឬ អនុវត្តទណ្ឌកម្មទៅលើបុគ្គល ដែលត្រូវចោទប្តឹងដោយមូលហេតុពូជសាសន៍ សាសនា សញ្ជាតិ ឬ ទស្សនៈនយោបាយរបស់បុគ្គលនោះ ឬ ឋានៈរបស់ជនដែលត្រូវចោទប្តឹងក្នុងរឿងក្តីនោះ ត្រូវបានគេចាត់ទុកថាបានធ្វើអោយប៉ះពាល់ការសំអាងដែលពោលខាងលើ ។

៣.បទល្មើសដែលជាកម្មវត្ថុនៃសំណើបត្យាប័ន តាមច្បាប់របស់ភាគីដាក់សំណើ គឺជាបទល្មើសយោធាសុទ្ធសាធ ។

៤.ការចោទប្រកាន់ ឬ ការអនុវត្តការដាក់ទណ្ឌកម្មចំពោះបទល្មើសណាមួយ ដែលកម្មវត្ថុរបស់បត្យាប័នត្រូវបានរលត់ដោយមូលហេតុមានចែងក្នុងច្បាប់នៃភាគីចុះកិច្ចព្រមព្រៀងណាមួយដោយរាប់បញ្ចូលទាំងច្បាប់ស្តីពីអាជ្ញាយុកាល ។

៥.ភាគីទទួលសំណើ បានចេញសាលក្រមកាត់ទោសជនដែលត្រូវស្នើសុំ ចំពោះបទល្មើសដែលនេះរួចហើយ មុនពេលដាក់សំណើសុំធ្វើបត្យាប័ន ។

៦.ប្រសិនបើសាលក្រមរបស់ភាគីដាក់សំណើបានត្រូវធ្វើឡើងដោយកំបាំងមុខដោយជនជាប់ចោទពុំបានទទួលពត៌មានគ្រប់គ្រាន់ អំពីសវនាការកាត់ក្តីនេះ ឬ គ្មានឱកាសចាត់ចែង ការការពារក្តីរបស់ខ្លួន ឬ គ្មានឱកាសដើម្បីអោយសំណុំរឿងក្តីរបស់ខ្លួនបានត្រូវជំនុំជំរះឡើងវិញដោយមានវត្តមានរបស់ខ្លួន ។

## ប្រការទី ៤
## មូលដ្ឋាននៃការបដិសេធដោយឆន្ទានុសិទ្ធិ

ក្នុងក្របខ័ណ្ឌនៃសន្ធិសញ្ញានេះ បត្យាប័នអាចបដិសេធបានក្នុងករណីណាមួយ ដូចខាងក្រោមនេះ :

១.យោងទៅតាមច្បាប់របស់ខ្លួន ភាគីទទួលសំណើមានយុត្តាធិការលើបទល្មើស ដែលជាកម្មវត្ថុរបស់សំណើបត្យាប័ន ហើយនឹងត្រូវរៀបចំនីតិវិធីជំនុំជំរះជនដែលត្រូវស្នើសុំដោយខ្លួនឯង ។

២.ភាគីទទួលសំណើ កំពុងតែធ្វើនីតិវិធីជំនុំជំរះក្តី លើជនដែលត្រូវស្នើសុំចំពោះបទល្មើសដដែលនេះ ។

៣.ក្នុងករណីពិសេសទាំងឡាយ ដោយគិតពីភាពធ្ងន់ធ្ងរនៃបទល្មើស និង ផលប្រយោជន៍ស្របច្បាប់របស់ភាគីដាក់សំណើ ភាគីទទួលសំណើអាចពិនិត្យឃើញថា បត្យាប័ននេះមានវិសមិតភាព នឹងទស្សនៈវិស័យផ្នែកមនុស្សធម៌ ដោយសារស្ថានភាពផ្ទាល់របស់ជនដែលត្រូវស្នើសុំ ។

៤.ប្រសិនបើបុគ្គលដែលត្រូវស្នើអោយធ្វើបត្យាប័ន ត្រូវបានគេកាត់ទោស ឬក៏ នឹងត្រូវចូលសវនាការ ឬ កាត់ទោសនៅក្នុងទឹកដីនៃភាគីដាក់សំណើ ដោយតុលាការ ឬ សាលាជំរះក្តីពិសេស ឬ បណ្តោះអាសន្នណាមួយ ។

## ប្រការទី ៥
## បត្យាប័នចំពោះពលរដ្ឋសាមី

១.ភាគីចុះកិច្ចព្រមព្រៀងម្ខាងៗ មានសិទ្ធិបដិសេធការធ្វើបត្យាប័នពលរដ្ឋផ្ទាល់របស់ខ្លួន ។

២.ប្រសិនបើបត្យាប័នមិនត្រូវបានផ្តល់អោយ ដោយយោងទៅលើកថាខ័ណ្ឌទី១នៃមាត្រានេះ ភាគីទទួលសំណើត្រូវបញ្ជូនបណ្តឹងក្តីនេះទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួន ដើម្បីធ្វើការចោទប្រកាន់ទៅតាមសំណូមពររបស់ភាគីដាក់សំណើ ។ ក្នុងករណីនេះ ភាគីដាក់សំណើត្រូវបញ្ជូនឯកសារ និង ភស្តុតាងដែលទាក់ទងនឹងបណ្តឹងក្តីនេះទៅភាគីទទួលសំណើ ។

៣. ទោះបីកថាខ័ណ្ឌទី២នៃមាត្រានេះ បានចែងដូច្នេះក៏ដោយ ភាគីទទួលសំណើពុំចាំបាច់ត្រូវបញ្ជូនបណ្តឹងក្តីនេះទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនដើម្បីចោទប្រកាន់ទេ ប្រសិនបើភាគីទទួលសំណើគ្មានយុត្តាធិការលើបទល្មើសនេះ ។

## ប្រការទី ៦
## វិធីផ្តល់ព័ត៌មាន

ក្នុងស្មារតីនៃសន្ធិសញ្ញានេះ ភាគីចុះកិច្ចព្រមព្រៀងត្រូវប្រាស្រ័យទាក់ទងគ្នាតាមរយៈផ្លូវទូត វៀរលែងតែមានបទបញ្ញត្តិផ្សេងចែងក្នុងសន្ធិសញ្ញានេះ ។

## ប្រការទី ៧
## សំណើបត្យាប័ន និង ឯកសារចាំបាច់ ដែលត្រូវភ្ជាប់ជាមួយ

១. សំណើបត្យាប័នត្រូវធ្វើជាលាយលក្ខអក្សរ ហើយត្រូវភ្ជាប់ជាមួយនូវ :

ក. ឯកសារ, សេចក្តីបញ្ជាក់ ឬ ភស្តុតាងដទៃទៀត មានលក្ខណៈគ្រប់គ្រាន់សំរាប់ពិពណ៌នាអំពីអត្តសញ្ញាណ និង ទីកន្លែងប្រហាក់ប្រហែលដែលជនត្រូវស្នើសុំកំពុងស្នាក់នៅ,

ខ. សេចក្តីបញ្ជាក់ លើកអង្គហេតុនៃបណ្តឹងក្តី,

គ. រាល់បទបញ្ញត្តិនៃច្បាប់ ដែលពិពណ៌នាអំពីធាតុសំខាន់ៗ និងការកំណត់នៃបទល្មើសដែលជាកម្មវត្ថុនៃបត្យាប័ន,

ឃ. រាល់បទបញ្ញត្តិនៃច្បាប់ ដែលចែងពីការផ្តន្ទាទោសទៅលើបទល្មើស និង

ង. រាល់បទបញ្ញត្តិនៃច្បាប់ ដែលចែងពីការកំណត់ពេលនៃការចោទប្រកាន់ ឬ ការអនុវត្តទណ្ឌកម្ម ចំពោះបទល្មើសប្រសិនបើមាន ។

២. សំណើបត្យាប័ន ដែលទាក់ទងនឹងជនដែលត្រូវស្នើសុំដើម្បីចោទប្រកាន់ ត្រូវភ្ជាប់ជាមួយផងដែរនូវ :

ក. សេចក្តីចំលងនៃដីកាចាប់ខ្លួន ដែលចេញដោយចៅក្រម ឬ អាជ្ញាធរមានសមត្ថកិច្ចដទៃទៀតរបស់ភាគីដាក់សំណើ ។

ខ. ភស្តុតាងដែលអាចសំអាងបានសំរាប់ការចាប់ខ្លួន និង ការឃុំខ្លួនដើម្បីរង់ចាំការជំនុំជំរះក្តីរបស់ជននោះ ដោយរាប់បញ្ចូលទាំងភស្តុតាងដែលបញ្ជាក់ថា ជនដែលត្រូវស្នើសុំពិតជាជនដែលកំណត់ក្នុងដីកាចាប់ខ្លួនមែន ។

៣. ជាបន្ថែមទៅលើចំណុចទាំងឡាយ ដែលចែងក្នុងកថាខ័ណ្ឌ២នៃប្រការនេះ កាលណាសំណើបញ្ជូនទាក់ទងទៅនឹងជនដែលបានត្រូវកំណត់ទោសរួចហើយ សំណើនេះត្រូវភ្ជាប់មកជាមួយនូវ :

ក. សេចក្តីចំលងនៃសាលក្រមរបស់តុលាការនៃភាគីដាក់សំណើ,

ខ. ភស្តុតាងបញ្ជាក់ថា ជនដែលត្រូវស្នើសុំ ពិតជាជនដែលកំណត់ក្នុងសាលក្រម,

គ. សេចក្តីបញ្ជាក់បង្ហាញអំពីកំរិតដែលសាលក្រមនោះបានត្រូវអនុវត្តហើយ និង

ឃ. សេចក្តីបញ្ជាក់ទាក់ទងនឹងមធ្យោបាយតាមផ្លូវច្បាប់ ដែលមានសំរាប់បុគ្គលដើម្បីរៀបចំការការពារខ្លួនរបស់គេ ឬ ក៏ធានាអោយមានការកាត់ក្តីសារឡើងវិញ ដោយមានវត្តមានបុគ្គលនោះ ចំពោះករណីដែលជននោះត្រូវបានសំរេចកំបាំងមុខ អោយជាប់ទោស ចំពោះបទល្មើសរបស់គាត់ ។

៤. រាល់ឯកសារទាំងអស់ដែលភាគីដាក់សំណើ ត្រូវបញ្ជូនអោយក្នុងក្របខ័ណ្ឌនៃបទបញ្ញត្តិនៃសន្ធិសញ្ញានេះ ត្រូវចុះហត្ថលេខា ឬ បោះត្រាផ្លូវការ និង ភ្ជាប់មកជាមួយនូវអត្ថបទបកប្រែជាភាសានៃភាគីទទួលសំណើ ឬ ជាភាសាអង់គ្លេស ។

## ប្រការទី ៨
## ពត៌មានបន្ថែម

ប្រសិនបើភាគីទទួលសំណើយល់ឃើញថា ពត៌មានដែលផ្តល់សំរាប់គាំទ្រសំណើបញ្ជូនពុំមានលក្ខណៈគ្រប់គ្រាន់ ស្របតាមសន្ធិសញ្ញាដែលអនុញ្ញាតអោយធ្វើបញ្ជូនបាន ភាគីនោះអាចស្នើសុំផ្តល់ពត៌មានបន្ថែមពីភាគីដាក់សំណើ ក្នុងរយៈពេលកំណត់ណាមួយសមស្រប ។ ប្រសិនបើភាគីដាក់សំណើនកខានពុំបានបញ្ជូនពត៌មានបន្ថែម តាមរយៈពេលកំណត់នោះ នឹងត្រូវចាត់ទុកថាបានលះបង់នូវសំណើរបស់ខ្លួន ។ ប៉ុន្តែភាគីដាក់សំណើ មិនត្រូវបានហាមឃាត់មិនអោយធ្វើសំណើនេះជាថ្មីទៀតនោះទេ ។

## ប្រការទី ៩

## ការចាប់ខ្លួនបណ្ដោះអាសន្ន

១. ក្នុងករណីបន្ទាន់ ភាគីចុះកិច្ចព្រមព្រៀងម្ខាង អាចស្នើទៅភាគីចុះកិច្ចព្រមព្រៀងម្ខាងទៀតអោយធ្វើការចាប់ខ្លួនបណ្ដោះអាសន្ននូវជនដែលត្រូវស្នើសុំ ។ សំណើនេះអាចដាក់ជូនជាលាយលក្ខណ៍អក្សរតាមផ្លូវទូត ឬ តាមរយៈអង្គការនគរបាលព្រហ្មទណ្ឌអន្តរជាតិ ( អាំងទែរប៉ូល )។

២. សំណើសុំខាងលើត្រូវមាន :

- ការពិពណ៌នាអំពីជនដែលត្រូវស្នើសុំ
- ទីកន្លែងដែលជននោះស្ថិតនៅ ប្រសិនបើដឹង
- សេចក្ដីបញ្ជាក់សង្ខេប អំពីដំណើរហេតុនៃបណ្ដឹងក្ដី
- សេចក្ដីបញ្ជាក់ថា មានដីកាចាប់ខ្លួន ឬ សាលក្រមលើជននោះ ដូចមានចែងក្នុងប្រការទី៧ និង
- សេចក្ដីបញ្ជាក់ថា សំណើបញ្ជូនលើជនដែលត្រូវស្នើសុំនឹងត្រូវបញ្ជូនមក តាមក្រោយ ។

៣. ភាគីដាក់សំណើនឹងត្រូវបានទទួលដំណឹងពីលទ្ធផលនៃសំណើរបស់ខ្លួន ដោយគ្មានបង្អែបង្អង់ ។

៤. ការចាប់ខ្លួនបណ្ដោះអាសន្ននឹងត្រូវបញ្ចប់ ប្រសិនបើអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីទទួលសំណើ ពុំបានទទួលសំណើបញ្ជូនជាផ្លូវការ និង រាល់ឯកសារសំអាងទាំងឡាយដូចដែលកំណត់ក្នុងប្រការទី៧ ក្នុងរយៈពេល ៦០ថ្ងៃ បន្ទាប់ពីការចាប់ខ្លួនជនដែលត្រូវសុំ ។ កថាខណ្ឌនេះ មិនត្រូវបានរារាំងដល់លទ្ធភាពក្នុងការដោះលែងដោយមានលក្ខខ័ណ្ឌជនដែលត្រូវស្នើសុំមុនផុតរយៈពេល ៦០ថ្ងៃនេះទេ ក្នុងករណីដែលភាគីទទួលសំណើមានមូលដ្ឋានបដិសេធដាច់ខាត ឬ គឺមូលដ្ឋានបដិសេធដោយឆន្ទានុសិទ្ធិ ឬក៏ ក្នុងករណីដែលភាគីដាក់សំណើលុបចោលនូវសំណើបញ្ជូនរបស់ខ្លួន។

៥. ការបញ្ចប់នូវការចាប់ខ្លួនបណ្ដោះអាសន្នយោងតាមកថាខ័ណ្ឌ៤នៃប្រការនេះ មិនត្រូវមានផលប៉ះពាល់ដល់ការធ្វើបញ្ជូននូវជនដែលត្រូវស្នើសុំនោះទេប្រសិនបើសំណើបញ្ជូន

និង រាល់ឯកសារគាំទ្របត្យាប័នដូចមានចែងក្នុងប្រការទី៧ ត្រូវបានផ្តល់អោយក្នុងកាលបរិច្ឆេទក្រោយទៀត ។

## ប្រការទី ១០
## ការសំរេចចិត្តទៅលើការស្នើ

១. ភាគីទទួលសំណើត្រូវអនុវត្តពិនិត្យលើសំណើសុំបត្យាប័ន ស្របតាមនីតិវិធីចែងដោយច្បាប់របស់ខ្លួន និងត្រូវជូនពត៌មានយ៉ាងឆាប់រហ័សតាមរយៈផ្លូវទូត ទៅភាគីដាក់សំណើអំពីសេចក្តីសំរេចចិត្តរបស់ខ្លួន ។

២. ការបញ្ជាក់ពីមូលហេតុនៃការបដិសេធទាំងស្រុង ឬ ដោយផ្នែកណាមួយលើសំណើសុំបត្យាប័ននោះត្រូវតែផ្តល់ជូន ។

## ប្រការទី ១១
## ការប្រគល់ខ្លួនជនដែលត្រូវស្នើសុំ

១. ប្រសិនបើបត្យាប័នត្រូវបានផ្តល់ឱ្យ ភាគីទទួលសំណើ និង ភាគីដាក់សំណើត្រូវសំរេច អំពីការអនុវត្តន៍បត្យាប័នតាមរយៈការពិគ្រោះយោបល់គ្នា ។ ដើម្បីបំណងនេះ ភាគីទទួលសំណើ នឹងជូនពត៌មានដល់ភាគីដាក់សំណើពីរយៈពេលដែលជនដែលត្រូវស្នើសុំនោះត្រូវបានចាប់ឃុំឃាំងមុនពេលប្រគល់ខ្លួន ។

២. លើកណាកថាខណ្ឌ ៣ នៃប្រការនេះ មិនមានចែងអ្វីមួយផ្ទុយពីនេះ ភាគីដាក់សំណើត្រូវ បានចាត់ទុកថាបានបោះបង់សំណើបត្យាប័ន ប្រសិនបើភាគីនេះពុំទទួលយកជនដែលត្រូវបានស្នើសុំ ក្នុងរយៈពេល១៥ថ្ងៃក្រោយពីកាលបរិច្ឆេទសំរាប់ការអនុវត្តធ្វើបត្យាប័ន ដូចដែលបានព្រមព្រៀងគ្នារួចហើយ ។ ភាគីទទួលសំណើត្រូវដោះលែងជននោះអោយមានសេរីភាពជាបន្ទាន់ហើយអាចបដិសេធការធ្វើបត្យាប័នចំពោះបទល្មើសដដែលនេះ ។

៣. ប្រសិនបើភាគីចុះកិច្ចព្រមព្រៀងណាមួយឥតខានពុំបានប្រគល់ ឬ ទទួលជនដែលត្រូវស្នើសុំ ក្នុងពេលវេលាដែលបានព្រមព្រៀងគ្នា ដោយករណីប្រធានសក្តិភាគីម្ខាងទៀត

ត្រូវតែបានផ្ដល់ព័ត៌មានពីបញ្ហានេះ ។ ភាគីចុះកិច្ចព្រមព្រៀងត្រូវសំរេចជាថ្មីម្ដងទៀត តាមការពិគ្រោះគ្នាអំពីការអនុវត្តន៍បត្យាប័នម្ដងទៀត ហើយបទបញ្ញត្តិនៃកថាខណ្ឌទី ២ នៃប្រការនេះនឹងត្រូវអនុវត្ត ។

## ប្រការទី ១២
## ការពន្យារពេលនៃការប្រគល់ខ្លួន និង ការប្រគល់ខ្លួនជាបណ្ដោះអាសន្ន

១. នៅពេលណាដែលជនត្រូវស្នើសុំ កំពុងត្រូវស្ថិតក្នុងនីតិវិធីជំនុំជំរះក្ដី ឬ កំពុងទទួលទោសក្នុងប្រទេសនៃភាគីទទួលសំណើ អំពីបទល្មើសណាមួយផ្សេងពីបទល្មើសជាកម្មវត្ថុរបស់បត្យាប័ន ភាគីទទួលសំណើអាចប្រគល់ ឬ ពន្យារការប្រគល់ជននោះរហូតដល់ការបញ្ចប់នីតិវិធីជំនុំជំរះក្ដី ឬ ការទទួលទោសទាំងស្រុង ឬ មួយផ្នែកណានៃទោសដែលកំណត់ក្នុងសាលក្រម ។ ភាគីទទួលសំណើត្រូវផ្ដល់ដំណឹងជូនភាគីដាក់សំណើអំពីការពន្យារពេលនេះ ។

២. យោលទៅតាមធរមាននៃច្បាប់របស់ប្រទេសខ្លួន ក្នុងករណីដែលគេយល់ថា ជនម្នាក់អាចត្រូវធ្វើបត្យាប័នបាន ភាគីទទួលសំណើអាចប្រគល់ជនដែលត្រូវស្នើសុំជាបណ្ដោះអាសន្នទៅភាគីដាក់សំណើ ដើម្បីធ្វើការចោទប្រកាន់ស្របទៅតាមលក្ខខណ្ឌ ដែលបានកំណត់រវាងភាគីទាំងពីរ ។ ជនណាម្នាក់ដែលត្រូវបានប្រគល់ទៅភាគីដាក់សំណើបន្ទាប់ពី ការប្រគល់ខ្លួនបណ្ដោះអាសន្ន អាចត្រូវប្រគល់ជាស្ថាពរទៅភាគីដាក់សំណើ ដើម្បីទទួលទោសតាមសាលក្រមកំណត់ស្របតាមបទបញ្ញត្តិ នៃសន្ធិសញ្ញានេះ ។

## ប្រការទី ១៣
## សំណើបត្យាប័នធ្វើឡើងដោយរដ្ឋជាច្រើន

ប្រសិនបើសំណើបត្យាប័នចំពោះតែជនម្នាក់ត្រូវបានធ្វើឡើងដោយភាគីចុះកិច្ចព្រមព្រៀងណាមួយ និងពីរដ្ឋដទៃផ្សេងមួយឬច្រើនទៀតផងនោះ ភាគីទទួលសំណើអាចកំណត់ពីអាទិភាពចំពោះសំណើណាមួយក្នុងចំណោមសំណើបត្យាប័នទាំងនោះ ។

## ប្រការទី ១៤
## វិធានពិសេស

១. ជនដែលត្រូវធ្វើបត្យាប័ន អនុលោមតាមសន្ធិសញ្ញានេះ មិនត្រូវទទួលការឃុំឃាំង ទទួលការកាត់ក្តី ឬ ការដាក់ទណ្ឌកម្ម នៅក្នុងដែនដីភាគីដាក់សំណើសំរាប់បទល្មើសផ្សេង ក្រៅពីបទល្មើសដែលបត្យាប័នបានត្រូវប្រគល់ជូនព្រមទាំងមិនត្រូវធ្វើបត្យាប័នបញ្ជូនទៅរដ្ឋផ្សេងទៀតដោយភាគីនេះ លើកលែងតែក្នុងករណី :

ក. ជននោះបានចាកចេញពីដែនដីនៃភាគីដាក់សំណើ បន្ទាប់ពីការធ្វើបត្យាប័ន ហើយបានត្រឡប់មកដែនដីនេះវិញដោយស្ម័គ្រចិត្ត

ខ. ជននោះមិនបានចាកចេញពីដែនដីភាគីដាក់សំណើ ក្នុងរយៈពេល ៣០ថ្ងៃ ដែលគេទុកឱ្យជននោះមានសិទ្ធិចាកចេញ ឬ

គ. ភាគីទទួលសំណើបានយល់ព្រមឱ្យមានការឃុំឃាំង ការកាត់ក្តី ឬ ការដាក់ទណ្ឌកម្មចំពោះជននោះពីបទល្មើសផ្សេងក្រៅពីបទល្មើសដែលបានស្នើសុំឱ្យមានបត្យាប័ន ឬ យល់ព្រមឱ្យមានការធ្វើបត្យាប័នទៅរដ្ឋដទៃផ្សេងទៀត ។ ក្នុងស្ថានភាពនេះ ភាគីទទួលសំណើអាចទាមទារឱ្យផ្តល់នូវឯកសារ ឬ សេចក្តីបញ្ជាក់ណាមួយ ដូចមានចែងក្នុងប្រការទី៧ រួមទាំងសេចក្តីបញ្ជាក់ដែលធ្វើឡើងដោយជនដែលត្រូវធ្វើបត្យាប័ន ចំពោះបទល្មើសដែលត្រូវពាក់ព័ន្ធ ។

២. បទបញ្ញត្តិទាំងនេះមិនត្រូវអនុវត្តចំពោះបទល្មើសទាំងឡាយណា ដែលបានប្រព្រឹត្ត ក្រោយការធ្វើបត្យាប័នឡើយ ។

## ប្រការទី ១៥
## ការប្រគល់ទ្រព្យសម្បត្តិ

១. ក្នុងក្របខណ្ឌនៃច្បាប់របស់ប្រទេសខ្លួន និង យោងតាមសំណើនៃភាគីដាក់សំណើ ភាគីទទួលសំណើត្រូវរឹបអូសទ្រព្យសម្បត្តិ និង ក្រោយពីបានផ្តល់បត្យាប័ន ត្រូវប្រគល់ទ្រព្យសម្បត្តិ៖

ក. ដែលអាចតម្រូវឱ្យធ្វើជាភស្តុតាង ឬ

ខ. ដែលត្រូវបានទទួលស្គាល់ថាជាទ្រព្យសម្បត្តិចេញពីលទ្ធផលនៃបទល្មើស ។

២.ទ្រព្យសម្បត្តិដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការនេះត្រូវរឹបអូស ឬ ប្រគល់ជូនស្របតាមកថាខណ្ឌខាងលើទោះបីជាបត្យាប័នដែលត្រូវបានផ្តល់ឱ្យ មិនអាចអនុវត្តបានដោយមូលហេតុមកពីមរណៈភាព ការបាត់ខ្លួន ឬ ការគេចខ្លួននៃជនដែលត្រូវជាប់ចោទ ។

៣. កាលណាទ្រព្យសម្បត្តិដូចមានចែងខាងលើនេះ ជាកម្មសិទ្ធិនៃការដកហូត ឬ រឹបអូសនៅលើដែនដីនៃភាគីទទួលសំណើ ភាគីនេះអាចរក្សាទុកជាបណ្ដោះអាសន្នទ្រព្យសម្បត្តិទាំងនេះ ឬ បញ្ជូនវាត្រឡប់ទៅវិញ ក្នុងលក្ខខណ្ឌដែលទ្រព្យសម្បត្តិទាំងនេះស្ថិតក្នុងការរង់ចាំនីតិវិធីព្រហ្មទណ្ឌ ។

៤.រាល់សិទ្ធិទាំងឡាយណា ដែលភាគីទទួលសំណើ ឬ រដ្ឋណាមួយ ឬ បុគ្គលណាមួយមានលើទ្រព្យសម្បត្តិដូចពោលខាងលើត្រូវបានរក្សាទុក ។ ក្រោយពីមានការជំនុំជំរះរួចទោះជាសិទ្ធិលើទ្រព្យសម្បត្តិទាំងនេះនៅទីណាក៏ដោយ ទ្រព្យសម្បត្តិទាំងនេះត្រូវបញ្ជូនទៅភាគីទទួលសំណើតាមសំណូមពរនៃភាគីនេះភ្លាមដោយគ្មានបន្ទុកពន្ធអាករ បន្ទាប់ពីការជំនុំជំរះក្តី ។

## ប្រការទី ១៦
## ដំណើរឆ្លងកាត់

១. នៅពេលដែលជនម្នាក់ត្រូវបានធ្វើបត្យាប័នបញ្ជូនពីរដ្ឋទីបីមកភាគីចុះកិច្ចព្រមព្រៀងណាមួយ ដោយឆ្លងកាត់ទឹកដីនៃភាគីចុះកិច្ចព្រមព្រៀងម្ខាងទៀត ភាគីដំបូងត្រូវស្នើសុំការ

អនុញ្ញាតិឆ្លងកាត់ពីភាគីម្ខាងទៀត ។ ការអនុញ្ញាតិបែបនេះ មិនត្រូវទាមទារទេ ក្នុងករណីដែលមានការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនតាមផ្លូវអាកាស ហើយគ្មានការសុំសំចតលើទឹកដីនៃភាគីចុះកិច្ចព្រមព្រៀងម្ខាងទៀត ។

២. ភាគីទទួលសំណើ ត្រូវផ្តល់ជូនតាមសំណើនៃការសុំឆ្លងកាត់ដែលត្រូវបានស្នើដោយភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត ល្គឹកណាការឆ្លងកាត់នេះមិនផ្ទុយពីច្បាប់ក្នុងប្រទេសខ្លួន ។

## ប្រការទី ១៧
## ការផ្តល់ពត៌មានអំពីលទ្ធផល

ភាគីដាក់សំណើត្រូវបញ្ជូនដំណឹងទៅភាគីទទួលសំណើ ឱ្យបានទាន់ពេលវេលា នូវដំណឹងដែលពាក់ពន្ធ័ដល់ការចោទប្រកាន់ ការជំនុំជំរះ និង ការអនុវត្តន៏នូវការដាក់ទណ្ឌកម្ម ចំពោះជនដែលស្នើសុំ ឬ ពាក់ពន្ធ័ដល់ការធ្វើបត្យាបន៍បន្ត ចំពោះជនរូបនោះ ទៅរដ្ឋផ្សេងទៀត ។

## ប្រការទី ១៨
## ការឧបត្ថម្ភ និង ការចំណាយ

១. ភាគីទទួលសំណើត្រូវចេញមុខ ក្នុងនាមជាភាគីដាក់សំណើដោយចាត់ចែង និង អនុវត្តរាល់នីតិវិធីដែលចេញពីសំណើបត្យាបន៍ ។

២.ចំណាយសំរាប់បត្យាបន៍ ជាបន្ទុករបស់ភាគីដែលចំណាយនេះកើតឡើង ។ ចំណាយសំរាប់ការដឹកនាំតាមផ្លូវអាកាស និងការឆ្លងកាត់ដែលទាក់ទងនឹងការធ្វើបត្យាបន៍ជននោះ គឺជាបន្ទុករបស់ភាគីដាក់សំណើ ។

## ប្រការទី ១៩
## ទំនាក់ទំនងជាមួយនឹងអនុសញ្ញាពហុភាគី

សន្ធិសញ្ញានេះគ្មានប៉ះពាល់ដល់សិទ្ធិ និង កាតព្វកិច្ចទាំងឡាយដែលភាគីចុះកិច្ចព្រមព្រៀងបានទទួល និង គោរពក្នុងក្របខណ្ឌនៃអនុសញ្ញាពហុភាគីណាមួយឡើយ ។

## ប្រការទី ២០
## ដំណោះស្រាយនៃបញ្ហាវិវាទ

រាល់វិវាទដែលកើតចេញពីការអនុវត្តន៍ ឬ ការបកស្រាយនៃសន្ធិសញ្ញានេះ ត្រូវដោះស្រាយតាមការពិគ្រោះយោបល់ ឬ ការចរចា ។

## ប្រការទី ២១
## ការធ្វើវិសោធនកម្ម

សន្ធិសញ្ញានេះអាចធ្វើវិសោធនកម្មបាន តាមការស្នើសុំពីភាគីចុះកិច្ចព្រមព្រៀងណាមួយ ។ រាល់វិសោធនកម្មដែលបានយល់ព្រមដោយភាគីចុះកិច្ចព្រមព្រៀងតាមរយៈការពិគ្រោះផ្លូវទូត ត្រូវចូលជាធរមានចាប់ពីថ្ងៃដែលបានព្រមព្រៀងគ្នាទៅវិញទៅមក និងត្រូវបង្កើតជាផ្នែកមួយ រួមជាមួយនឹងកិច្ចព្រមព្រៀងនេះ ។

## ប្រការទី ២២
## ការផ្តល់សច្ចាប័ន ការចូលជាធរមាន និង សុពលភាពនៃសន្ធិសញ្ញា

១. សន្ធិសញ្ញានេះត្រូវស្ថិតនៅជាកម្មវត្ថុនៃការសុំសច្ចាប័ន ។ លិខិតូបករណ៍នៃការធ្វើសច្ចាប័នត្រូវប្តូរគ្នានៅភ្នំពេញ ។ សន្ធិសញ្ញានេះត្រូវចូលជាធរមានក្នុងរយៈពេល ៣០ ថ្ងៃក្រោយពេលនៃការប្តូរលិខិតូបករណ៍នៃការធ្វើសច្ចាប័ន ។

២. ភាគីនៃកិច្ចព្រមព្រៀងនីមួយៗអាចបញ្ចប់សន្ធិសញ្ញានេះបាន ដោយផ្តល់ដំណឹងជាលាយល័ក្ខអក្សរ ទៅភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀតតាមរយៈផ្លូវទូត ។ សន្ធិសញ្ញានេះនឹងស្ថិតនៅជាធរមាន រហូតរយៈពេល៦ខែក្រោយពេលដែលភាគីម្ខាងទៀត ទទួលបានការផ្តល់ពត៌មានស្តីពីការបញ្ចប់នេះ ។ ការបញ្ចប់នៃសន្ធិសញ្ញានេះមិនត្រូវធ្វើឱ្យប៉ះពាល់ដល់នីតិវិធីនៃបត្យាប័ននានា ដែលផ្តើមអនុវត្តមុន ការបញ្ចប់សន្ធិសញ្ញានេះឡើយ ។

ដើម្បីជាសក្ខីភាព អ្នកតំណាងដែលបានទទួលសិទ្ធិពេញលេញពីរដ្ឋាភិបាលរៀងៗខ្លួន បានចុះហត្ថលេខាលើសន្ធិសញ្ញានេះ ។

ធ្វើជាពីរច្បាប់ នៅ ប៉េកាំង ថ្ងៃទី ...០៩... ខែ កុម្ភៈ ឆ្នាំ មួយពាន់ប្រាំបួនរយកៅសិបប្រាំបួន ជាភាសាខ្មែរ ភាសាចិន និង ភាសាអង់គ្លេស ។ អត្ថបទនីមួយៗមានតំលៃស្មើៗគ្នា ។ ក្នុងករណីមាន ការបកស្រាយខុសគ្នាអត្ថបទជាភាសាអង់គ្លេស ត្រូវយកមកប្រើប្រាស់ជាឯកសារគោល ។

តំណាងព្រះរាជាណាចក្រកម្ពុជា

តំណាងសាធារណរដ្ឋប្រជាមានិតចិន